ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

## កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៩

ខែ ៤, ៥, ៦, រួមគ្នា

កុងស៊ីយ៍សេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង

ទំព័រ


១ ខេមរាខេមសរណកថា (លទ្ធិមហាយាន) ព្រះមហាពិទូរ ក្រសេម រៀបរៀង (ត) ៣

២ ល្បើកច្បាប់ក្រឹត្យក្រម ព្រះគ្រូវិសុទ្ធិវង្ស ទិត វត្តសិរីសាគរ ស្រុកត្រែបែក ខែត្រព្រៃវែង រៀបរៀង (ត ចប់) . . . . . . . . . . . . . . . . ១៧

៣ ធនញ្ជ័យបណ្ឌិត រឿងខ្មែរ (ត ចប់) . . . . . . . . . . . . . . . . . ៣១

៤ រឿងព្រេងខ្មែរ រឿងគង់ហ៊ាន (ត ចប់) . . . . . . . . . . . . . . . ៤៥


# រូបក្រៅរឿង


១ លោកសង្ឃ ភូមា និមន្តដើរបាំងទាំងយូ ធ្វើអំពីសំពត់ព៌ណក្រហម ឬលឿង. ១

២ រូបអ្នកតា នឹងរូបភាព ដំណាលរឿងត្រង់ព្រះនាងមហាមាយាទ្រង់ព្រះសុបិន . . ១៥

# TABLE DES MATIÈRES

I. Khem'âKhema Saranakathā ou Religions, refuge des hommes........................................ 3

II. Lois morales (Poème)................................ 17

III. Histoire de Thmenh chey............................ 31

IV. Conte Cambodgien inédit Kong le brave.............. 45

## HORS TEXTE:

I. Bonze birman avec son ombrelle de toile laquée rouge ou jaune........................................ 1

II. L'entrée de la pagode de Nagayon—le génie protecteur et l'image représentant le rêve de Maya-Pagan-Birmanie. 15



លោកសង្ឃភូមា និមន្តដើរ បាំងឆាំងយូធ្វើពីសំពត់ជ្រលក់ពណ៌
ក្រហម ឬលឿង ។

ខេមាខេមសរណាគាថា

# ខ្សែ ៤ (ត)

## ព្រះមហាពិទូរក្រសេមគន្ធរបទបណ្ឌិត

រៀបរៀង

[stamp]

ពាក្យដែលហៅថា មហាយាន ដូច្នេះ ជាឈ្មោះនៃគតិធម៌ តាមអាការដែលបុគ្គលសម្មតិឡើង ពួកអ្នកប្រព្រឹត្តតាមលទ្ធិនេះ គោរពរាប់អានព្រះពុទ្ធជាម្ចាស់ (គឺព្រះសាក្យមុនី) យកជាសរណៈទីពឹងដែរ តែប្រកាន់លទ្ធិក្លាយផ្សេងទៅ ។

សារហេតុដែលព្រះពុទ្ធសាសនាបែកញែកជា ២ លទ្ធិដូច្នេះ តាំងតែកាលព្រះសង្ឃពួកវជ្ជីបុត្តប្រែកែធម៌វិន័យ លើកយកវត្ថុ ១០ ប្រការឡើងអាង ព្រះសង្ឃទាំងពួងក្រៅអំពីពួកនេះមិនយល់ព្រមផង ព្រោះវត្ថុ ១០ ប្រការនេះជាហេតុ ទើបនាំគ្នាធ្វើទុតិយសង្គាយនាក្នុងកាល ព. ស... នោះមក, រឿងនេះកើតឡើងក្នុងប្រទេសឥណ្ឌៀ ពួកព្រះសង្ឃដើមដែលកាន់តាមពុទ្ធវចនៈក្នុងវេលានោះ គេហៅថា ទក្ខិណនិកាយ ព្រោះពួកនេះច្រើននៅក្នុងប្រទេសប៉ែកខាងត្បូង ហើយប្រកាសសាសនាផ្សាយមកក្នុងប្រទេសភាគខាងត្បូងតាំងតែនគរមគធៈមក លទ្ធិធម៌ដែលពួកនេះកាន់ ហៅថា ថេរវាទ កាន់តាមបែបវាទៈដែលព្រះអរិយសាវកលោកធ្វើសង្គាយនា, បំណែកឯពួកវជ្ជីបុត្តដែលបែកពួកចេញទៅ ហៅថា ឧត្តរនិកាយ ប្រែថាពួក

ខាងជើង ព្រោះពួកនេះច្រើននៅក្នុងប្រទេសប៉ែកខាងជើង ហើយប្រកាសសាសនាផ្សាយចេញទៅក្នុងប្រទេសប៉ែកខាងលើ តាំងតែនគរវេសាលីរហូតទៅនគរគន្ធារ លទ្ធិធម៌ដែលពួកនេះកាន់ហៅថា អាចរិយវាទ កាន់តាមវាទៈដែលអាចារ្យតាំតៗមក, វេលាក្រោយមកពួកឧត្តរនិកាយបញ្ញត្តិហៅតាមលទ្ធិ ដែលខ្លួនកាន់ថា មហាយាន ដោយអធិប្បាយថា លទ្ធិនេះអាចដឹកនាំអ្នកបដិបត្តិតាមទៅកាន់សួគ៌និព្វានបានច្រើន ប្រៀបដូចជាយានដ៏ធំទូលាយផ្ទុករបស់ទ្រព្យបានច្រើនដូច្នោះ ហើយហៅលទ្ធិដែលពួកទក្ខិណនិកាយកាន់ថា ហីនយាន ដោយអធិប្បាយថា លទ្ធិនេះតូចចង្អៀតដឹកនាំអ្នកបដិបត្តិតាមទៅកាន់សួគ៌និព្វានបានតិច ប្រៀបដូចជាយានដ៏តូចដឹកនាំរបស់ទ្រព្យបានបន្តិចបន្តួចដូច្នោះ ពួកព្រះសង្ឃមហាយានិកនិកាយនោះបើនឹងចង្អុលតួយ៉ាងក្នុងវេលានេះបាននឹងលោកសង្ឃ យួន ចិន យីប៉ុន ធិបេត៍, ព្រះសង្ឃពួកហីនយានិកនិកាយនោះគឺព្រះសង្ឃ គណៈមហានិកាយ គណៈធម្មយុត្តិក៍ ក្នុងប្រទេសខ្មែរ-សៀម នឹងព្រះសង្ឃភូមា-មន លង្កាជាដើម ព្រះសង្ឃទាំងពីរនិកាយនេះ

រាប់អានព្រះពុទ្ធសាសនាជាមួយគ្នា តែពួកមហាយានិកនិកាយបានលះបង់ចោលសិក្ខាបទពុទ្ធបញ្ញត្តិដែលមកក្នុងភិក្ខុបាតិមោក្ខជិតអស់ទៅហើយ នៅសល់បន្តិចបន្តួចថែមទាំងកាន់ក្លាយខុសអំពីរូបដើមទៅជាច្រើនសព្វថ្ងៃនៅមានសំគាល់តែកោរសក់ក្បាលស្លៀកដណ្តប់ពណ៌លឿង ពណ៌លឿងនោះជាខោជាអាវអស់ទៅហើយ មិនមែនជាស្បង់ចីពរ រោងឧបោសថសង្ឃកម្មក៏គ្មានសីមាតាមពុទ្ធបញ្ញត្តិ ។ល។ ធម៌វិន័យជ្រើសរើសកាន់តាមគាប់ចិត្តរបស់ខ្លួនតែម្តងក៏នៅអួតខ្លួនថា មហាយាន ។

ការប្រព្រឹត្តិប្រតិបត្តិសព្វថ្ងៃប្រាថ្នាផលជា ២ យ៉ាង គឺ

១- ប្រាថ្នាឲ្យបានជាពោធិសត្វនឹងបានត្រាស់ជាព្រះពុទ្ធ

២- ប្រាថ្នាឲ្យបានទៅកើតក្នុងខេត្រសុខាវតី, ក្នុងខទី ១ តាមគតិមហាយានកាន់ថា បុគ្គលទាំងអស់គ្នាមិនគួរប្រាថ្នាយកភូមិជា បច្ចេកពុទ្ធ ឬជាអរហន្តខីណាស្រព ព្រោះបុគ្គល ២ ជំពូកទៅកាន់ព្រះនិព្វានតែខ្លួនម្នាក់ឯង មិនជាប្រយោជន៍ដល់អ្នកដទៃ គួរប្រាថ្នាតែពុទ្ធភូមិ ១ យ៉ាងប៉ុណ្ណោះ នឹងបានបម្លងសត្វឲ្យឆ្លងវដ្តសង្សារជាមុនសិនហើយសិមខ្លួនចូលព្រះ

និព្វានជាងក្រោយ លើកយករឿងព្រះពោធិសត្វកាលសោយព្រះជាតិជាសុមេធតាបស ក្នុងសាសនាព្រះទីបង្ករ វេលាដែលលោកបានជួបនឹងព្រះពុទ្ធទីបង្ករនោះ លោកមានឧបនិស្ស័យបាស់ក្លាគួរដល់ព្រះអរហត្តហើយ តែលោកមិនស្រឡាញ់សាវកភូមិ ទើបសុំប្រាថ្នាពុទ្ធភូមិឲ្យបានត្រាស់ជាព្រះពុទ្ធ នឹងបានប្រោសសត្វដាក់ដល់ត្រើយគឺព្រះនិព្វាន ជាគ្រឿងអាង, កាលមានគតិរាប់អានដូច្នេះជាមូលហេតុហើយក៏ប្រដៅមនុស្សទាំងឡាយឲ្យប្រាថ្នាជាពោធិសត្វរាល់ៗគ្នា ជំនួសដែលប្រាថ្នាឲ្យបានមគ្គផលមកអំពីដើម អ្នកដែលបំពេញគុណសម្បត្តិដើម្បីជាព្រះអរិយបុគ្គល ក៏កាន់ទៅថាជាពោធិសត្វទៅអស់ ទើបកើតរាប់អានព្រះពោធិសត្វឡើងជាសំខាន់ក្នុងលទ្ធិមហាយាន ក៏ឯពោធិសត្វនោះគេកំណត់ទុកជាធ្យានីពោធិសត្វ គឺពោធិសត្វដែលកើតឡើងដោយអំណាចឈានរបស់ព្រះពុទ្ធ ១ យ៉ាង មនុស្សពោធិសត្វ គឺមនុស្សដែលកសាងបារមីដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធ ១ យ៉ាង, មនុស្សពុទ្ធ គឺមនុស្សដែលបានត្រាស់ជាព្រះពុទ្ធក្នុងមួយអង្គ ៗ តោងមានធ្យានីពោធិសត្វមួយ ៗ ស្ថិត

នៅឯឋានសួគ៌ ជាអ្នកនៅចាំថែរក្សាសាសនារបស់ព្រះពុទ្ធអង្គនោះ ជាដូច្នេះរាល់អង្គទៅ ដូចយ៉ាងក្នុងសាសនាព្រះពុទ្ធកកុសន្ធ មានព្រះពោធិសត្វឈ្មោះ សមន្តភទ្រពោធិសត្វជាអ្នករក្សាព្រះសាសនា, ព្រះពុទ្ធកោនាគមនមានព្រះពោធិសត្វឈ្មោះវជិរបាណីពោធិសត្វជាអ្នករក្សាសាសនា, ព្រះពុទ្ធកស្សបមានព្រះពោធិសត្វឈ្មោះ រតនបាណីពោធិសត្វជាអ្នករក្សាសាសនា, ព្រះពុទ្ធគោតមមានព្រះពោធិសត្វឈ្មោះអវលោកិតេស្វរ (ឬលោកេស្វរ) ពោធិសត្វជាអ្នករក្សាសាសនា, ព្រះអរិយមេត្តេយ្យដែលនឹងត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល នឹងមានពោធិសត្វឈ្មោះវិស្វបាណីពោធិសត្វ ជាអ្នករក្សាសាសនា, ព្រះពុទ្ធអំពីបូរាណក្តី ព្រះពុទ្ធដែលនឹងត្រាស់ទៅខាងមុខ ៗ ក្តី តាមគតិមហាយានថា សុទ្ធតែមានធ្យានីពោធិសត្វមួយអង្គ ៗ នៅចាំរក្សាសាសនាដូច្នេះរាល់អង្គ សំដែងគុណរបស់ព្រះពោធិសត្វក្រៅអំពីរក្សាសាសនា គឺជាអ្នកជួយស្រោចស្រង់សត្វឲ្យរួចចាកគ្រោះថ្នាក់ទុក្ខសោករោគភ័យផ្សេង ៗ កំណត់ទុកដោយន័យមាន ១១ យ៉ាង គឺ ជាប់គុក, លង់ទឹក, ភ្លើងឆេះ, ដំរីព្រៃ,

ពោះបឹក, រាជសីហ (ឬខ្លា) ខាំ, យក្ខចាប់, សឹកសង្គ្រាម, រន្ទះបាញ់, ជម្ងឺដម្កាត់, ស្តេចខ្ញាល់, ហេតុនោះពួកអ្នកកាន់លទ្ធិនេះ ទើបសាងរូបព្រះពោធិសត្វមានដៃ ៤ ហើយកាន់របស់ជាសំគាល់គុណសម្បត្តិ គឺ ដៃ ១ ផ្កាឈូក ៗ នេះជារបស់សំគាល់ក្នុងព្រះពុទ្ធសាសនាមួយយ៉ាង, ដៃ១កាន់កុណ្ឌីទឹកៗនេះជារបស់សំគាល់ថាអ្នកនោះជាពេទ្យ បេះស្រោចទឹកមន្តរម្ងាប់ជម្ងឺដម្កាត់ទុក្ខសោករោគភ័យចង្រៃឧបទ្រពផ្សេង ៗ បាន រូបបែបនេះក្នុងប្រទេសកម្ពុជានេះក៏មាន អ្នកប្រាថ្នាចង់ឃើញសុំឲ្យទៅមើលនៅប្រាសាទបាយ័នក្នុងក្រុងនគរធំ ១ កន្លែង នៅប្រាសាទនាគ-ព័ន្ធ ១ កន្លែង ដែលធ្វើជាដៃ ២ ដៃ ៨ ក៏មានច្រើន មានលក្ខណៈប្លែកអំពីរូបដទៃ គឺមានព្រះពុទ្ធរូបនៅត្រង់ជើងសក់ខាងមុខ និងមានគ្រឿងកាន់ក្នុងដៃដូចពោលមកហើយ ។

បំណែកឯព្រះពុទ្ធនោះ តាមគតិដើមកាន់ថា មានទាំងក្នុងអតីត បច្ចុប្បន្ន និងអនាគត ពួកអ្នកកាន់លទ្ធិមហាយានមកប្រែកែគតិនេះឲ្យប្លែកចេញទៅថា ព្រះពុទ្ធមានពេញពាសទួទៅក្នុងអនន្តចក្រវាឡ ហើយសម្មតិភូមិព្រះពុទ្ធជា ៣ យ៉ាង

ផ្សេងអំពីគ្នា គឺ ១- ព្រះពុទ្ធមួយយ៉ាងនោះ ហៅថា ព្រះសយម្ភូពុទ្ធ ឬហៅថា ព្រះអាទិពុទ្ធ ១ អង្គជាព្រះដើមបង្អស់កើតឡើងឯងព្រមនឹងលោក (គឺទឹកដីនេះ) ហើយនៅប្រចាំក្នុងលោកនេះជានិច្ចនិរន្តរ៍ មិនបេះបុតប្រែប្រួលទៅឯណា ២- ថាមានព្រះធ្យានីពុទ្ធ ឬហៅថា ព្រះអមិតាភពុទ្ធ ទៀត ៥ អង្គកើតឡើងដោយអំណាចឈានទាំង ៥ របស់ព្រះអាទិពុទ្ធ នៅជាប្រធានក្នុងឋានសួគ៌ ជាអ្នកបណ្ដាលឬជាអ្នកអញ្ជើញព្រះពោធិសត្វឲ្យចុះមកកើតក្នុងមនុស្សលោកជាមនុស្សពុទ្ធ ៣- បណ្ដាមនុស្សជាតិដែលបានត្រាស់ជាព្រះពុទ្ធក្នុងលោកនេះ ហៅថា មនុស្សពុទ្ធ ព្រះពុទ្ធអង្គទាំង ២៨ អង្គ មានព្រះតណ្ហង្ករជាដើមរហូតដល់ព្រះគោត្តមសាក្យមុនី តាមគតិមហាយានរាប់ថាជាមនុស្សពុទ្ធទាំងអស់ ។

ក្នុងខទី ២ ដែលថា ប្រាថ្នាឲ្យបានទៅកើតក្នុងខេត្រសុខាវតី នោះ ពួកអ្នកកាន់លទ្ធិមហាយានមានសេចក្ដីជឿនឹងរាប់អានតាមសេចក្ដីក្នុងព្រះសូត្រ ១ ឈ្មោះថា អមិតាយុសូត្រ

ដោយហេតុថា ព្រះសូត្រនោះបេញអំពីពុទ្ធឧស្ម គឺព្រះពុទ្ធអង្គទ្រង់សំដែងដោយព្រះអង្គឯង អាងមានអ្នកបានស្ដាប់បានឮជាច្រើនគ្នា ក៏ឯព្រះសូត្រនោះពណ៌នាសរសើរអំពីសេចក្ដីសុខសប្បាយក្នុងខេត្រសុខាវតីជាយ៉ាងបំផុត ត្រូវឲ្យមនុស្សឧស្សាហ៍ប្រព្រឹត្តបដិបត្តិនឹងបានទៅកើតក្នុងទីនោះ អំពីនេះនឹងបាននាំយកសេចក្ដីនៃអមិតាយុសូត្រ ដែលមានក្នុងលទ្ធិនោះមកសំដែងក្នុងទីនេះដូចមានតទៅនេះ

## អមិតាយុសូត្រ

គ្រាមួយនោះ ព្រះដ៏មានព្រះភាគត្រាស់នឹងព្រះសារីបុត្រថា

១ "អំពីទីនេះទៅចម្ងាយ ១០០.០០០ យោជន៍ ខាងប្រស្ចិមទិសមានលោកធាតុ ១ កន្លែងឈ្មោះថា សុខាវតី ក្នុងទីនោះព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា អមិតាយុសៈ ស្ដេចស្ថិតនៅសោយសុខារម្មណ៍ នឹងទ្រង់សំដែងធម៌នៅក្នុងកាលឥឡូវនេះ ម្នាលសារីបុត្រ ម្ដេចលោកធាតុនោះទើបឈ្មោះសុខាវតី ក៏ព្រោះថាសត្វទាំងឡាយក្នុងទីនោះ គ្មានទុក្ខ

ក្នុងកាយ-ក្នុងចិត្ត មានតែសេចក្ដីសុខពន់ប្រមាណ ហេតុនោះទើបឈ្មោះថា សុខាវតី" ។

២ "ខម្លួយទៀត សារីបុត្រ ក្នុងសុខាវតីលោកធាតុនោះ មានកំពែងកែវ ៧ ជាន់ មានដើមត្នោត ៧ ជួរ មានក្រឡាសំណាញ់ព័ន្ធព័ទ្ធជុំវិញបរិវេណ មានកណ្ដឹងមាសព្យួរយោងយោលទង្គិចគ្នាឮសូរស័ព្ទពិរោះល្ងៀងល្ងើយ ដ៏ហើយទៅដោយកែវ ៤ ប្រការ ព័ន្ធព័ទ្ធជុំវិញបរិវេណនោះទៀត ហេតុនោះទើបឈ្មោះសុខាវតី" ។

៣ "ខម្លួយទៀត សារីបុត្រ ក្នុងខេត្រសុខាវតីនោះ មានស្រះកែវ ៧ ប្រការ គឺស្រះមាស ប្រាក់ ពិទូរ្យ ផលិក ទទឹម ព្រពាឡ ប៉ុតពណ៌ (ប៉ុតឡាយ) ពេញព្រៀបទៅដោយទឹកដ៏មានអដ្ឋង្គិកគុណ នៅបាតស្រះនោះមានខ្សាច់មាស ទាំង ៤ ទិសនៃស្រះនោះមានជណ្ដើរដ៏វិចិត្រ ប្រឌិតឡើងដោយមាស ប្រាក់ កែវពិទូរ្យ កែវផលិក, លើមាត់ស្រះមានដើមឈើ ៧ ប្រការ ដុះរៀងរាយល្អមុខគួរមើល ជាទីត្រជាក់ចិត្ត ត្រជាក់

ភ្នែកក្រៃពេកណាស់ ក្នុងស្រះនោះមានផ្កាបទុមជាតិប្រមាណ ប៉ុនកង់រទេះ ខ្លះពណ៌លម្មង់ ខ្លះពណ៌លឿង ខ្លះពណ៌ក្រហម ខ្លះពណ៌ស សុទ្ធតែល្អះល្អ ទ្រង់ក្លិនត្រឡប់អប់អសីទាំងស្រះ ភរិ ម្នាលសារីបុត្រ សុខាវតីពុទ្ធក្សេត្រ រមែងមានគ្រឿង ប្រដាប់នឹងគុណវិសេសផ្សេង ៗ ដូច្នេះ ។



រូបអ្នកតានឹងរូបភាពដំណាក់លរឿងត្រង់ព្រះនាងមហាមាយា ទ្រង់ព្រះសុបិន គេធ្វើទុកនៅក្លោងទ្វារចូលទៅវត្តនាគយោង សាងកាល ព.ស. ១.៦៥៥ ស្រុកបាគន ភូមា ។

# ច្បាប់ក្រិត្យក្រម
(តបប់)

ដែលនាំខ្លួនខូចពីព្រោះខឹង អន្តរាយមិនដឹងខ្លួនសោះឡើយ
នាំទាញលិបលង់មិនដឹងត្រើយ អ្នកកើយអ្នកគិតឲ្យមែនទែន ។
អ្នកគិតតែល្អត្រូវត្រឹមត្រង់ ល្មមអ្នករំពឹងលើខ្លួនបាន
ទៅណាយកទៅជាប់នឹងប្រាណ គ្រាន់បានផ្ញើរូបផ្ញើជីវិត ។
តាមបន្ទូលព្រះអង្គទុកឲ្យ នឹងបានទៅសោយសួគ៌សម្បត្តិ
កោតខ្លាចឲ្យទៀងទាត់ប្រយ័ត្ន កុំឲ្យមានភ្លាត់ភ្លាំងប្លស់ល្ហោយ ។
បើជាប់ធម៌សីលទានទៅរ៉ា គ្រាន់បានជាគ្នាយិតយោងជួយ
រាប់អានស្រឡាញ់ដូចខ្លួនមួយ សីលទាននេះហើយស្មើជីវិត ។
ឲ្យអ្នកភាវនាតែសព្វថ្ងៃ អកុសលចង្រៃគ្មានហ៊ានជិត
បាក់បបខ្លបខ្លាចខ្ចាយប្រាសព្រាត់ អន្តរធានបាត់ខ្ចាត់ទៅឯង ។
អ្នកកុំស្អប់ខ្ពើមសីលសិក្ខា លោកសង្ឃអាចារ្យក្តីចៀសវាង
ដូងកែវកំណើតដល់រូបរាង លោកតែងដុះលាងរូបខ្មោ ។
ព្រះធម៌ថ្លៃថ្លាគ្មានស្អប់សត្វ អ្នកកុំគិតកាត់មិនដឹងគួរ
លោកតែងដឹកដៃអ្នកទៅសួគ៌ កុំគិតបិត្តជួរគួរខ្លាចស្លាប់ ។
តែផុតរលត់ទៅកាលណា ទៅតាមវេរាបុណ្យនឹងបាប
ធ្វើអ្វីបាននោះជាជំរាប ប្រាប់យំភូបាលធ្វើតាមកម្ម ។

ត្រូវដុតត្រូវស្ងោរត្រូវស្លុបថ្ពក់　ត្រូវដោលត្រូវរុកកាប់បិញ្ច្រាំ
ត្រូវឡើងរការដែកតាមកម្ម　តាមហេតុដែលបាំធ្វើហួសហើយ ។
ទោសខ្លះត្រូវបុកអង្រែដែក　ល្អិតល្អោចខ្ទេចបែកដូចសំឡី
ស្លាប់ហើយរស់វិញតែរាល់ថ្ងៃ　រងភ័យនរកវេទនាណាស់ ។
ស្រែកយំសន្លោបខ្លោចឈឺផ្សា　ពីព្រោះអាត្មាធ្វើកម្មគ្រាស់
ប្រកាច់ដីដើធ្វើទីសទាស　ផ្តួលផ្តាសរកអ្វីទីពឹងគ្មាន ។
យំទួញស្រែកហៅប្រពន្ធប្តី　កូនចៅប្រុសស្រីតាមមួយគ្មាន
ហុតខ្ទុះផឹកឈាមដោយសារឃ្លានមិនអាចអ្វីស៊ីលំបាកណាស់ ។
ខំស្រែកអង្វរយមបាល　ថាខ្ញុំរាងចាលហើយលោកម្ចាស់
គេរឹតរូតបងបិងវាយទះ　ថាពះអាហោរខូចអប្រិយ៍ ។
មឹងឯងលួចប្លន់កាប់ចាក់គេ　មិនមានទំនេរតែរាល់ថ្ងៃ
ប្រពន្ធប្តីគេឯងគាប់ចៃ　លួចមិនប្រណីព្រោះចិត្តធំ ។
ប្រមាថម៉ែឪគ្រូអាចារ្យ　ជញ្ជីងធ្ងន់ស្រាលប្លឹងបន្លំ
ដេញបាញ់អម្រឹកសត្វតូចធំ　មិនមេត្តាពុំប្រណីឡើយ ។
ផឹកស្រាស្រវឹងក្រហមភ្នែក　ចិត្តត្រអាលត្រេកមិនមានស្បើយ
គ្មានគិតធ្វើបុណ្យសីលទានឡើយ,រៀនធម៌ឲ្យហើយតាមស្ពាន។

រីយមពាលទាំងបួននាក់ តែងតែទាត់ធាក់ប្រាស់ប្រិប្រាន
កាន់លំពែងចាក់សុះសព្វប្រាណ អ្នកខ្លះសោះបានទឹកទង្គែង ។
យកមកចាក់ស្រែបហុបឲ្យទៅ ហើយកាន់ពួថៅឈើរកំហែង
ថាហ៍នេះស្រារបស់ឯង ដែលអាធ្លាប់តែងផឹកពីមុន ។
អញបិទយ៉ាងល្អទុកសម្រាំង ក្បាលស្រាយ៉ាងខ្លាំងពីសាស៊ុន
ផឹកទៅអាវ៉ាវ៉ាបាត់គ្រិន មិនបាច់គ្រេរគ្នាន់គិតប្លែប្លរ ។
អញឲ្យអាពាងឯងផឹកបុះ ដោយបិត្តអញស្មោះមិនលក់ដូរ
ឲ្យផឹកទទេគ្មានប្លែប្លរ ដ្បិតធ្លាប់ផឹកហួរពីដើមមក ។
រីឯអស់ពួកសត្វនរក ភ័យភិតជាទុករត់ពួនជ្រក
យំភ្លូបាលគម្រាមដេញសង្រ្គប់ ដេរស្រែកកំហកកំហែងចាក់ ។
បានហើយបំផឹកទឹកទង្គែង គិតទៅគួរស្ញែងភ្លើងឆេះឆាប់
រលាករលួយរលាយស្លាប់ ប្រែប្រាណក្រឡាប់រស់ឡើងវិញ
អាហារនៅក្នុងស្ថាននរក នោះមានតែល្មក់ខ្ទុះឈាមមិញ
ហើយក្រនឹងបានស៊ីឲ្យពេញ ពោះកើតទុក្ខម្នេញនឹងភ្លើងក្តៅ។
ឯណាស្រែកទឹកស្ងួតខាស់ក ឃើញទឹកហ្វាល្អរត់សំដៅ
ស្ទើរស្ទុះស្ទើរលោតរត់លឿនស្លៅលុះបានដល់ទៅក្បែងទឹកឡើង។

ពុំទាន់នឹងបានដល់ក្នុងពោះ  រីឯទឹកនោះក្លាយជាភ្លើង
ឆាបឆេះដាលរាលដល់ចុងជើង  ស្ទុះរត់ក្រញើងភ្ញាក់សស្គុះ ។
ភ្លើងឆេះខ្មៅរោលរលួយសាប់  របួតអស់អាចម៍ពីក្នុងពោះ
ស្លាប់ហើយបណ្ដាលឡើងជារស់  មិនខុសមួយថ្ងៃមួយរយដង ។
តែងតែនឹងស្លាប់ក្រឡាប់កើត  រាប់ជាតិកំណើតច្រើនកន្លង
វេទនារងទុក្ខរងទោសផង  ស្រែកយំរំពងរងកម្មក្រាស ។
សម្ដែងអំពីសត្វនរក  នឹងលើកស្លេះទុកបុណ្ណោះប៉ុះ
មានច្រើនប្រការថ្លែងមិនអស់  គ្រាន់នេះនឹងថ្លែងលោកិយវិញ ។
លោកិយនេះត្រូវតែខំរៀន  បំណោះរបៀនខំទន្ទេញ
ធម៌បរមត្ថអត្ថប្រែចេញ  ជាពាក្យខ្មែរវិញតាមតិចច្រើន ។
មួយមាត់ពីរមាត់ខំឧស្សាហ៍  តាំងចិត្តភាវនានឹងចម្រើន
ផលានិសង្សនឹងបានកើន  បើមិនក្រវើនឥតអំពើ ។
ចេះតិចចេះច្រើនឲ្យជាក់ច្បាស់  កុំសូត្រផ្ដេសផ្ដាសជាពពើ
បន្លែបន្លំដូចមមើ  ដេរដើផ្ដេសផ្ដាសមិនច្បាស់តួ ។
ជឿងធ្ងល់ត្រង់ណាប្ដូរប្រតិបត្តិ  លោកណាចេះស្ទាត់ឲ្យសើុបសួរ
ពិនិត្យសង្កេតរៀងរាល់តួ  ចាំទុកទៅគួរនឹងមានអាង ។

សេចក្ដីស្លាប់មានតែរាល់គ្នា    គួររាងគួររាគួរខំសាង
កំណាត់មានឈ្មោះនៅក្នុងក្រាំង    ចាប់បានកើបឆាំងវាមិនលែង ។
ជាអ្នកកន្ទ្រឹសកាបអាក្រក់    ប្ដូលចាប់កាប់ចក់គិតកោតក្រែង
សំពះបង់ដៃគ្មានយល់ឯង    ចាប់បានមិនលែងឲ្យរួចទេ ។
ទុកជាមាសប្រាក់ទាំងប៉ុន្មាន    គេមិនទុកប្រាណនៅទំនេរ
បោលកូនបោលចៅបោលឪម៉ែ    បោលកេរ្តិ៍បោះស្រែទ្រព្យរបស់
អង្វរថាខំធ្វើបុណ្យទាន    ឧទ្ទិសបញ្ជូនឲ្យលោកម្ចាស់
សូមបង្អង់ឲ្យរៀបកូនអស់    គេគ្មានស្រណោះស្ដាប់អ្នកទេ ។
ថាឱអ្នកផងទាំងឡាយយើយ    មរណនេះហើយមិនទំនេរ
មានរាល់តែរូបមិនតែគេ    យើងក៏មានដែរមិនរម្លង ។
តាមព្រះពុទ្ធដីកាឲ្យភាវនា    រំឭកគាថាបីបទផង
ឲ្យរឿយ ៗ ណាស់កុំរម្លង    ទើបបានផលផងយ៉ាងឧក្រិដ្ឋ ។
អជិរំស្មេវថ្ងៃនេះស្អែក    បរមស្មេវខានស្អែកពិត
ឲ្យខំភាវនារំពឹងគិត    ថាអញប្រាកដជានឹងស្លាប់ ។
រំឭកឲ្យជាប់រាល់វេលា    កុំឲ្យឃ្លាតឃ្លាមិនត្រង់ត្រាប់
ឲ្យលង់ចិត្តចុះទៅតាមច្បាប់    ទើបគាប់ដូចព្រះបន្ទូលថា ។

សង្វេគបង្កើតកុំឲ្យភ្លេច ឲ្យបានសម្រេចធម៌អនិច្ចា
រំពឹងឲ្យច្បាស់ផ្ចាលផ្ដន្ទា ជាអញត្រូវការស្លាប់មិនលែង ។
ភាវនាកុំភ្លេចរាល់វេលា ឲ្យបានពិស្តារច្រើនយូរវែង
បង្កើតបង្ហាត់គំនិតឯង គួរស្វែងខ្លាចស្លាប់រូបវេទនា ។
រតនៈត្រ័យទាំងបីបទ ឲ្យចាំរត់មាត់រៀងរាល់ឃ្លា
ថ្វាយបង្គំព្រះរាល់វេលា ជាគ្រឿងសស្ត្រាការសត្រូវ ។
សំគាល់ធម៌ណាជាបរមត្ថ ប្រុងប្រៀបប្រយ័ត្នចាំទុកទៅ
រាល់រូបមុខជាមិនលែងត្រូវ ការស្លាប់មានទៅរូបទាំងអស់ ។
អាហារឲ្យធម៌កម្របាន ព្រលឹងវិញ្ញាណមិនញសោះ
ស្លូតអាត់ប្រហារក្រៀមផ្អស់ លុះតែភ័ព្វខ្ពស់ទើបស្តាប់បាន ។
អរហំតាំងចិត្តគិតឲ្យហើយ អ្នកកុំបណ្តោយឲ្យបាកស្មាន
សំណាងតិចច្រើនបានមិនបាន កុំខានចាំតែទំពឹងគេ ។
កុំអួតកុំអាងសំណាងខ្ពស់ ក្រែងជួនជាខុសទៅទទេ
វេទនាខ្វេសខ្វាស់ដូចជាគេ គិតគ្នេរទៅឃើញលំបាកក្រៃ ។
មរណទុក្ខនេះលំបាកណាស់ លុះដល់ប្រទះទើបបានភ័យ
មិនដឹងជាក្រឬងាយ យើងអ្នកនៅអោយមិនដឹងសោះ ។

ស្លាប់ទៅប៉ុន្មានបាត់សូន្យឈឹង  គ្មានឮដំណឹងនៅតែឈ្មោះ
ធ្វើបុណ្យតែរូបដូចគល់ឧស  ដុតតារបញ្ចុះហ៏បានហើយ ។
ត្រង់ក្រត្រង់ងាយគ្មានដំណឹង  មិនមានវិលវិញមកប្រាប់ឡើយ
ដុតតារបានទៅទុកព្រើយ  អ្នកអើយគេធ្វើះបគុណទេ ។
បើកូនស្រុះស្រួលហើយចិត្តស្មោះ  ធ្វើបុណ្យចំពោះទៅឪម៉ែ
តាមដោយសុចរិតបានខ្វះអែរ  បើចិត្តវាប្រែមិនត្រង់ស្មោះ ។
អ្នកកុំរំពឹងបានទៅដល់  វាគិតខ្វាយខ្វល់នឹងរបស់
ចិត្តវាក៏ដឹងមិនត្រង់ស្មោះ  ធ្វើច្រើនក្រែងអស់ក្រខ្លួនវា ។
វារៀបដំណើរដាក់ទៅឲ្យ  របស់ខ្សត់ខ្សោយយ៉ាងខ្ជា
ប្រអប់បានឆ្នាំងកាំបិតព្រា  ទ្រព្យណាគិតការវាដាក់ផ្លុង ។
ទិញផ្តិលឬហ៊ាសប្រអប់ស្តើង  បង្សុកូលដំកើងថ្វាយព្រះសង្ឃ
អាខ្មែរសោះស្តាយយំទ្រហឹង  ស្មើរនឹងផ្ទះខ្លួនស្ងួមទៅផង ។
អាខ្មែរខ្លាំងណាស់មួយខែប៉ាយ  បែកទ្រព្យប្រញាយគ្រប់ប្អូនបង
បានតិចបានច្រើនកើតសៅហ្មង  ប្អូនបងទាស់គ្នាកើតក្តីក្តាំ ។
អ្នកអើយខំប្រឹងចិញ្ចឹមកូន  ផ្ទះចិត្តផ្ទះខ្លួនទំនងពៀរកម្ម
មិនឲ្យអត់ឃ្លានប្រឹងទ្រាំទ្រា  ដល់ខ្លួនប្រែប្រមបាស់ជាវា ។

រកកូនណាមួយអាសូរគ្មាន    ប្រដៅទូន្មានមិនស្តាប់ណា
ប្រទុស្តរឹងរុះឈ្លោះឆ្លើយថា    ឬស្ប៉ាផ្ដិញផ្ដាល់បង្អាប់វិញ ។
ស្រឡាញ់កូនស្មើប្តូរជីវិត    ខំអត់មិនហ៊ានហើបហាបេញ
ទឹកភ្នែកសស្រោកពោះពោរពេញ    កូនបៅស្រឡាញ់មិនដូចចិត្ត
ម្លោះហើយខឹងខ្ញាញ់ស្ដីឲ្យវា    ឥតមានកូនណាដូចគំនិត
វាថាឯងចាស់មិនប្រព្រឹត្ត    ម្លោះហើយខឹងបិត្តអាណិតខ្លួន ។
ទ្រព្យធនណាល្អមិនធ្វើបុណ្យ    ផ្គត់ផ្គង់អម្រែងទុកឲ្យកូន
បុណ្យទានមិនបានធ្វើមាំមួន    ក្រែងកូនគ្មានស៊ីគ្មានស្លៀកពាក់
ទាល់តែស្លាប់ទៅវេទនា    ឥតមានកូនណាជួយធុរៈ
ទ្រព្យរបស់បែកវិមានមាសប្រាក់    គិតចុះណាអ្នកកុំសង្ស័យ ។
ស្លាប់ទៅរំពឹងកូនធ្វើបុណ្យ    ពិចារណាចុះជនទាំងប្រុសស្រី
តែមិនប្រយ័ត្នទៅអវិចី    ធ្វើអ្វីធ្វើទៅទាន់ខ្លួនរស់ ។
រៀនធម៌ប្រតិបត្តិតាមសម្មា    ព្រះអង្គទេសនាមិនដែលខុស
រៀនសូត្រភាវនាទាន់ខ្លួនរស់    គួរគិតពិគ្រោះនឹងអ្នកប្រាជ្ញ ។
គេធ្វើបុណ្យឲ្យមិនទៀងណា    ស្រេចនៅអាត្មាក្រែងកោតខ្លាច
កាន់សីលភាវនារាល់ព្រឹកល្ងាច    នោះអាចប្រាកដទៀងជាបាន។

ដល់វេលាស្លាប់លះលែងជាតិ　អន្ទោលហ្វាឃ្លាតមនុស្សលោកហោង
តេជះភាវនាធម៌សីលទាន　នាំប្រាណហោះផ្សុងទៅតុសិត ។
ស្ថានទោះមែនមានប្រាង្គណ៍ប្រាសាទ　ប្រសើរស្អាងស្អាតអស់ពីចិត្ត
សម្បត្តិទិព្យប្រហូរបូលលែងគិត　រាប់ពុំអស់ឥតមានខ្វះអ្វី ។
មានហ្វូងនាងស្រីទេពកញ្ញា　នៅជាបរិវាររូបស្រស់ស្រី
ពីរពាន់សំរាប់ជាប្រក្រតី　មានតូរ្យតន្ត្រីត្រៃស្រឡៃ ។
ដេញដំប្រគំរាំច្រៀងថ្វាយ　ពួសពួស្សរសាយពីរោះក្រៃ
រាល់ពេលវេលាអាចិន្ត្រៃ　សព្វថ្ងៃគាប់ចែល្អបំឡែក ។
អស់ពួកស្រីស្នំក្រម្ភារគាល់　រាយរៀងរូបរាល់យ៉ាងឯក ៗ
ស្អាងខ្លួនចូលយាមតាមដោយវែក　ដោយពួកដោយប៉ែកវែកវេនគ្នា ។
គ្មានអាក់គ្មានអៀនគ្មានអន់ចិត្ត　គ្មានប្រណែនគិតនឹងនិន្ទា
តាមតែសព្វព្រះហឫទយា　នឹងរូបអ្នកណាឥតមន្ទិល ។
សម្តែងបែបនេះយ៉ាងហោកទាប　បើតាមសភាពអំណោចសីល
កាន់ខ្ជាប់ទំរៀនសូត្រកុំខ្ជិល　រំកិលជាតិកើនលឿនទៅមុខ ។
បានដល់អរិយមគ្គក៏សឹងមាន　សម្រេចនិព្វានស្ថានក្សេមសុខ
ប្រាសចាកអំពីសេចក្តីទុក្ខ　ប្រយោជន៍ទៅមុខព្រោះតែសីល ។

ហេតុនេះគួរអ្នកពិសង្កាត ចិត្តកុំប្រមាទដូចជាទ្មិល
ខំរៀនសព្វថ្ងៃកុំគិតខ្ជិល នឹងបានរំកិលជឿនជាតិទៅ ។
តាំងចិត្តធ្វើឲ្យបរិសុទ្ធ ឲ្យទៀងហ្មត់ចត់ត្រង់ត្រឹមត្រូវ
ប្រព្រឹត្តដើរតាមគន្លងផ្លូវ អរិយមគ្គក្លូវនឹងបានខ្លះ ។
អ្នកឯងកុំនឹកថាខ្លួននៅ ក្មេងទេតិចឡើមិនទាន់ចាស់
ឈប់ចាំបង្អង់ឲ្យចំរកាស់ សន្សឹមគិតប្រាសរករៀនធម៌ ។
កុំគិតក្នុងចិត្តស្រវឹងថា ខ្លួនអ្នកឯងណាទៅរួចល្អ
ក្មេងក្អាងក្នុងចិត្តគិតស្មោះសរ ស្អាតអរនឹងរូបតិតរោគចាប់ ។
ហើយអ្នកកុំអាលគិតថាខ្លួន ចំណាប់មាំមួនមិនទាន់ស្លាប់
បន្តិចទៀតសិនសឹមរៀនច្បាប់ ធ្វើតាមសណ្ដាប់គ្រូអាចារ្យ ។
គិតគំនិតនោះខុសមិនស្អាត ចាត់ជាប្រមាទក្នុងសង្សារ
តាំងពីយ៉ាងនឹងមិនគួរថា កុំអ្នកបរបាចាត់ចោលចេញ ។
ផ្លូវស្លាប់សព្វថ្ងៃទៅហួរហែ មិនគិតកាញ់គ្មេរៀនទន្ទេញ
បង្ការប្រយ័ត្នខ្លួននោះមិញ ទៅវិញពន្លឺផ្លូវឲ្យយល់ ។
ព្រលឹងថយចេញអស់វិញ្ញាណ រូបប្រាណបង្គ្រាំងដូចឧសគល់
កំពុងនៅពាលគ្មានគិតយល់ ធ្លាក់ដល់ផរាមរណាក្ស័យ ។

ទើបបានគិតឃើញភ័យរកផ្លូវ　　រកម៉ែរកឪព្រះគុណថ្លៃ
គ្មានធម៌ស្មូត្រអុជធូបសព្វថ្ងៃ　ទៀបក្ស័យដឹងខ្លួនជាតុកឡុង ។
លុះដល់រោគមកបៀតបៀនកាយ　　ឈឺចុកសៀតសាយផាប់ដល់បុង
អាហារបាយទឹកទោះជ្រិកហុង　ដាក់បុះក្នុងមាត់លេបមិនបាន ។
ដឹងខ្លួនជាក់ច្បាស់ជានឹងក្ស័យ　ភិតភ័យពេកក្រៃពន់ប្រមាណ
ប្រមើលមើលរូបរាងខ្លួនប្រាណ　រីងដារីខានចិត្តជាទុក្ខ ។
ស្តាយកូនស្តាយចៅស្តាយប្រពន្ធ　ស្តាយអស់ទ្រព្យធនវែងវិតក្ក
ទ្រង់ត្រួតស្ងួតស្ងប់សញ្ជប់មុខ　រោគរឹងរឹតទុកកាន់តែខ្លាំង ។
លុះដល់ទៀបហៀបជិតនឹងក្ស័យ, ភិតភ័យពេកក្រៃស្លន់ស្លុតស្លាំង
ស្មារតីភ្លេចភ្លើដល់កំឡាំង　ទើបរករៀបក្រាំងសូត្រការវិតា ។
ប្រាថ្នាបង់ឡូលដោះកម្ម　　តែគ្មានបានហាំបទត្រង់ណា
វល់តែនឹងឈឺខ្លោចផ្សា　　ក្នុងអង្គកាយាពន់ប្រមាណ ។
ធម៌រៀនបេះហើយគ្មានរក្សា　ដល់ភ័យប្រវ៉ារកធម៌គ្មាន
មិនរក្សាទុកបម្រុងប្រាណ　មិនបេះរាប់អានបោលបង់បោះ ។
ប្រៀបដូចបងប្អូនស្រឡាញ់គ្នា　យូរទៅឃ្លាតឃ្លាមិនរាប់សោះ
មិនដែលហៅរកបំបេញឈ្មោះ　ពីព្រោះចិត្តលោភជ្រុលច្រេះឯង ។

ដល់ភ័យហៅរកបងប្អូនជួយ ប្អូនបែរមុខក្រោយមិនគិតក្រែង
កាលណាគេនឹងស្រណោះឯង ក្រែងតែមានព្រេងបុណ្យវាស្នា ។
អំពីអតីតសាងមកច្រើន ជួយថែក្រវើនទោះមិនថា
គ្មានគិតសន្សំមគ្គផលា បង្ការប្រយ័ត្នដល់ខ្លួនស្លាប់ ។
អ្នកស្លាប់ទៅមុននោះច្រើនណាស់ មិនដែលប្រទះវិលមកប្រាប់
ដំណើរដែលទៅឲ្យយើងស្តាប់ សារសព្វឲ្យដឹងបែបយ៉ាងណា ។
តែស្លាប់ទៅបាត់ជ្រងំឈឹង មិនដែលវិលវឹងមកប្រាប់ថា
ទៅបានសុខទុក្ខយ៉ាងម្តេចម្តា ឲ្យយើងរាល់គ្នាបានដឹងផង ។
ក្រែងខ្ញុំលើកលោះខុសសេចក្តី មិនគួរគប្បីបែបទំនង
ខុសពាក្យកុបតិនមិនប៉ុនឃ្លោង ខុសបែបគន្លងផ្លូវធម៌អាថ៌ ។
ដ្បិតទើបនឹងរៀបរៀនលើកម្តង សេចក្តីច្រើនផ្គងគ្រប់ប្រការ
លោកណាបេះអាថ៌សូមមេត្តា ដម្រង់ភាសាឲ្យទានផង ។
ឥឡូវបញ្ឈប់ចប់សេចក្តី ល្មមគួរគប្បីស្តាប់ហើយហោង
អស់ទាំងសន្តានគួរហ៊ាចង សូបេម្ល៉េះផងចប់ឯវី ។๛

នេះច្បាប់ក្រិត្យក្រម ។

# រឿងធនញ្ជ័យមង្គល

(៦)

ហើយស្តេចមានព្រះបន្ទូលថា អាជែងឯងនេះធ្វើឲ្យក្តៅទឹកដីអញណាស់នឹងទុកនៅមិនបាន ទើបស្តេចមានព្រះបន្ទូលហៅនាយពេជ្ឈឃាតឲ្យយកធនញ្ជ័យទៅសម្លាប់ ឯក្នុងទន្លេជាបម្រាមឯក្នុង ឲ្យអស់រាស្ត្រវាឃើញកុំឲ្យវាខឹងវា ។ ឯអស់ពេជ្ឈឃាតស្តាប់ព្រះបន្ទូល ហើយក៏ចាប់ធនញ្ជ័យចងហើយនាំទៅសម្លាប់ដូចព្រះបន្ទូលបង្គាប់នោះហោង ឯអស់ពេជ្ឈឃាតនាំធនញ្ជ័យទៅដល់ទូកហើយ ឲ្យយកទូក១មកយកគ្នាដាក់អង្គុយអុំគ្រប់បំណុះទូកពេញហើយ ដាក់ធនញ្ជ័យត្រង់កណ្តាលហើយតាំងហោបីដឹងហើយចេញទូកទៅ ឯធនញ្ជ័យគិតក្នុងចិត្តថាអញនឹងបញ្ឆោតឲ្យអស់ទាំងពេជ្ឈឃាតកុំឲ្យសម្លាប់អញបាន គិតរួចហើយនិយាយថា អស់បងប្អូន ឥឡូវនេះអញនឹងស្លាប់ហើយអញនឹងលេងអស់បងប្អូនឲ្យអស់កុំខ្លាច . ថាបើរត់តើនឹងទៅឯណា នៅក្នុងទឹកនោះឯង ឯអស់ពេជ្ឈឃាតស្តាប់ពាក្យធនញ្ជ័យហើយគិតថា បើនឹងមានបើនឹងរត់តើដូចម្តេចក៏នឹងរួចក្នុងតែអញនឹងចាប់បាន គិតដូច្នោះហើយក៏ស្រាយធនញ្ជ័យចេញ ឯធនញ្ជ័យក៏ថាឲ្យខ្ញុំទៅក្បែរទូកហើយខ្ញុំនឹងលេងប្រៀងបន្ទរលេង

ឲ្យសប្បាយ ឯអស់ពេជ្ឈឃាតក៏ព្រមឲ្យធនញ្ជ័យទៅអង្គុយឯកឡៃប្រៀងបន្ទរថា បើអញថាធនញ្ជ័យធ្លាក់ទឹក ឯងថាហៃអើៗ ឯអស់អ្នកអ៊ុំទូកក៏ព្រមថាហៃអើ ៗ លុះថាតែដូច្នោះរឿយ ៗ ទៅហើយ វាពុំបានជាគិតថាជាធនញ្ជ័យនឹងលោតទឹកតែដូច្នោះ គិតតែសប្បាយក៏ថាទៅ ដឹងជាដូច្នោះក៏ទេ ។ ឯធនញ្ជ័យថាឲ្យស្រែកឲ្យខ្លាំងជាងពីដើមទៀត លុះធនញ្ជ័យល្មមតែនឹងលោតទឹកហើយ ក៏លោតទៅក្នុងទឹកប្រឹង ៗ

ឯអ្នកកឡៃស្រែកថា ធនញ្ជ័យធ្លាក់ទឹកទៅហើយ អ្នកក្បាលហៅហៃអើ ៗ ដូចអំពីដើមនោះឯង ឯធនញ្ជ័យក៏ប្រឹងហែលទៅដល់ត្រើយហើយដើររកស្បង់ចីពរបានហើយចូលទៅបួសនឹងព្រះសង្ឃរាជហើយនៅក្នុងកុដិលោកនោះជាសុខសប្បាយដូចសព្វ១ដងរៀងមក ឯអស់អ្នកអ៊ុំទូកនោះលុះបន្តិចដឹងថា ធនញ្ជ័យបញ្ឆោតលោតទឹកទៅហើយក៏បន្ទោសគ្នាថា អញមិនដឹងទេសេចក្តីនេះតាមតែលោកនាយបុះខុសត្រូវយើងមិនបានស្រាយធនញ្ជ័យទេ ដដែកគ្នាហើយវិលមកវិញហើយឡើងទៅក្រាបទូលថា សូមទានក្រាបទូលដ្បិតទ្រង់បង្គាប់ឲ្យនាំ

ធនញ្ជ័យទៅសម្លាប់នោះធនញ្ជ័យក៏ខឹងចិត្តលោតទឹកទាំងបំណង លិចបាត់ទៅរកមើលមិនឃើញអណ្តែតឡើងឡើយ ឯព្រះមហាក្សត្រស្តាប់ហើយមានព្រះបន្ទូលថាវាហើយទៅចុះ កុំឲ្យតែវារស់ឡើងវិញ មានព្រះបន្ទូលដូច្នោះហើយ គង់កំសាន្តព្រះទ័យជាសប្បាយឥតមានទុកហឹងឡើយ ។

លុះយូរបន្តិចទៅដឹងឮទៅដល់ស្រុកចិនថា អ្នកស្រុកគោកធ្លកជាស្រុកខ្មែរថាមានអ្នកប្រាជ្ញ ១ ឈ្មោះធនញ្ជ័យ ឥតមានអ្នកប្រាជ្ញឯណានឹងស្មើប្រាជ្ញាចៅធនញ្ជ័យនោះគ្មាន ប៉ុន្តែឥឡូវនេះឲ្យសម្លាប់ បើដូច្នោះ ឃើញថានឹងចាប់យកងាយ ឯស្តេចស្រុកចិនគិតឃើញដូច្នោះហើយ ឲ្យហៅនាហ្មឺនធំតូចមកដល់ហើយស្តេចឲ្យជំនុំស្តេចនឹងចាប់យកនគរខ្មែរ ដ្បិតស្តេចនគរខ្មែរគេសម្លាប់អ្នកប្រាជ្ញទៅហើយ បើដូច្នោះឲ្យនាហ្មឺនជំនុំគិតគ្នា បើឃើញការដូចម្តេច ៗ ឲ្យមកប្រាប់អញ ឯអស់នាហ្មឺនបានស្តាប់ព្រះបន្ទូលហើយមកជំនុំគ្នាថា បើគេសម្លាប់អ្នកប្រាជ្ញនោះវាជាហើយ យើងឲ្យយកអ្នកប្រាជ្ញយើងទៅចោទប្រស្នា បើរកមិនឃើញយើងយកនគរនោះបានងាយ គិត

ឃើញដូច្នោះហើយឡើងទៅក្រាបទូលឲ្យទ្រង់ជ្រាប ឯអស់យើងខ្ញុំគិតទៅឃើញថា ឲ្យអាចារ្យយើងបាន ៤ នាក់ទៅពោធប្រស្នាភ្នាល់យកនគរនេះឃើញជាងាយ ដ្បិតអ្នកប្រាជ្ញស្រុកខ្មែរក៏ស្លាប់ទៅហើយ ស្ដេចស្ដាប់ហើយក៏ព្រមតាមទាហ៊ានទូលនោះ ហើយឲ្យយកអាចារ្យទាំង ៤ មកដល់ហើយទ្រង់ផ្ដាំថាឲ្យទៅពោធប្រស្នានឹងភ្នាល់ស្ដេចស្រុកខ្មែរ បើអ្នកណាចាញ់យកនគរជាបំណុះ ផ្ដាំរួចហើយឲ្យយកសំពៅបាន ៤ ឲ្យ ១ ម្នាក់គ្រប់អាចារ្យទាំង ៤ ហើយធ្វើព្រះបន្ទូលប្រាប់មកស្ដេចស្រុកខ្មែរឲ្យបានដឹង ឯសេចក្ដីក្នុងសំបុត្រព្រះបន្ទូលថា ព្រះរាជសារមេត្រីអំពីស្ដេចក្រុងចិន ឲ្យមកស្ដេចស្រុកខ្មែរឲ្យបានដឹង ដ្បិតឮដំណឹងដោយរាស្ត្រទៅរកស៊ីស្រុកខ្មែរថា ស្រុកខ្មែរមានអ្នកប្រាជ្ញ ១ ឈ្មោះធនញ្ជ័យជាអ្នកប្រាជ្ញ ឥឡូវនេះយើងប្រើអ្នកប្រាជ្ញស្រុកយើងឲ្យទៅពោធអាថ៌ប្រស្នាភ្នាល់គ្នា បើអ្នកប្រាជ្ញឯណាចាញ់នឹងយកនគរនោះឯង ប្រាប់មកសួរឯគួរពុំគួរតាមចិត្ត សេចក្ដីអស់តែប៉ុណ្ណោះឯង ធ្វើព្រះបន្ទូលហើយដាក់ក្នុងបំពង់ឲ្យទៅអាចារ្យទាំង ៤ ចុះសំពៅបើកមកដល់ស្រុកខ្មែរ

ហើយបតនៅប្រុបកំពង់ហើយឡើងយកសំបុត្រទៅថ្វាយស្ដេច ក្រុងទគរគោកធ្លក ហើយវិលមកសំពៅវិញ ឯមហាក្សត្រ ឃើញសំបុត្ររាជសាស្ន៍ឲ្យបើកមើលឃើញក្នុងសេចក្ដីសព្វគ្រប់ ដូចយើងបានស្រដីអំពីមុនហើយ ឯព្រះមហាក្សត្រទ្រង់ជ្រាប គ្រប់ប្រការហើយ គិតស្ដាយធនញ្ជ័យថា បើអញមិនឲ្យសម្លាប់ វាយល់ជាមិនពិបាកចិត្តទេ ។

នេះយើងនឹងស្រដីអំពីកាលធនញ្ជ័យទៅបួសយូរបានមួយ ខែ ឯលោកសង្ឃឈ្មោះផែនោះគិតថា អញនឹងទៅយកបង្ហាន់ បិណ្ឌបាតក្នុងព្រះរាជវាំង ឲ្យជួបនឹងស្ដេចបង់ដឹង បើឃើញ អញតើស្គាល់ឬទេ លោកសង្ឃផែគិតដូច្នោះហើយក៏ឃ្លុំចីពរ ស្រែចហើយយកបាត្រមកស្ពាយដើរចូលទៅក្នុងព្រះរាជវាំង ជា មួយនឹងលោកសង្ឃដ៏ច្រើន ឯលោកសង្ឃផែនោះដើរក្រោយ គេបង្អស់ ឯព្រះមហាក្សត្រចេញមកដាក់បាត្រលោកសង្ឃដូច សព្វដងគ្រប់អស់លោក នៅតែលោកតាផែក្រោយគេបង្អស់ ស្ដេចទតទៅឃើញ ស្ដេចមានព្រះបន្ទូលថា អញមើលមុខ

លោកនេះដូចជាមុខលោកដៃ ឯលោកសង្ឃថា ដៃហើយថាមិនអាដៃ ហើយដើរភ្លេសទៅ ឯព្រះមហាក្សត្រក៏ស្ងៀមនៅ ។

លុះដល់សាស្ន៍មកពីស្រុកចិនឲ្យដោះប្រស្នានោះស្តេចគិតថា កាលអំពីមុនអញឃើញលោកសង្ឃមកយកបាត្រប្រហែលអាដៃ ក្រែងវាមិនស្លាប់ទេហើយវាទៅបួស បើដូច្នោះអញឲ្យអមាត្យដើររកដោយវត្តលោកសង្ឃក្រែងទៅបួសមែន ហើយស្តេចបង្គាប់អមាត្យ ៤ នាក់ថាអស់អាឯងទៅរកអាដៃក្រែងវារត់ទៅបួស ឯអមាត្យស្តាប់ហើយក៏ក្រាបថ្វាយបង្គំលាដើរទៅរកធនញ្ជ័យនៅវត្តលោកសង្ឃ ទៅឃើញនៅវត្តហើយបួសជាសង្ឃ ហើយអមាត្យទូលព្រះពុទ្ធដីកាថា ដ្បិតមានព្រះបន្ទូលពិសេសឲ្យនិមន្តលោកទៅ ឯលោកតាដៃស្តាប់ហើយក៏និមន្តទៅតាមអមាត្យ លុះទៅដល់ហើយក៏គង់ស្ងៀម ឯព្រះមហាក្សត្រទតទៅឃើញធនញ្ជ័យដល់ហើយក៏ត្រេកអរ ហើយសួរថា លោកតាដៃអស់ចិត្តនឹងឆាន់ករុណាឬដូចម្តេច ឯលោកតាដៃថ្វាយព្រះពរថាទេ ទើបស្តេចមានព្រះបន្ទូលថា ដ្បិតមានអាចារ្យពីស្រុកចិន គេឲ្យមកដោះឲ្យប្រស្នាភ្នាល់យកនគរ បើដូច្នេះតើជាពេក

ដោះរួចឬទេ ឯលោកតាជៃថាដោះថ្វាយកុំព្រួយព្រះរាជហឫទ័យ ស្តេចស្តាប់ហើយក៏ត្រេកអរក្នុងព្រះទ័យ ហើយមានព្រះបន្ទូលនឹងលោកតាជៃថា បើដូច្នោះ មានតែសឹកចេញទើបជា ទើបលោកសង្ឃឈ្មោះជៃថ្វាយព្រះពរថា អាត្មាភាពសឹកថ្ងៃនេះឯង កុំព្រួយព្រះរាជហឫទ័យឡើយ ហើយស្តេចឲ្យសំពត់អាវក្រម៉ាក្រវ៉ាត់ ហើយលោកតាជៃទទួលយកសំពត់អំពីព្រះមហាក្សត្រ ហើយលាវិលទៅសឹកចេញ ស្លៀកសំពត់ពាក់អាវក្រវ៉ាត់ក្រម៉ាហើយក៏ចូលទៅថ្វាយបង្គំគាល់ ស្តេចទតឃើញហើយស្តេចមានព្រះបន្ទូលថាបណ្ឌិតជៃគេមកហើយ មើលទៅល្អសមជាបណ្ឌិតអ្នកប្រាជ្ញ បានជាឈ្មោះថាបើអ្នកឯណាបួសហើយសឹកចេញហៅថាបណ្ឌិត ៗ ដូច្នេះឯង រួចហើយស្តេចដណ្តឹងថា ឥឡូវនេះនឹងឲ្យអាចារ្យចិនគេឡើងមកចោទប្រស្នាថ្ងៃណា ទើបបណ្ឌិតជៃក្រាបទូលថា ក្នុងបីថ្ងៃទៀតឲ្យឡើងមកនឹងចោទប្រស្នាគ្នា ហើយបណ្ឌិតជៃឲ្យគេរកគម្ពីរឲ្យច្រើន ហើយឲ្យរកមហាឡឹកបាន ៤ នាក់ ឲ្យយកខ្មៅដុះឲ្យច្រើនដាក់នឹងថាសនោះ ៤ ហើយឲ្យយកក្តារធំរលីង ៤ ជ្រុងមកឲ្យហើយ

ចាប់ក្តាមឲ្យច្រើនបាន ៤ ក្អមហើយឲ្យរកក្រដាសសព្តុធំឲ្យច្រើនមកឲ្យទូលព្រះបង្គន់នឹងធ្វើប្រស្នាថ្វាយ កុំព្រួយព្រះរាជហឫទ័យ ឯព្រះមហាក្សត្រស្តាប់ហើយឲ្យរកតាមពាក្យធនញ្ជ័យ បង្គាប់នោះ បានមកហើយឲ្យយកទៅប្រគល់ឲ្យធនញ្ជ័យ រួចហើយឲ្យបំរើទៅប្រាប់អាចារ្យស្រុកចិនដែលមកចតសំពៅនៅកំពង់នៅមុខព្រះលាន មានព្រះបន្ទូលឲ្យមកប្រាប់ថា បីថ្ងៃទៀតឡើងទៅចោទប្រស្នានឹងអ្នកប្រាជ្ញយើងស្រុកខ្មែរចុះកុំខានឡើយ ឯអាចារ្យស្រុកចិនស្តាប់ហើយទទួលតាម លុះដល់ថ្ងៃត្រូវសន្មតហើយអាចារ្យចិនឡើងទៅចោទប្រស្នា ឯធនញ្ជ័យក៏ដើរចុះទៅទទួលគ្នាពាក់កណ្តាលផ្លូវ មុខព្រះលានស្តេចនោះឯង ឯអាចារ្យចិនមើលទៅឃើញធនញ្ជ័យដើរមកអំពីចម្ងាយហើយធ្វើជាប្រស្នាចង្អុលទៅលើមេឃ ឯធនញ្ជ័យចង្អុលទៅព្រះអាទិត្យ អ្នកប្រាជ្ញចិនចង្អុលទៅក្រោមដី ធនញ្ជ័យលាបាទដៃហើយម្រាមដៃបញ្ឈរឡើងទៅ ឯអ្នកប្រាជ្ញចិនចង្អុលចុះទៅក្រោម ធនញ្ជ័យចង្អុលមកខ្លួនឯង ។

ឯអ្នកប្រាជ្ញស្រុកចិនសួរថា កាលយើងបង្ហុលទៅលើមេឃ ហើយអ្នកឯងបង្ហុលទៅព្រះអាទិត្យនោះ តើអ្នកឯងដឹងដូចម្ដេច ទើបធនញ្ជ័យថាយើងដឹង អ្នកឯងបង្ហុលទៅលើមេឃនោះ អ្នកសួរថាមានសត្វអ្វី ឯបង្ហុលទៅព្រះអាទិត្យនោះតើជាអ្នកដឹងឬទេ ឯអ្នកប្រាជ្ញចិនថាអញដឹង អ្នកឯងថាមេឃនោះមានតែព្រះអាទិត្យព្រះចន្ទនោះឯងនៅលើមេឃ ទើបអ្នកប្រាជ្ញស្រុកចិនថា ដែលអញបង្ហុលទៅខាងក្រៅដីនោះ តើឯងថាដូចម្ដេច ទើបធនញ្ជ័យឆ្លើយថាអញដឹងហើយ ឯបង្ហុលទៅខាងក្រៅនោះថាសត្វអ្វី ទើបធនញ្ជ័យថាអញធ្វើម្រាមដៃឡើងទៅលើជុំវិញនោះ តើឯងថាសត្វអ្វី ទើបអាចារ្យចិនថាអញដឹង បានជាឯងធ្វើដូច្នោះនោះ ថាក្រៅផែនដីមានទឹកសមុទ្រ ក្រៅសមុទ្រនោះមានភ្នំចក្រវាឡក្រៅនោះឯង ទើបអាចារ្យចិនថាអញបង្ហុលចុះក្រោមនោះតើឯងដឹងឬទេ ទើបធនញ្ជ័យថាអញដឹង ឯងបង្ហុលចុះក្រោមនោះថានៅលើដីនេះតើមានសត្វអ្វី ធនញ្ជ័យថាអញបង្ហុលមកខ្លួនអញនោះ តើដឹងឬទេ ឯអាចារ្យចិនថាអញដឹង ឯង

បង្អុលខ្លួនឯងនោះថានៅដីនេះមានតែមនុស្ស ឆ្លើយទទួលគ្នា ។ រួចហើយអាចារ្យបិនលាធនញ្ជ័យវិលទៅសំពៅវិញ ។

លុះដល់ព្រឹកឡើងមកជួបនឹងធនញ្ជ័យ ឯអាចារ្យបិនធ្វើប្រស្នាឲ្យធនញ្ជ័យ ចាប់ដៃធ្វើជារង្វង់ ឯធនញ្ជ័យធ្វើបត់ជុំដៃបង្ហាញទៅ អាចារ្យបិនលាម្រាមដៃទាំង៥បង្ហាញមកធនញ្ជ័យ ធនញ្ជ័យបង្ហាញម្រាមដៃ១បង្ហាញទៅអាចារ្យបិន ឯអាចារ្យបិនឃើញហើយវិលទៅសំពៅវិញ ឯធនញ្ជ័យវិលទៅផ្ទះវិញ ។

ឯលោកគ្រូសម្តេចព្រះសង្ឃរាជបានឮថាធនញ្ជ័យដោះប្រស្នានឹងអាចារ្យបិនដូច្នោះហើយ ក៏និមន្តមកសួរចង់ដឹងដំណើរនោះ ជួបនឹងធនញ្ជ័យហើយពណ្ណាំងថា កាលអ្នកដោះប្រស្នានឹងបិនធ្វើដូចម្តេច ទើបធនញ្ជ័យទូលថា បិនធ្វើដៃជារង្វង់ ខ្ញុំបង្ហាញជុំដៃ បិនលាដៃបង្ហាញម្រាមទាំង ៥ ខ្ញុំក្តាប់ដៃបង្ហាញបង្អុលម្រាមដៃ ១ ។

ទើបលោកគ្រូសង្ឃរាជពណ្ណាំងថាបើដូច្នោះតើដូចម្តេច ទើបធនញ្ជ័យថា ឯបិនធ្វើដៃជារង្វង់ដូច្នោះ ខ្ញុំថាធ្វើអង្រិតគេរុតត្រី ទើបខ្ញុំបង្ហាញកែងដៃនោះ ថាបើអង្រិតរុតត្រីដូច្នោះ រុតត្រីបាន

ប៉ុនជុំដៃ ឯបង្ហាញម្រាមដៃ ៥ នោះ ថាបើបានត្រីប៉ុណ្ណោះល្មមធ្វើផៀតបាន ៥ បំពៀក ឯខ្ញុំបង្ហាញបង្គុលដៃ ១ ថាស៊ី ១ ថ្ងៃ ១ បំពៀក ក្នុងត្រី ១ កន្ទុយ បាន ៥ ថ្ងៃទើបអស់ ។ ឯលោកសង្ឃរាជបានដឹងហើយវិលទៅកុដិវិញ ។

ទើបឯលោកសម្ដេចចៅហ្វាទៅសួរធនញ្ជ័យ បង់ដឹងអំពីប្រស្នាបិននោះ ថាដូចម្ដេចប្រាប់អញផងអញបង់ដឹង ធនញ្ជ័យស្ដាប់ហើយជំរាបថា បិនធ្វើដៃជារង្វង់ ខ្ញុំបង្ហាញកែងដៃ បិនបង្ហាញម្រាមដៃ ៥ ខ្ញុំបង្ហាញបង្គុលដៃ ១ ទើបលោកសម្ដេចចៅហ្វាជណ្ដឹងថា បើដូច្នោះ ថាដូចម្ដេច ទើបធនញ្ជ័យប្រាប់ថា បិនឱបដៃជារង្វង់នោះថានឹងចាប់នគរ ។

(មានត)

# រឿងគង់ហ៊ាន

## រឿងគង់ហ៊ា ៦

អំពីនេះនឹងនិយាយពាក្យព្រេងដែលចាស់ទុំនិយាយត ៗ មកថា កាលនោះ មានមនុស្សម្នាក់ឈ្មោះគង់មានប្រពន្ធពីរ ប្រពន្ធ ១ ឈ្មោះនាងអាំ ១ ឈ្មោះនាងគំ ប្អូនមួយថ្ងៃអ្នកគង់នាំប្រពន្ធទាំងពីរទៅសួរបងប្អូននៅស្រុកឆ្ងាយ តាមផ្លូវទៅស្រុកនោះឯងមានខ្លាសាហាវ អ្នកគង់បណ្តើរប្រពន្ធទាំងពីរទៅដល់ក្នុងព្រៃធំ ១ ជិតស្រុកគេហើយ តែងមានខ្លាដេញខាំមនុស្សក្របីគោស៊ីតែរឿយ ៗ លុះអ្នកគង់ទៅដល់កន្លែងនោះហើយខ្លាលោតស្ទុះទៅដេញ ស្រែកសន្ធាប់ពីចម្ងាយមក អ្នកគង់ភ័យរត់ចូលរូងឈើហើយរាកទាំងនោម ព្រោះភ័យខ្លាចណាស់ញ័រទាំងដៃទាំងជើង ឯនាងអាំនាងគំខំជួយគ្នាក៏វាយខ្លានោះស្លាប់ទៅ ។

ឯអ្នកគង់ឃើញប្រពន្ធវាយខ្លាស្លាប់ហើយ ស្ទុះចេញពីរូងម្នីម្នាមកយកដំបង វាយខ្លាស្លាប់ស្រាប់នោះថែមទៀត ឯប្រពន្ធទាំងពីរបន្ទោសប្ដីថា ខ្លាគេវាយស្លាប់ហើយធ្វើជាមកវាយថែមទៀត ប្រុសតិកំសាកញីជួ្នះ ឯអ្នកគង់ដេរបំពាន

ទៅប្រពន្ធថា មិនដែលមានស្រីឯណាវាយខ្លាស្លាប់ មានតែប្រុសបានហ៊ានវាយខ្លាស្លាប់ ។

អ្នកគង់បោចវល្លិចងខ្លាសែងនឹងប្រពន្ធចូលទៅក្នុងស្រុក អស់អ្នកស្រុកគេឃើញអ្នកគង់សែងខ្លាមក, គេបបួលគ្នាមកមើលពាសពេញ ហើយគេសួរថា អ្នកឯងធ្វើដូចម្ដេចបានជាបានខ្លានេះ ដ្បិតខ្លានេះសាហាវណាស់វាតែងតែខាំមនុស្សម្នាក្របីគោស៊ីច្រើនណាស់ហើយ. ប្រពន្ធអ្នកគង់ក៏និយាយប្រាប់អ្នកស្រុកថា អ្នកគង់គាត់ឃើញខ្លាវាដេញមក គាត់រត់ចូលក្នុងរូងឈើ ខ្ញុំពីរនាក់ស្រី ៗ ជួយគ្នាវាយខ្លាស្លាប់ អ្នកគង់ឮប្រពន្ធនិយាយប្រាប់គេដូច្នោះហើយ បញ្ចោររំលោភទៅលើប្រពន្ធថា មិនដែលមានស្រីណាខ្លាំងពូកែហ៊ានវាយខ្លាស្លាប់ទេ មានតែប្រុសទើបខ្លាំងពូកែ ហ៊ានវាយខ្លាស្លាប់ ឯអ្នកគង់អួតប្រាប់អ្នកស្រុកថា ខ្លាវាស្ទុះមកនឹងខាំដូច្នេះ ខ្ញុំដាក់ស្នៀតគុនដូច្នោះបានជាវាយខ្លាបាន ឯអ្នកគង់ធ្វើជាលោតគុនវាយខ្លាឲ្យអ្នកស្រុកមើល ឯអស់អ្នកស្រុកកោតខ្លាចអ្នកគង់តែរាល់គ្នា ហើយសន្មតឲ្យឈ្មោះហៅថា អ្នកគង់ហ៊ាន

ពីថ្ងៃនោះមក ឮល្បីឈ្មោះអ្នកគង់ហ៊ានជាអ្នកពូកែបេះគុនវាយខ្លាស្លាប់ ជ្រាបទៅដល់ស្ដេចៗ ឲ្យយកទៅធ្វើជាសេនាបតីញ៉ាំមទុកនឹងច្បាំងសឹកសង្គ្រាម ។

លុះនៅយូរទៅបួនមានសឹកគេលើកមកច្បាំងយកនគរ ស្ដេចត្រាស់ប្រើអ្នកគង់ឲ្យច្បាំងសឹក ឯអ្នកគង់ហ៊ានឮស្ដេចត្រាស់ប្រើឲ្យទៅច្បាំងសឹកដូច្នោះភ័យណាស់ ពុំដឹងបើគិតធ្វើដូចម្ដេចនឹងមិនទៅច្បាំងមិនបាន ដ្បិតស្ដេចត្រាស់ប្រើហើយ បានជាល្បីឈ្មោះជាអ្នកខ្លាំងពូកែផង ដល់ត្រឡប់មកវិញដេកសន្ធឹកសង្វែរអត់ទាំងបាយ ប្រពន្ធទាំងពីរបួលទៅសួរថាប្ដីបានជាអ្នកដេកអត់ទាំងបាយដូច្នេះ មានបើហេតុភេទអ្វីប្រការដូចម្ដេច ។

អ្នកគង់ហ៊ានប្រាប់ថាដ្បិតស្ដេចត្រាស់ប្រើបងឲ្យទៅច្បាំងសឹក តទ្បូវនេះបងភ័យខ្លាចសឹកនោះណាស់ មិនដឹងបើគិតធ្វើដូចម្ដេច ។

ប្រពន្ធឆ្លើយឡើងថា អ្នកកុំព្រួយបិត្តជានានៅខ្ញុំទាំងអស់អ្នកក្រោកឡើងពិសាបាយឲ្យឆ្អែត ងូតទឹកឲ្យសប្បាយខ្លួន ឯគង់ហ៊ានឮប្រពន្ធលួងលោមដូច្នោះហើយ គ្រាន់ធូរក្នុងចិត្ត

ក្រោកឡើងងូតទឹកស៊ីបាយ រៀបគ្រឿងប្រដាប់នឹងទៅច្បាំងសឹក ។

លុះរៀបរួចហើយដល់ថ្ងៃពេលល្អ ក៏ចូលទៅក្រាបថ្វាយបង្គំលាស្តេចចេញទៅច្បាំង យកទាំងប្រពន្ធទៅផង គង់ហ៊ានជិះខាងក្បាលដំរី ប្រពន្ធជិះខាងក្រោយ មានពលហែហមទាំងមុខទាំងក្រោយជាក្បួនទ័ពរាសពេញត្រៀបត្រា លុះទៅជិតខ្មាំងសត្រូវមើលឃើញច្បាស់ប្រាកដ គង់ហ៊ានភ័យណាស់ លេបទាំងអាចម៍ញ័រទាំងដៃទាំងជើង ដួបគេអង្រួនក្បាលដំរី ឯដំរីគិតស្មានថាជាគេអង្រួនឲ្យបោលចូល ក៏បេះតែបោលចូលហួសពលរេហ៍ទាំងអស់ គ្មាននរណាតាមទាន់ ។

ឯខ្មាំងសត្រូវឃើញគង់ហ៊ានបរដំរីបោលចូលដូច្នោះ គិតស្មានថាមេទ័ពនេះពូកែណាស់ បាក់ទ័ពបាញ់រត់យកព្រះអាយុដោយខ្លួនទៅ ។

ឯគង់ហ៊ានឃើញខ្មាំងរត់ទៅអស់ហើយ ធ្វើជាអួតក្អេងក្អាងឲ្យអស់នាហ្មឺននៅពលរេហ៍កោតខ្លាច អស់នាហ្មឺនឃើញគង់ហ៊ានលេបលាមកដាក់ក្បាលដំរីស្អុយរាសពេញដូច្នោះ គេសួរ

ថាលោកមេទ័ពថ្មីក៏លេចលាមកដូច្នោះ គង់ហ៊ានឆ្លើយឡើងថា បើកំពុងតែច្បាំងនឹងសត្រូវ ហើយឈឺផ្ទៃនឹងចុះទៅដោះទុក សត្វឯណាបាន មានតែដោះទុកសត្វលើក្បាលដំរីដូច្នេះឯង បើចុះទៅខ្មាំងវាកាប់ស្លាប់ឥតអំពើទៅ ។

អស់នាហ្មឺននៅពលរេហ៍ឮគង់ហ៊ាននិយាយដូច្នោះ អ្នកខ្លះគេមានប្រាជ្ញាគេដឹងថាគង់ហ៊ានខ្លាច អ្នកខ្លះមិនសូវមានប្រាជ្ញាកោតខ្លាចគង់ហ៊ានណាស់ ឯគង់ហ៊ានបានឈ្នះទ័ព ហើយត្រឡប់ចូលមកនគរវិញ ហើយចូលទៅក្រាបថ្វាយបង្គំស្ដេច ។

ឯស្ដេចឃើញគង់ហ៊ានទៅច្បាំងឈ្នះសឹក ហើយខ្មាំងរត់ខ្ចាត់ខ្ចាយអស់ទៅ មានព្រះទ័យត្រេកអរណាស់ ទ្រង់ព្រះរាជ-ទានយសសក្តិជានាហ្មឺនធំ ហើយព្រះរាជទានរបស់ទ្រព្យនូវគ្រឿងយសសក្តិជាច្រើន ឯគង់ហ៊ានអំពីថ្ងៃនោះមកបេះតែអួតខ្លាំងពូកែក្អេងក្អាងឡើងទៀត ។

លុះឯក្រោយទៀតចួនមានសត្វក្រពើសាហាវបេះតែដេញខាំអស់មនុស្សម្នាអ្នកឈ្នួញជួញលលក់ដើររកស៊ី ខាងជើងទឹក

ជើងកំពង់ ខ្លាចរអាមិនមានអ្នកឯណា ហ៊ានចុះងូតទឹក ដើរទូកសោះ អស់រាស្ត្រពិបាកចិត្តណាស់ រឿងនោះក៏ជ្រាបទៅដល់ស្តេច ៗ ទ្រង់ត្រាស់ប្រើគង់ហ៊ាន ឲ្យទៅចាប់ក្រពើ ឯគង់ហ៊ានឮព្រះបន្ទូលដូច្នោះ នឹកគិតភ័យណាស់ ប៉ុន្តែមិនហ៊ានទាស់ទទឹងព្រះបន្ទូលបានឹងយកអាសា កុំឲ្យព្រួយព្រះរាជហឫទ័យ ឯគង់ហ៊ានលុះត្រឡប់មកដល់ផ្ទះហើយនិយាយនឹងប្រពន្ធថា គេអើយឥឡូវនេះស្តេចត្រាស់ប្រើឲ្យទៅចាប់ក្រពើក្នុងទន្លេ ដ្បិតក្រពើសាហាវណាស់ ម្តងនេះឃើញជាមិនរួចខ្លួនហើយ មុខជាក្រពើខាំស្លាប់ម្តងនេះមិនខានទេ ឯពីមុនដ្បិតនៅលើគោកគ្រាន់នឹងមើលទៅឃើញ ឥឡូវនេះនៅក្នុងទឹកធ្វើដូចម្តេចនឹងមើលឃើញ ប៉ុន្តែស្តេចប្រើនឹងមិនទៅក៏មិនបានបើដូច្នោះទៅលោតទឹកឲ្យក្រពើខាំស្លាប់ទៅវិញជា គង់ហ៊ាននិយាយគិតនឹងប្រពន្ធដូច្នោះហើយ ហៅអស់កូនក្មួយហើយធ្វើដំណើរទៅចាប់ក្រពើ លុះដល់ទៅកំពង់ទឹកហើយឃើញក្រពើហែលនៅប្រែបកំពង់ អស់មនុស្សម្នាឮថាគង់ហ៊ានទៅចាប់ក្រពើ ក៏បបួលគ្នាទៅមើលពាសពេញ គង់ឃើញក្រពើហែល

មកប្រឹបប្រាំង មានដើមឈើពីរដើមដុះជិតគ្នា មានព្រៃគាប មែក គង់ហ៊ានលោតស្ទុះលោតទៅក្នុងទឹក ឯក្នុងចិត្តគិតថា លោតទៅឲ្យក្រពើវាខាំឲ្យស្លាប់ទៅ ។

ឯក្រពើឮសន្ធឹកគង់ហ៊ានរត់លោតទៅ ក៏ភ្ញាក់ប្រឹងលោត ពោលឡើងដូចជាគេប្រហាកក្នុងដើមឈើ ជាប់ពាក់កណ្ដាល ខ្លួនទៅមុខមិនរួចទៅក្រោយមិនរួច ឯគង់ហ៊ានមុជទៅក្នុងទឹក ងើបឡើងឃើញក្រពើជាប់នឹងដើមឈើដូច្នោះ ស្រែកបង្គាប់ ឲ្យកូនក្មួយយកលំពែងចាក់កាប់ក្រពើនោះស្លាប់ទៅ ឯអ្នក ដែលមើលគិតស្មានថាគង់ហ៊ានចាប់ក្រពើពោលមកឲ្យជាប់នឹង ដើមឈើ គិតកោតខ្លាចគង់ហ៊ានទាំងអស់ ។

ឯគង់ហ៊ានបានឃើញក្រពើស្លាប់ដូច្នោះហើយ ក៏រឹតតែក្អេង ក្អាងអួតខ្លាំងពូកែឡើងទៀត ហើយចូលទៅក្រាបទូលស្ដេច ថា ខ្ញុំបានចាប់ក្រពើពោលឡើងមកលើគោកដូច្នោះ ហើយ ស្ដេចក៏ត្រេកអរទ្រង់ប្រោសព្រះរាជទានយសសក្តិឲ្យគង់ហ៊ានជា ធំលើសពីមុនទៀត ព្រះរាជទានទាំងអំណាច រង្វាន់ជាច្រើន ណាស់ទៅទៀត ។ ៚—

# បញ្ជីរឿង

លេខទំព័រ


១ ខេមាខេមសរណកថា សំដែងអំពីលទ្ធិមហាយាន ព្រះមហាពិទូរក្រសេម រៀបរៀង (ត) . . . . . . . . . . . . . . . . . . . . . . ៥៩

២ លោកន័យ ពាក្យកាព្យ (ត) . . . . . . . . . . . . . . . . . . ៧៥

៣ ច្បាប់កូនចៅ របស់ក្រុម ង៉ុយ តែង . . . . . . . . . . . . . . . . ១០៩

៤ រឿងស្តេច ក្រុងចិន . . . . . . . . . . . . . . . . . . . . . . ១២៣


# រូបក្រៅរឿង


១ ព្រះពុទ្ធរូប ១ អង្គ នៅក្នុងចំណោមព្រះពុទ្ធរូបដ៏ជាច្រើន នៅក្នុងវត្តអានន្ទបាយៈ (ភូមា)៧៣

២ ចេតិយបុរាណឈ្មោះ ពុប៉យ នៅឆ្នេរទន្លេឥរាវតី ប្រទេសភូមា . . . . . ១៨៧

# TABLE DES MATIÈRES


I. Khemâ Khema Saranakatha ou Religions, refuge des hommes ........................ 59

II. Lokaneya ........................ 75

III. Conseils aux enfants paroles de Krom Ngoy .......... 109

IV. Conte populaire Cambodgien inédit. Le Roi de Chine... 123


## HORS TEXTE:


I. Une statue du Bouddha parmi tant d'autres à la pagode d'Ananda Paya-Pagan-Birmanie ........................ 73

II. La pyramide Bu Paya au bord de l'Irrawady-Pagan-Birmanie ........................ 107

ខេមាខេមសរណគាថា

ព្រះមហាពិទូរក្រសេម គន្ធរបទបណ្ឌិត

រៀបរៀង (ត)

៤ "ម្យ៉ាងទៀត សារីបុត្រ ក្នុងសុខាវតី ពុទ្ធក្សេត្រនោះ រមែងមានទិព្យតុរិយាង្គតន្ត្រីដ៏បន្លឺនៅសូរសព្ទជានិច្ចនិរន្តរ ផ្ទៃផែនដីក្រាលទៅដោយមាសជាសុវណ្ណប្រឹថពី មានផ្កាមន្ទារវជាសបក់ក្លិនក្រអូបរំភើយក្នុង១ថ្ងៃ៦ដង វេលាព្រឹកព្រហាមអាកាសស្រស់ស្រទន់បរិសុទ្ធ មហាជននាំគ្នាទៅបេះផ្កាឈើវិសេសនេះដាក់ពេញភាជនៈហើយ នាំទៅថ្វាយព្រះពុទ្ធអង្គផ្សេង ៗ គ្រប់ទិស, លុះដល់ពេលបរិភោគអាហារ គេក៏នាំគ្នាត្រឡប់ចូលគេហស្ថាន កាលបរិភោគហើយក៏ចេញទៅធ្វើទិវា-វិហារ គឺដើរលេងក្នុងវេលាថ្ងៃ ម្នាលសារីបុត្រ ខេត្តសុខាវតីរមែងមានគ្រឿងប្រដាប់នឹងគុណវិសេសផ្សេង ៗ ដូច្នេះ ។

៥ "ម្យ៉ាងទៀត សារីបុត្រ ក្នុងសុខាវតីពុទ្ធក្សេត្រនោះមានវិហគជាតិ (សត្វបក្សី) ពណ៌សម្បុរផ្សេង ៗ ជាអស្ចារ្យមានហង្ស មយូរា កោញ្ចា កោកិលា ជាដើម, បក្សីជាតិអំបាលនេះយាសយំរងំសាន់ប្រកាសឥន្ទ្រិយ ៥, ពល ៥ ពោជ្ឈង្គ ៧ មគ្គ ៨, នឹងព្រះធម៌ដទៃៗទៀតក្នុង ១ ថ្ងៃ ៧ ដង, បណ្ដានិករជនដែលនៅក្នុងទីនោះ កាលបានឮបក្សីយំរមែងធ្វើនមស្សការដល់

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សារីបុត្រ អ្នកចូរកុំសំគាល់ថា បក្សីអំបាលនោះ កើតមកហោកទាបដោយអំណាចផលកម្ម ព្រោះហេតុថា ក្នុងសុខាវតីពុទ្ធក្សេត្រ គ្មានការធ្វើទោសផ្តន្ទា ដូចម្តេចឡើយ សូម្បីតែពាក្យថា នរកលោក តិរច្ឆានលោក យមលោក ក៏គ្មានអ្នកណាដែលបានឮ បក្សីទាំងឡាយនេះ ព្រះពុទ្ធអមិតាយុសទ្រង់និម្មិតឡើងដើម្បីនឹងឲ្យប្រកាសព្រះធម៌, ម្នាលសារីបុត្រ ក្នុងពុទ្ធក្សេត្រកាលណាមានខ្យល់រំភើយ បោកបក់មកបណ្តាដើមឈើនឹងសំណាញ់កណ្តឹងមាស ដែល ព័ទ្ធព័ទ្ធជុំវិញ គឺរយាសយោល បន្លឺនៅសំឡេងព្រមគ្នាទាំង សែនកោដិគ្រឿងដំពីរោះប្រដូចជាតូរ្យតន្ត្រី អ្នកណាបានឮសូរ សព្ទដំពីរោះនេះហើយរមែងកើតពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ. ម្នាលសារីបុត្រ ទីពុទ្ធក្សេត្រនោះរមែងមាន គ្រឿងប្រដាប់ នឹងគុណវិសេសផ្សេង ៗ ដូច្នេះ ។.

៦ "ម្នាលសារីបុត្រ អ្នកដែលនឹកឬទេ ថាហេតុម្តេច ព្រះពុទ្ធនោះទើបទ្រង់នាមថា អមិត, ម្នាលសារីបុត្រ រស្មីនៃ ព្រះពុទ្ធនោះរមែងផ្ទះទៅគ្រប់ទិសានុទិសគ្មានទីបំផុត ទើបទ្រង់

ព្រះនាមថា អមិត, ១ ទៀតសារីបុត្រ ព្រះជន្មាយុនៃព្រះពុទ្ធនោះ និងពួកបរិវាររបស់លោកនោះតាំងនៅរហូតកល្បាវសាន គ្មានកំណត់ថាប៉ុណ្ណោះប៉ុណ្ណោះ (គឺអាយុវែងណាស់) ហេតុនោះទើបទ្រង់នាមថា អមិត, ម្នាលសារីបុត្រ ចាប់ដើមតែអំពីព្រះពុទ្ធអមិតាយុសបានបន្លុះព្រះពោធិញ្ញាណមកដល់ឥឡូវនេះកន្លងវេលាមកបាន ១០ កល្បហើយ (មិនបុតិប្រែប្រួលទៅណា), ១ ទៀតសារីបុត្រ ព្រះពុទ្ធអង្គនោះមានសាវកជាអរហន្តមានចំនួនរាប់មិនអស់ ព្រះពោធិសត្វក៏មានច្រើនដូចគ្នាដែរ, ម្នាលសារីបុត្រ ទីពុទ្ធក្សេត្រនេះរមែងមានគ្រឿងប្រដាប់និងគុណវិសេសផ្សេង ៗ ដូច្នេះ" ។

៧ "ខមួយទៀត សារីបុត្រ សត្វទាំងឡាយដែលកើតមកក្នុងខេត្តសុខាវតីនេះជាអវិវត្តិនីយសត្វ ជាសត្វមិនបេះប្រែប្រួលទៅជាធម្មតា (គឺនឹងបានត្រាស់ដឹងក្នុងថ្ងៃឯណានីមួយមិនខាន) សត្វអំបាលនោះដោយច្រើននៅកើតទៀតមួយជាតិប៉ុណ្ណឹង អ្នកដែលយ៉ាងដូច្នេះមានច្រើនណាស់ទាល់តែរាប់មិនអស់ ម្នាលសារីបុត្រ បុថុជ្ជនបុគ្គលឯណាបានឮបានស្តាប់

រឿងដូច្នេះ គួរនឹងប្រាថ្នាកំណើតឲ្យទៅកើតក្នុងខេត្រនេះឲ្យបាន ដើម្បីនឹងបានវិស្សាសៈនឹងអ្នកដ៏មានបុណ្យដូចពោលមកហើយ, ម្នាលសារីបុត្រ បើដោយមូលហេតុ នឹងដោយគុណវិសេស ត្រឹមបន្តិចបន្តួចទេ រមែងមិនសម្រេចកិច្ចដែលឲ្យខ្លួនទៅកើតក្នុងដែននោះបាន" ។

៨ "ម្នាលសារីបុត្រ មនុស្សដែលល្អជាប្រុសឬស្រីក៏តាម កាលបើបានឮរឿងព្រះពុទ្ធអមិតាយុស ចាំព្រះនាមនោះក្នុងចិត្តដោយមិនឲ្យភ្លាំងភ្លេច អស់កាលមួយថ្ងៃ ២ ថ្ងៃរហូតដល់ ៧ ថ្ងៃហើយ កាលអ្នកនោះជិតនឹងដល់នូវកាលមរណៈ គេនឹងបានឃើញព្រះពុទ្ធអមិតាយុស សឹងហោមរោមទៅដោយបរិវារដ៏ទ្រង់សក្តិ លុះដល់មរណៈទៅហើយ នឹងបានទៅកើតក្នុងដែនសុខាវតី ដ៏ជាទីស្ថិតនៅនៃព្រះអមិតាយុសពុទ្ធ ម្នាលសារីបុត្រ កាលតថាគតឃើញផលប្រយោជន៍ដូច្នេះហើយ ទើបពោលថា រាល់ៗគ្នាដែលបានស្តាប់ព្រះធម៌ទេសនានេះហើយ គួរជាសាធ្យាយមន្ត សូមឲ្យទៅកើតក្នុងដែននោះ" ។

៩ "ម្នាលសារីបុត្រ តថាគតបានសំដែងព្រះធម៌ទេសនាសរសើរគុណវិសេស នៃព្រះអមិតាយុសពុទ្ធក្នុងកាលឥឡូវនេះ ដូចម្ដេច នៅមានព្រះពុទ្ធដទៃៗក្នុងបុរិមលោកធាតុ (លោកធាតុខាងកើត) ដូចយ៉ាងព្រះពុទ្ធអក្ខោភ្យ ព្រះពុទ្ធមេរុធ្វជ ព្រះពុទ្ធមហាមេរុ ព្រះពុទ្ធមេរុប្រភាស ព្រះពុទ្ធមញ្ជុឃោសៈ និងព្រះពុទ្ធដទៃ ៗ ទៀតជាអនេក ស្មើនឹងគ្រាប់ខ្សាច់ក្នុងគង្គានទី លោកទាំងអំបាលនេះសុទ្ធតែទ្រង់ផ្សាយព្រះសទ្ធម៌ទៅក្នុងបុរិមលោកធាតុទាំងមូលថា "ពុទ្ធជនទាំងឡាយ ចូរជឿស្ដាប់ព្រះសូត្រនេះដ៏ជាពុទ្ធដម្រាស់ ជាសេចក្ដីដែលព្រះពុទ្ធទាំងឡាយទ្រង់ឃើញប្រពៃ ទាំងទ្រង់ប្រទានអារក្ខាមកហើយ ដ៏មានសេចក្ដីប្រកាសគុណវិសេសរបស់ព្រះអមិតាយុសពុទ្ធដូច្នេះ" ។

១០ "ម្នាលសារីបុត្រ នៅមានព្រះពុទ្ធដទៃៗក្នុងទក្សិណលោកធាតុ (លោកធាតុខាងត្បូង) ដូចយ៉ាងព្រះពុទ្ធចន្ទ្រសូរ្យប្រទីប ព្រះពុទ្ធយសប្រភៈ ព្រះពុទ្ធមហារ្ចិស្កន្ធ ព្រះពុទ្ធមេរុប្រទីប ព្រះពុទ្ធអនន្តវីរ្យ និងព្រះពុទ្ធដទៃ ៗ ទៀតជាអនេក ស្មើចំនួនគ្រាប់ខ្សាច់ក្នុងគង្គានទី លោកទាំងអំបាលនេះសុទ្ធតែ

ទ្រង់ផ្សាយព្រះសទ្ធម៌ទៅក្នុងទក្សិណលោកធាតុទាំងមូលថា បុប្ផជនទាំងឡាយ ចូរជឿស្ដាប់ព្រះសូត្រនេះ ដែលព្រះពុទ្ធទាំងឡាយឃើញគាប់ប្រសើរ និងទ្រង់ប្រទានអារក្ខាហើយ ដ៏មានសេចក្ដីប្រកាសគុណវិសេសរបស់ព្រះអមិតាយុសពុទ្ធទុកស្រាប់ ។

១១ "ម្នាលសារីបុត្រ នៅមានព្រះពុទ្ធដទៃ ៗ ទៀតក្នុងបាច់ិមលោកធាតុ (លោកធាតុខាងលិច) ដូចយ៉ាងព្រះពុទ្ធអមិតាយុស ព្រះពុទ្ធអមិតលក្ខណៈ ព្រះពុទ្ធអមិតធ្វជ ព្រះពុទ្ធមហាប្រភៈ ព្រះពុទ្ធមហានិរភាស ព្រះពុទ្ធរតនលក្ខណៈ ព្រះពុទ្ធសុទ្ធរស្មីប្រភៈ និងព្រះពុទ្ធដទៃ ៗ ទៀតជាអនេក ស្មើនឹងចំនួនគ្រាប់ខ្សាច់ក្នុងគង្គានទី លោកទាំងអំបាលនេះសុទ្ធតែផ្សាយព្រះសទ្ធម៌ទៅក្នុងបាច់ិមលោកធាតុទាំងមូលថា "បុប្ផជនទាំងឡាយ ចូរជឿស្ដាប់ព្រះសូត្រនេះ ដែលព្រះពុទ្ធទាំងឡាយឃើញគាប់ប្រសើរ និងទ្រង់ប្រទានអារក្ខាហើយ ដ៏មានប្រកាសគុណវិសេសរបស់ព្រះអមិតាយុសពុទ្ធទុកស្រាប់ ។

១២ "ម្នាលសារីបុត្រ នៅមានព្រះពុទ្ធដទៃ ៗ ទៀតក្នុងឧត្តរលោកធាតុ (លោកធាតុខាងជើង) ដូចយ៉ាងព្រះពុទ្ធអគ្គិស្កន្ធ ព្រះពុទ្ធវៃស្វានរនិរឃោសៈ ព្រះពុទ្ធទុស្ប្រធម៌ ព្រះពុទ្ធអាទិត្យសម្ភវៈ ព្រះពុទ្ធជាលិនីប្រភៈ នឹងព្រះពុទ្ធដទៃ ៗ ទៀតជាអនេកស្មើនឹងចំនួនគ្រាប់ខ្សាច់ក្នុងគង្គានទី លោកទាំងអំបាលនេះ សុទ្ធតែទ្រង់ផ្សាយព្រះសទ្ធម៌ទៅក្នុងឧត្តរលោកធាតុទាំងមូលថា "បុថុជ្ជនទាំងឡាយចូរជឿស្តាប់ព្រះសូត្រនេះ ដែលព្រះពុទ្ធទាំងឡាយឃើញគាប់ប្រសើរ នឹងទ្រង់ប្រទានអារក្សាហើយដ៏មានសេចក្តីប្រកាសគុណវិសេសរបស់ព្រះអមិតាយុសពុទ្ធទុកស្រាប់" ។

១៣ "ម្នាលសារីបុត្រ នៅមានព្រះពុទ្ធដទៃ ៗ ទៀតក្នុងហេដ្ឋិមលោកធាតុ (លោកធាតុខាងក្រោម) ដូចយ៉ាងព្រះពុទ្ធសិង្ហ ព្រះពុទ្ធយសសៈ ព្រះពុទ្ធយសប្រភៈ ព្រះពុទ្ធធម៌ ព្រះពុទ្ធធម៌ធ្វជ ព្រះពុទ្ធធម៌ធរ នឹងព្រះពុទ្ធដទៃ ៗ ទៀតជាអនេកស្មើនឹងគ្រាប់ខ្សាច់ក្នុងគង្គានទី ទាំងអំបាលនេះសុទ្ធតែផ្សាយ

ព្រះសទ្ធម៌ទៅក្នុងហេដ្ឋិមលោកធាតុទាំងមូលថា "បុប្ផជនទាំងឡាយចូរជឿស្ដាប់ព្រះសូត្រនេះ ដែលព្រះពុទ្ធទាំងឡាយទ្រង់ឃើញគាប់ប្រសើរ នឹងទ្រង់ប្រទានអារក្ខាហើយ ដ៏មានសេចក្ដីប្រកាសគុណវិសេសរបស់ព្រះអមិតាយុសទុកស្រាប់" ។

១៤ "ម្នាលសារីបុត្រ នៅមានព្រះពុទ្ធដទៃៗទៀតក្នុងឧបរិមលោកធាតុ (លោកធាតុខាងលើ) ដូចយ៉ាងព្រះពុទ្ធព្រហ្មឃោសៈ ព្រះពុទ្ធនក្ខត្តរាជ ព្រះពុទ្ធគន្ធោត្តម ព្រះពុទ្ធគន្ធប្រភាស ព្រះពុទ្ធមហាវ្ចិស្កន្ធ ព្រះពុទ្ធរតនកុសុមសំបុស្បិ-តគាត្រ ព្រះពុទ្ធសាលេន្ទ្ររាជ ព្រះពុទ្ធរតនោត្បលស្រី ព្រះពុទ្ធសព្វាត្ថទស្ស ព្រះពុទ្ធសុមេរុកល្ប នឹងព្រះពុទ្ធដទៃៗទៀតជាអនេកស្មើនឹងចំនួនគ្រាប់ខ្សាច់ក្នុងគង្គានទី ទាំងនេះរាល់ៗព្រះអង្គក៏សុទ្ធតែផ្សាយព្រះសទ្ធម៌ទៅក្នុងសកលលោកធាតុខាងលើថា "បុប្ផជនទាំងឡាយចូរជឿស្ដាប់ព្រះសូត្រនេះដ៏ជាពុទ្ធដម្រាស់ ជាសេចក្ដីដែលព្រះពុទ្ធទាំងឡាយទ្រង់ឃើញគាប់ប្រសើរ ទ្រង់ប្រទានអារក្ខាមកហើយ ដ៏មានសេចក្ដីប្រកាសគុណវិសេសរបស់ព្រះអមិតាយុសពុទ្ធដូច្នេះ" ។

១៥ "ម្នាលសារីបុត្រ អ្នកឯងសំគាល់ដូចម្តេច ហេតុម្តេចទើបពោលថា ព្រះសូត្រនេះព្រះពុទ្ធទាំងឡាយបានទ្រង់ឃើញគាប់ប្រសើរ នឹងទ្រង់ប្រទានអារក្ខាមកហើយ ក៏បើសាធុជនប្រុសក្តីស្រីក្តីបានជឿស្តាប់ត្រាប់ត្រងព្រះពុទ្ធទាំងឡាយនោះ ផ្តើមនសិការដល់ព្រះនាម អមិតាយុស នឹងនាមនៃព្រះសូត្រនេះហើយ សាធុជននោះនឹងបានទទួលអារក្ខា (គឺសេចក្តីពិ-ភក្ខរក្សា) អំពីព្រះពុទ្ធទាំងពួង ហើយនឹងមិនឃ្លៀងឃ្លាតចាកអនុត្តរសម្យក្សម្ពោធិ (អនុត្តរសម្មាសម្ពោធិ) ហេតុដូច្នេះឯងសារីបុត្រ អ្នកទាំងឡាយទើបគួរគាប្បីជឿស្តាប់ពាក្យតថាគត នឹងគាប្បីជឿស្តាប់សេចក្តីប្រកាសរបស់ព្រះពុទ្ធអំបាលនោះ សា-រីបុត្រ បើអ្នកឯណាបានសាធ្យាយមន្ត ជាក្នុងអតីត បច្ចុប្បន្ន ឬអនាគតក៏តាម តាំងចិត្តប្រាថ្នានឹងឲ្យបានទៅកើតក្នុងដែនរបស់ព្រះពុទ្ធអមិតាយុស អ្នកអំបាលនោះនឹងមិនឃ្លៀងឃ្លាតចាកអនុត្តរសម្យក្សម្ពោធិឡើយ ហើយនឹងបានទៅកើតក្នុងដែននោះ សម្រេចដូចបំណងជាប្រាកដពិត ព្រោះហេតុនោះ

សារីបុត្រ សាធុជនប្រុសក្តីស្រីក្តី បើមានសទ្ធាជឿជាក់ក៏គួរនឹងសាធ្យាយមន្ត តាំងចិត្តប្រាថ្នាឲ្យទៅកើតក្នុងដែននោះ" ។

១៦ "ម្នាលសារីបុត្រ តថាគតពោលសរសើរព្រះគុណវិសេស នៃព្រះពុទ្ធទាំងឡាយនោះក្នុងកាលឥឡូវនេះដូចម្ដេចព្រះពុទ្ធទាំងឡាយនោះ ក៏រមែងពោលសរសើរគុណវិសេសរបស់ព្រះតថាគតដូច្នោះដោយពាក្យថា "ព្រះសាក្យមុនីសម្មាសម្ពុទ្ធបានធ្វើការដ៏កម្រក្រៃពេកឡើសម្រែប ពោលគឺទ្រង់បាននូវអនុត្តរសម្មាសម្ពោធិក្នុងមនុស្សលោក ក្នុងសម័យដែលកំពុងតែមានសេចក្ដីអាប់ឱនទាំង ៥ ប្រការ ដើម្បីប្រយោជន៍ដល់វេនេយ្យសត្វព្រះអង្គទ្រង់បំណែកចែកចាយនូវព្រះធម៌ដែលជារបស់កម្រមនុស្សនឹងចូលចិត្តបាន" ដូច្នេះ ។ ម្នាលសារីបុត្រក្នុងកណ្ដាលសេចក្ដីលាមកនៃលោក ក្នុងវេលាដែលកំពុងអាប់ឱននេះ តថាគតបានពុះពារសេចក្ដីលំបាក ទាល់តែបានបាននូវអនុត្តរសម្មាសម្ពោធិជាប្រយោជន៍ខ្លួន និងដើម្បីប្រយោជន៍ដល់វេនេយ្យសត្វ បានប្រកាសព្រះធម៌ជារបស់កម្រសត្វនឹងចូលចិត្តបាន សេចក្ដីលំបាកក្រៃក្រៃនៃការនោះមហិមាដូច្នេះ" ។

ពួកអ្នកកាន់លទ្ធិមហាយានមានសេចក្ដីជឿនឹងប្រតិបត្តិព្រះសូត្រជាសំខាន់ដូចយ៉ាងបច្ចុប្បន្នបិនដែលនៅក្នុងប្រទេសនេះ ព្យាយាមរាយត្រដោកសូត្រមន្តប៉ុយប៉ប់សុំឲ្យបានទៅកើតនៅទីសុខាវតី, ក៏ការដែលពួកមហាយានិកនិកាយកាន់ថាមានព្រះពុទ្ធនឹងព្រះពោធិសត្វស្ថិតនៅឯស្ថានសួគ៌រហូតកល្បមិនបេះបុតិប្រែប្រួលទៅណា ជាអ្នកបាំរក្សាព្រះពុទ្ធសាសនានឹងជួយដោះគ្រោះថ្នាក់របស់មនុស្ស ដែលមានគ្រោះថ្នាក់ប៉ាំងដូចពោលហើយខាងដើមដូច្នេះនេះ គឺធៀបយកតាមលទ្ធិសាសនាព្រាហ្មណ៍ ព្រោះលទ្ធិនេះកាន់ថាមានព្រះជាម្ចាស់នៅលើស្ថានសួគ៌ ជាអ្នកបាំឲ្យនូវសេចក្ដីល្អ សេចក្ដីអាក្រក់ដល់មនុស្សទាំងឡាយ អ្នកណាធ្វើខុសមិនត្រូវព្រះហឫទ័យព្រះជាម្ចាស់ ៗ ក៏ធ្វើទោសទណ្ឌកម្មដល់អ្នកនោះ អ្នកណាប្រព្រឹត្តប្រពៃត្រូវព្រះហឫទ័យព្រះជាម្ចាស់ ៗ ក៏ប្រទានពរបណ្ដាលឲ្យបន្ទះលាភសក្ការៈនឹងឫទ្ធិតេជះ តាមចិត្តបំណងគ្រប់យ៉ាងរហូតដល់ទៅសន្មតថានាងតារាជាជាយារបស់ព្រះពោធិសត្វដូចយ៉ាងនាងទេពធីតាជាជាយារបស់ព្រះជាម្ចាស់, គិតកែគតិ

សាសនាទៅតាមបែបនេះ ដោយកាន់យកតាមធម្មតាថា ព្រះពោធិសត្វរមែងរក្សាព្រះពុទ្ធសាសនា ទើបប្រដៅឲ្យមនុស្សយឹតយកព្រះពោធិសត្វជាទីពឹង ទំនងដូចគតិអ្នកកាន់សាសនាព្រាហ្មណ៍ ពឹងទេវតានៅលើស្ថានសួគ៌ ព្រោះនឹងប្រដៅឲ្យយកខ្លួនជាទីពឹងរបស់ខ្លួនដូចក្នុងបទថា "អត្តា ហិ អត្តនោ នាថោ ខ្លួនជាទីពឹងរបស់ខ្លួន" ដូច្នេះកម្រមនុស្សនឹងឃើញតាមសម្បីជាសេចក្តីពិតត្រូវដូច្នេះ ក៏មិនសូវមានអ្នកណានឹងយល់តាម ព្រោះវិស័យមនុស្សធ្លាប់ពឹងអ្នកដទៃមកហើយតាំងពីតូចអ្នកដែលមានបញ្ញាទន់ទាបរមែងចូលចិត្តងាយក្នុងពាក្យប្រដៅឲ្យពឹងអ្នកដទៃ ជាងឲ្យពឹងខ្លួនឯង សូម្បីក្នុងលទ្ធិគ្រិស្តនឹងលទ្ធិឥសលាម ក៏យកដម្រាប់តាមលទ្ធិព្រហ្មញ្ញទាំងអស់ សុទ្ធតែបង្អួលទៅឯស្ថានសួគ៌ ព្រោះឃើញបែបវិធីប្រដៅយ៉ាងនោះមានសេចក្តីចំរើនមកហើយ ទើបបញ្ញត្តទំនងប្រហែលគ្នា ប្លែកតែព្រះពុទ្ធសាសនាប្រដៅឲ្យពឹងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនៅក្នុងលោករៀងអាយនេះ ។

(មានតទៅទៀត)



ព្រះពុទ្ធរូប ១ អង្គនៅក្នុងចំណោមព្រះពុទ្ធរូបដ៏ជាច្រើន
នៅក្នុងវត្តអានន្ទប៉ាយះ ក្រុងបាគន ភូមា

លោកន័យ

( ព )

នាកាលឯព្រឹក អ្នកឲ្យទានទឹក ស្នត្តស្លាម្ហផង លុះថ្ងៃ
ខ្ពស់បាន ឲ្យទានទៀតម្តង គឺបាយទឹកផង អាហារភោជន ។
លុះថ្ងៃត្រង់ជាក់ ឲ្យទានមាសប្រាក់ សារពើទ្រព្យធន ថ្នាំ
បំបាត់ព្យាធ អាពាធធ្ងន់ លុះល្ងាចទន់ៗ ឲ្យទានអាស្នា ។
ខ្នល់ខ្នើយពូកព្រិ កន្ទេលបៀមបំ ប្រទីបជ្វាលា ជាប្រក្រតី
ថ្លែងពីប្រស្នា វិតក្កបណ្ហា សូរពម្លេះហោង ។ ឯកសមយេ
មានថ្ងៃមួយឯ ក្សត្រាប្រុះប្រុង ផ្ទុកព្រះហឫទ័យ មមៃប៉ុនប៉ង
ប្រពាតលេងលង លើកបាប់អម្រឹគ ។ ស្តែងស្តេចចេញចរ
ពាកព្រះនគរ ទៅអំពីព្រឹក នៅអស់សេនា យោធាពន្លឹក
ពលផងគគឹក ហែមហាក្សត្រា ។ ស្តេចទៅដល់ព្រៃ ដង្គ
មួយនៃ ទើបឲ្យសេនា រៀបរាយបង្កាត់ ឃាំងស្កាត់ដាសដា
ស្រែកហោគ្រប់គ្នា បង្អើលសត្វផង ។ ស័ព្ទគងស័ព្ទស្គរ
កក្រើកខ្ទរខ្ទរ លាន់ឮរំពង ទូទាំងព្រៃព្រឹក អម្រឹគយង់ឃ្នង
ផ្អើលរត់ត្រសង ត្រសែតភិតភ័យ ។ មានប្រើសមួយនោះ
រត់មកបំពោះ ព្រះភ័ក្ត្រក្សត្រថ្លៃ ស្តេចយល់ពុំលង់ ឡើងគង់
អាជានេយ្យ ដែលផាយវិលវៃ ដេញអម្រឹគា ។ អស់ពល

ទាំងឡាយ រត់តាមប្រញាយ ពុំទាន់ក្សត្រា តែមួយព្រះអង្គ ចូលក្នុងព្រឹក្សា តាមអម្រឹគា ពុំទាន់ឡើយនែ ។ ហើយ ណាស់ស្តេចឈប់ សំរានដោយម្លប់ ក្រោមដើមព្រះជ្រៃ មួយមែកសាខា យក្សាទិភ័យ សំណាក់អាស្រ័យ នៅរាន នោះណា ។ ឈ្មោះនន្ទិយក្ស តែងទៅសំណាក់ បម្រើក្សត្រា ព្រះបាទវេស្សវ័ណ សោភ័ណថ្លៃថ្លា ឲ្យជ្រៃនោះជា លំនៅ យក្សយង់ ។ ហើយស្តេចផ្តាំថា បើអ្នកឯណា បរចូលទៅ ក្នុង ក្រោមជ្រៃនេះឯង ប្រស្វែងចោទបង់ ពណ្ណឹងអត្ថត្រង់ មូលតរធម៌ ។ បើអ្នកណាបេះ មូលតរធិនេះ កុំបរិភោគ្គា ថាបើពុំបេះ បំណេះនោះណា បូរហាប់យកវា នោះបរិភោគ ហោង ។ ហេតុដ្បិតដូច្នោះ បើអ្នកណាឆ្លោះ ទៅដល់ជា ម្តង ទើបនន្ទិយក្ស ចាប់អ្នកនោះហោង ពណ្ណឹងទំនង ដំណើរ ធម្មា ។ បើពុំដឹងអត្ថ នៃមូលតរធម៌ ទើបយក្សភោគ្គា ដឹកឈាមស៊ីសាច់ ពុំដាច់ឡើយណា ឈាមដាប់ហត្ថា ពុំស្ងួត ឡើយនែ ។ កាលណោះព្រះអង្គ ស្តែងស្តេចទើបគង់ ក្រោម ដើមព្រះជ្រៃ នន្ទិយក្សចាប់ ស្តេចខាប់ហើយនែ ពណ្ណឹងថាហៃ

អ្នកមកពីឯណា ។ មហាក្សត្រស្ដាប់ហើយ ពើកបន្ទូលឆ្លើយ ថាហៃយក្ស អង្គអញនាមនៃ ធនញ្ជ័យរាជា សោយរាជ្យ នៅឯ នគរនោះនៃ ។ យក្សផណ្ដឹងថា អ្នកបេះទេស្នា ទូល តរធម៌បី ឬមួយពុំដឹង ដំណើងឡើយនៃ ចូរប្រាប់រ៉េវ ឲ្យ បានដឹងវ៉ា ។ ស្ដេចឆ្លើយថារាជបិ មួលតរធម៌ ម្ដេចប្អូនបរពា យក្សយង់ស្ដាប់ហើយ ឆ្លាស់ឆ្លើយវឹងថា មានអ្វីមួយជា មង្គលពេកក្រៃ ។ អ្វីឥតមង្គល បើដោយរមិល អាថ៌ពីរ នេះនៃ យល់ជាកម្ម ក្រៃក្រលៃ្បងវ៉ៃ មានអធ្យាស្រ័យ ដឹង អាថ៌នេះណា ។ ស្ដែងស្ដេចស្ដាប់ហើយ បន្ទូលឆ្លាស់ឆ្លើយ ថាហៃយក្ស អញពុំដឹងឡើយ យក្សឆ្លើយវឹងថា បើព្នោះ អ្នកជា បំណើអញហោង ។ សម្ដេចក្សត្រា ស្ដាប់ហើយ ឆ្លើយថា ហៃយក្សយង់ឃ្នង ប្រស្ដែងតើដឹង ដំណើងទំនង អាថ៌ធម៌នេះហោង ឬមួយពុំដឹង ។ យក្សយង់ឆ្លាស់ឆ្លើយ ថាមហារាជអើយ អញឥតដំណើង ស្ដេចស្ដាប់យក្សហើយ ឆ្លាស់ឆ្លើយទៅវឹង ថាបើពុំដឹង កុំធំជាកាច ។ បើអញ ទៅវឹង ទៅហៅនអញនឹង ផណ្ដឹងអ្នកប្រាជ្ញ លោកបានត្បូត្រ

រៀន របៀនឯងអាច យក្សហាមហារាជ កុំហាដូច្នោះ ។ បើសែងស្តេចទៅ ដល់ឋានលំនៅ នគរនាយនោះ ពុំដែលនឹងមក រួសរកអញស្មោះ កុំរកកលដោះ តាមតែនឹងថា ។ ស្តែងស្តេចស្តាប់ហើយ បន្ទូលឆ្លាស់ឆ្លើយ ថាហៃយក្សា កុំប្រស្តែងគិត ព្រួយចិត្តចប់ថា អញពុំយាត្រា វិលវឹងមកឋាន ។ ធម្មតាជាក្សត្រ សោយរាជសម្បត្តិ រក្សាសព្វឋាន បើមានទុក្ខភ័យ ក្រក្រៃប៉ុន្មាន សោតសឹងតែមាន ពាក្យ៥ប្រការ ។ មួយគឺពាក្យហាន មួយគឺពាក្យមាន ឫទ្ធិអស្ចារ្យ មួយគឺពាក្យគាប់ ដោយច្បាប់ធម៌អាថ៌ មួយពួកបរិហារ ទៀងឲ្យជឿក្រៃ ។ មួយមានពាក្យធំ គឺបុកបែនលំ តតអុកដទៃ ទាំង៥ប្រការ ដូចគភ៌ចាស់ផ្ទៃ ប្រសូតហើយនៃ ប្ដូលវិញពុំបាន ។ ហេតុនោះអញនឹង ក្រឡាប់វិលវឹង មកវិញពុំមាន អញពុំខ្លាចភ័យ ឡើយនៃដ្បិតមាន ច្បាប់ពីបុរាណ ទាំង៥សួស្តី ។ យក្សយល់ឆ្លើយឋាន ថាមហារាជមាន អ្នកប្រាជ្ញឬអ្វី ស្តេចស្តាប់យក្សហើយ ឆ្លាស់ឆ្លើយវឹងខ្មី ថាយក្សតិរិយ អ្នកប្រាជ្ញអញមាន ។ ទើបយក្សថាបើ ស្តេចទៅហើយតើ មត់ថ្ងៃប៉ុន្មាន

ទើបវិលត្រឡប់ ស្តេចប្រាប់ទៅថ្កាន ថាអត់អញបាន តែប្រាំពីរថ្ងៃ ។ យក្សថាអញអត់ បើឃ្លាតសន្មត ពុំឃ្លាតឡើយនៃ អញទៅធីអស់ ទាំងមនុស្សក្នុងផ្ទៃ ក្រោមឲ្យក្សីណក្ស័យ នូទាំងនគរ ។ កាលនោះព្រះបាទ ធនញ្ជ័យនរនាថ ធិរាជភូធរ ស្តេចលាយក្ខយង់ ឡើងគង់អស្សតរ វិលថ្កាននគរ បូរីរម្យរ័តន៍ ។ ដល់ស្រែបព្រះបាទ ឡើងលើប្រាសាទ ប្រសើររោនថិត ព្រួយព្រះហឫទ័យ ក្សត្រថ្លៃពេកក្តាត់ លុះព្រឹកឡើងថ្វាត់ ស្តេចបេញរោងរម្យ ។ អស់មុខមន្ត្រី សេនាបតី ព្រាហ្មណ៍ពិទូបាស់ទុំ អង្គុយរៀងរាល់គង់គាល់ប្ជុបជុំ ទើបក្សត្រឧត្តម បន្ទូលទៅថា ។ ហៃមន្ត្រីផង ដ្បិតយក្ខយង់ឃ្នង ឲ្យរកប្រស្នា ឈ្មោះមូលតរធម៌សម្មាថ្ងៃថ្លា អញមត់នឹងវា តែប្រាំពីរថ្ងៃ ។ មន្ត្រីយោធាព្រាហ្មណ៍ពិទូភណា បារ្យបាស់ទីទៃ ស្តាប់ព្រះបន្ទូល ព្រះស្សួរក្សត្រថ្លៃ រកអាថ៌នោះនៃ ពុំយល់ឡើយណា ។ ស្រែបទើបក្រាបទូល បពិត្រឥស្សូរ ជាម្ចាស់សិរសា រីអាថ៌នេះនៃក្រៃក្រែមហិមា យើងខ្ញុំគ្រប់គ្នា ពុំយល់ឡើយនៃ ។ ព្រះ

បាទតស្សូរ ស្តាប់ព្រះបន្ទូល ព្រួយព្រះហឫទ័យ ត្រាស់ថាឱ អញ នេះមិញសំកុ្បយ ជីវិតប្រល័យ អសារសូន្យសោះ ។ បរោ-ហិតទូលថា បពិត្រក្សត្រា បន្ទូលម្តេចប្លោះ ស្តេចបន្ទូលថា ព្រាហ្មណ៍អើយបើដោះ សារអាថ៌ធម៌នោះ ពុំបានឡើយណា ។ យក្ខទឹងមកប- រិភោគទាំងនគរ វិនាសសោះសារ សេនាបតី វិន្ទ័យទូលថា បពិត្រព្រះមហា ក្សត្រាប្រុះប្រុង ។ រីអាថ៌នេះគែ កម្រក្រៃក្រៃ ពេកពន់កន្លង រៀរតែព្រះបាទ ត្រាស់ញាណអ្នក ផង ក្រៅលែងនោះហោង ពុំអាចរួសរក ។ អាថ៌នេះបាន ឡើយ ស្តេចបន្ទូលឆ្លើយ ប្អោះយើងឲ្យយក ធនញ្ជ័យកុមារ ត្រអាលបួលមក ឲ្យគិតរិះរក អាថ៌ធម៌នេះណា ។ សេនាបតី ក្រញាញក្រាបវិន្ទ័យ ទើបទូលទាស់ថា ធនញ្ជ័យនេះក្មេង ពុំដឹង អ្វីវា ស្តេចស្តាប់ហើយណា ទ្រង់ព្រះក្រោធក្រៃ ។ បន្ទូល ត្រាស់ថា ហៃអស់សេនា មន្ត្រីទាំង បើពុំយល់អាថ៌ តរធម៌ នេះនែ ក្នុងពាថ្ងៃ អញឲ្យសំឡាប់ ។ អស់មុខមន្ត្រី សេនា-បតី ប្រណម្យស្តែងស្តាប់ ភិតភ័យខ្លបខ្លាច ព្រះរាជបញ្ញត្តិ ពុំ អាចសងសព្ទ សោតសិងស្ងៀមនៅ ទើបបរោហិត ទូលថា

បពិត្រ ក្សត្រថ្លៃចមហៅ គួរឲ្យជំនុំ ដោយជំពូកនៅ ទូទៅទីទៃ ទាល់ ៧ ថ្ងៃ ។ ស្ដេចស្ដាប់បរោហិត ថាអើគាប់ពិត ទើប ក្សត្រផ្ទៀសផៃ ត្រាស់ប្រើឧបរាជ នូវរាជបុត្រថ្លៃ ឲ្យរក អាចិនៃ មូលតរធម៌ ។ សេនាបតី អស់មុខមន្ត្រី អមាត្យ យោធា ចូលមកប្រជុំ ជំនុំរកអាចិ ថាអ្វីហៅជា មាន មន្ទិលក្រៃ ។ សឹងតែទន្ទេញ រកអាចិនោះមិញ ពីព្រឹកដល់ ថ្ងៃ ល្ងាចគោះដល់យប់ ពុំឈប់ឡើយនៃ ពុំអាចទៅឮ លំនៅឡើយណា ។ លុះបឋមយាម ស្ដេចចេញគម្រាម ទ្រង់ព្រះខ័នថ្លា ហើយមានព្រះបន់- ទូលដណ្ដឹងថា រកអាចិ ប្រស្នា យល់ហើយឬនៅ ។ ថាបើពុំយល់ ឡើយសំនឹង ដល់ អម្រឹត្យុ[1] អញនឹងកាត់ក្បាល អស់កាលតះរូវ គ្រា នេះឯងក្រូវ ពុំលែងឡើយណា ។ អស់មុខមន្ត្រី លើកអញ្ជលី បង្គំទូលថា បពិត្រព្រះបាទ នរនាថថ្លៃថ្លា រកអាចិនេះណា ពុំយល់ឡើយហោង ។ ស្ដេចស្ដាប់ហើយណា វិលចូល ក្នុងប្រា- សាទសួគ៌ឥតហ្មង លុះអធ្រាត្រចេញ មកវិញទៀត

---

១ សំស្ក្រឹត ម្រឹត្យុ ។ ម្រឹត្យូវពាក្យក្លាយ ។

ម្តង គម្រាមអ្នកផង ដូចដែលនោះណា ។ ហើយចូលទៅ
វិញ ដល់ផាស់ទុំមិញ ជួបជាបីគ្រា សោតសឹងពុំយល់
លុះដល់សុរិយា ព្រឹកឡើងជួបជា ថ្ងៃបីហើយហោង ។
ស្តេចឲ្យបុរោហិត នៅអស់ព្រាហ្មណ៍ព្រឹទ្ធ ជំនុំអឹងកង
ពីព្រឹកលុះយប់ ពុំឈប់ឡើយហោង ស្តេចចេញបីដង គម្រាម
បំភិត ។ ពុំយល់ឡើយណា លុះព្រឹកជួបជា បួនថ្ងៃស្តេចគិត
ប្រើអស់អ្នកប្រាជ្ញ នៅរាជបណ្ឌិត ជំនុំរិះគិត រកអាថិប្រស្នា ។
ពីព្រឹកលុះយប់ ពិតពុំមានឈប់ សម្តេចក្សត្រា ចេញមក
គម្រាម ធ្វើតាមអតីតា រកអាថិប្រស្នា ពុំយល់ឡើយនៃ ។
លុះស្រាងសុរិយា ព្រឹកឡើងជួបជា គំរប់៥ថ្ងៃ ស្តេចឲ្យ
អស់សង្ឃ- រាជទ្រង់សីលសៃយ ជំនុំរកនៃ មូលតរធម៌ ។
អស់មហាសង្ឃរាជ ជំនុំលុះល្ងាច ឥតអ្នកឯណា មួយមាន
យោបល់ អាចយល់បញ្ហា មូលតរធម៌ ដល់តិច
ឡើយហោង ។ លុះយាមបឋម ក្សត្រក្សាន្តឧត្តម ឥស្សរ
ប្លាស់ប្លង់ ទ្រង់ព្រះពស្ត្រស ល្អះល្អឥតហ្មង ទ្រង់ស្បៃ
សផង ព្រះហស្តទ្រង់ភ្ញី ។ ចេញមកបូជា បត្តិអស់មហា

សង្ឃរាជព្រឹទ្ធ មានព្រះបន្ទូល សាកសួរអំពី រកអាថ៌សេចក្ដី យល់ហើយឬនៅ ។ អស់សង្ឃទូលថា បពិត្រព្រះមហារាជក្សត្របរមបោ វិមូលតរធម៌ មានអត្ថនោះជ្រៅ អាត្មាភាពខ្លៅ រិះរកពុំយល់ ។ ស្ដេចស្ដាប់ហើយណា វិលបូលក្នុងប្រា- សាទសួគិមង្គល លុះដល់អធ្រាត្រ ព្រះបាទទសពល ក្សត្រថ្លៃនិមិល ទ្រង់ព្រះពស្ត្រា ។ ទ្រង់ព្រះពស្ត្រប្រាលរុងរឿងរន្ទាល ព្រះហស្តរាជា ទ្រង់ព្រះវិជ្ជនី បេញពីក្រឡាបន្ទំរាជា មកប្ដានសង្ឃហោង ។ ក្សត្រថ្លៃឧត្ដម ពុំប្ញាយបង្គំ អស់ទាំងសង្ឃផង មានព្រះបន្ទូល ព្រះសួរសារសង ថាហៃស្រមណ៍ផង ទាំងឡាយនេះណា ។ សោតសឹងសូត្ររៀនដោយនោរបៀន គម្ពីរដីកា ម្ដេចឥតដំណាំង ពុំដឹងប្រស្នា អស់សង្ឃទូលថា បពិត្រក្សត្រថ្លៃ ។ វិមូលតរធម៌ កំបាំងមានអាថ៌ កម្រក្រៃក្រៃ អាត្មាភាពពុំ ដឹងដំណើរនៃ រិះរកពីថ្ងៃម្លេះហើយពុំយល់ ។ ស្ដេចបន្ទូលថា ចុះស្រមណ៍ឬអា សារសោះសូន្យសល់ ប្រោះគួរកុំបោ ស្រមណ៍គួរឥតផល ឥតភស្ដុពុំយល់ អាថ៌ធម៌នេះណា ។ ព្រះបាទបរមបោ បរបួលទៀតទៅ

ដាស់ទុំក្សត្រា ទ្រង់កាសិកពស្ត្រ ព្រះហស្តភាជា ក៏កាន់គ្រទា ទ្រង់ព្រោះរាជរ័តន៍ ។ ស្ដែងស្ដេចបរបេញ មកក្រៅទៀតវិញ ទ្រង់ព្រះសណ្ឋិត បន្ទូលថាស្រមណ៍ ជំនុំរិះគិត រិះរកអាថិឥត អ្នកណាមួយយល់ ។ បួសជាស្រមណ៍ថ្មី នឹងប្រយោជន៍អ្វី ល្ងង់ខ្លៅឆ្ងាយឆ្ងល់ ពុំបេះរិះគិត ខ្លៅឥតយោបល់ កិច្ចការពុំយល់ ប្រស្នានេះណា ។ អស់មហាសង្ឃរាជ ស្ដាប់ហើយសឹងខ្លាប ភិតភ័យតក្កមា ពុំអាចទូលស្នង សារសងវាចា ដ្បិតទ្រង់ក្រោធា ពេកពន់ប្រមាណ ។ ទើបមហាក្សត្រា ស្ដែងស្ដេចលីលា ចូលក្នុងព្រះរោង ព្រួយព្រះហឫទ័យ ភ័យឥតប្រមាណ ញ័រអស់អង្គប្រាណ លុះស្រាងសុរិយា ។ ចួបចូលជាថ្ងៃ ៦ ហើយនៃ ទើបមហាក្សត្រា ចេញរាជរោងរម្យ ឧត្ដមថ្លៃថ្លា មន្ត្រីសេនា គង់គាល់រៀងរាយ ។ សម្ដេចក្សត្រា បន្ទូលត្រាស់ថា ម្នាលអ្នកទាំងឡាយ គំរូវនេះមិញ បើអញទៅអោយ ស្រុកនេះអន្តរាយ វិនាសអស់ហោង ។ ហេតុនោះអញទៅ ឲ្យយក្ខយោរយៅ ធីអញជាម្ចង ប្ញៃស្រុកនេះឯង ពុំលែងឡើយហោង កុំបីអ្នកផង គិតអញឡើយណា ។

អស់មុខមន្ត្រី សេនាបតី ព្រាហ្មណ៍ព្រឹទ្ធបោរាណ ឮព្រះបន្ទូលអន់អួលឱរា ជោរជលនេត្រា គ្រប់គ្នាទីទៃ ។ កាលនោះព្រះអង្គ ស្តេចចូលទៅក្នុង ប្រាសាទមាសមៃ អស់ស្រីស្រឹង្គារ បរិពារច្រើនក្រៃ សឹងសោកក្សត្រថ្លៃ ខ្សឹកខ្សួលគ្រប់គ្នា ។

*បទព្រហ្មគីត* កាលនោះ នាងនាថឧត្តរា ទេវីអគ្គជាយា សោតសឹងទ្រង់ព្រះកន្សែង ។ ពិលាពលន់អាលោះ គិតស្រណោះក្សត្រគម្តែង ដ្បិតនឹងបាកបំបែង បង់បាត់ទៅទីទុរ-ហេន ។ ឯអង្គព្រះភូមី សឹងសោកពីលាបប្រាសប្រាណ ទល់ទុក្ខពន់ប្រមាណ ថ្លែងទំនួញទួញមកទៅ ។ លុះស្រាងស្រេបព្រះអង្គ ស្តែងស្តេចទ្រង់ព្រះពស្ត្រខ្មៅ យាងព្រះបាទាទៅ តែឯកឯងពុំគង់យាន ។ កាលនោះនាងឧត្តរា អគ្គជាយាជាប្រធាន អស់ស្រីស្នំប៉ុន្មាន សឹងចេញចរតាមក្សត្រា ។ គក់ទ្រូងទ្រហោយំ សព្ទយោបំកងសោះសា អឺងកងជាកោលា- ហលហាក់ភ្ញុកទាំងបុរី ។ ឯអស់ព្រាហ្មណ៍ព្រឹទ្ធានូវសេនាបតីក្តី អមាត្យមុខមន្ត្រី សឹងតាមទៅឥតមានសល់ ។ ស្តេចចេញដោយទ្វារបូព៌ ទិសពុំយូរបានទៅដល់ បស្ចិម

គ្រាមមណ្ឌល ដាលំនៅបៅធនញ្ជ័យ ។ កាលនោះពោធិសត្វ បុរស័រតន៍វិសេសថ្លៃ លេងនឹងក្មេងដទៃ ឮសព្ទខ្សួញទំនួញ កង ។ បរបុះពីគ្រឹហា ហើយម្នីម្នារត់ត្រសង ទៅយល់ក្សត្រ ប្បុះប្បូង ទៀងទើបព្រះពង្សពោធិ ។ បរបូលថ្វាយបង្គំ ក្សត្រ ឧត្តមសូមសួរពី ដំណើរព្រះភូមិ ស្ដេចនឹងទៅឋានឯណា ។ យល់ហាក់អង្គឹក្ដី ពុំដូចពីមុនសព្វគ្រា ស្ដេចយាងព្រះបាទា ពុំគង់យានមានបើអ្វី ។ ស្ដែងស្ដេចបន្ទូលឆ្លើយ ថាចៅអើយ ដ្បិតនន្ទី យក្សយង់ទ្រង់ឫទ្ធិ ឲ្យអញរកអាចិប្រស្នា ។ មួយ ឈ្មោះមូលតរធម៌ ពុំយល់អាចិអញយាត្រា នឹងទៅឲ្យយក្សវា បរិភោគអញឥឡូវហោង ។ ព្រះពោធិសត្វស្ដាប់ ស្ដេចប្រាយ ប្រាប់ដោយទំនង ត្រែកអរក្រៃកន្លង ថាលាភោបរមលាភ ។ មកដល់អញនាថ្ងៃ នេះឯងនៃទើបអ្នកក្រាប ទូលទៅឲ្យបាន ជ្រាប ថាបពិត្រក្សត្រថ្លៃថ្លា ។ កុំស្ដេចព្រួយព្រះទ័យ ខ្ញុំឯងនៃ អាបធារនា ទទួលយកអាសា តាងព្រះអង្គឥឡូវនេះ ។ ទើប ស្ដេចត្រាស់ថាហៃ បៅធនញ្ជ័យបាឯងបេះ អត្ថមូលតរធម៌នេះ ហើយឬម្ដេចបានឹងទៅ ។ ពោធិសត្វទូលថា បពិត្រមហា

ក្សត្របមពៅ ប្រស្នានេះអាថិជ្រៅ បើវៀរលែងអញខ្ញុំហើយ ។ អស់មនុស្សទាំងជម្ពូ- ទ្វីបនេះក្សូវពុំដឹងឡើយ មានតែខ្ញុំឯង ហើយ អ្នកណានឹងដឹងលើសខ្ញុំ ។ ស្តេចស្តាប់ពាក្យពង្ស ពោ- ធិសត្វសោមនស្សភិរម្យ ថាច្នោះចូរហៅសំ- ដែងឲ្យ អញស្តាប់ផងណា៎ ។ ពោធិសត្វប្រណម្យ ថ្វាយបង្គំទើបទូល ថា ធម៌នេះព្រះសម្មា សម្ពុទ្ធឯងថ្លែងប្រោសសត្វ ។ ខ្ញុំនឹង ទេស្នានៅ ឋាននេះក្សូវពុំគួរក្តាត់ ពុំមានវត្តប្រណិបត្តិ ហាក់ បង្អោនព្រះធម្មា ។ ពិតពុំបានមានវត្ត ប្រណិបត្តិព្រះជិនស្រី ក្រញ្ញក្រាបរាបវន្ទ័យ ឱនលំទោនព្រះធម្មា ។ កាលនោះឯ ធនញ្ជ័យ សេដ្ឋីថ្លៃជាបិតា នៅនាងសុខុមា- លីឮថា ពោធិសត្វ ។ នឹងទៅកាន់យក្សា រត់ម្នីម្នាមកដល់ថ្វាត់ ថ្វាយ បង្គំមហាក្សត្រ ជាធនញ្ជ័យកុមារនោះ ។ ៧ ឆ្នាំទេក្សូវ ក្មេង ណាស់នៅធុមទឹកដោះ អំពីមាត់ដូច្នោះ ស្រដីម្តេចនឹងយក្ខ បាន ។ សូមទានកុំព្រះពៅ ស្តេចយកទៅផងក្សត្រក្សាន្ត មេត្តាទុកឲ្យទាន ព្រោះដ្បិតក្មេងណាស់នៅឡើយ ។ ស្តេច ស្តាប់ហើយត្រាស់ថា ហៃមហាសេដ្ឋីយើយ អញពុំយកទៅ

ឡើយ កូនព្រះស្ដេចបង់តាមទៅ ។ ធនញ្ជយកុមារ មាន
ប្រាជ្ញាបេះធមិជ្រៅ ប៉ុនប៉ងបំណងទៅ ជួយដោះទុក្ខអញឯង
ណា ។ ទើបពង្សពោធិសត្វ បុរសរ័តន៍បែងបរហា នឹងម្ដាយ
ឪពុកថា កុំអម្ចាស់ស្រីដីឃាត់ ។ នាងសុខុមាលី ស្ដាប់
ពាក្យពីពោធិសត្វ ហេតុក្ដីស្រឡាញ់ក្ដាត់ ឃាត់កូនស្ងួតជា
គាថា ។ មាតាតបិយ បុត្តកឯកិកា តាតហាទយា មាបង
រតំមេ ។ មាមំធិន្ទេសិ បុត្តេហិ ហៃបុត្រស្នេ ម្ដេចបាបោះបង់ឯ
ម្ដាយបង់សៀតតិឡូវហើយ ។ ម្ដាយទុកអ្នកស្មើឡើម ស្មើដង្ហើម
ម្ដាយជាត្រើយ សព្វថ្ងៃម្ដាយបានស្បើយ រស់ជីវិតដ្បិត
យល់បា ។ ធនញ្ជយសេដ្ឋីឆ្លើយ ថាកូនតើយយក្ខនោះវា
សាហាវឃោរមហិមា តែងចាប់មនុស្សសត្វសព្វថ្ងៃ ។ ជា
បំណើយប់ព្រឹក ឈាមទឹកជាប់នៅដៃ ខ្ទង់ខ្ពស់ ១ ត្នោតសៃ
ភ្នែកប៉ុនវង់ព្រះអាទិត្យ ។ បាទៅឋានយក្សា ហាក់ដូចបា
ក្ស័យជីវិត បទបាក្មេងពេកក្ដាត់ ស្រដីម្ដេចនឹងយក្ខបាន ។
ព្រះពង្សពោធិសត្វ បុរសរ័តន៍ឆ្លាស់ឆ្លើយថ្កាន បពិត្រអម្ចាស់
មាន គុណក្រាស់ក្រៃលែងប្រថពី ។ សូមអ្នកស្ដាប់ពាក្យខ្ញុំ

និងថ្លែងសំដែងវិទ្ធី អានុភាពមេត្រី ដោយគន្លងព្រះធម៌ថា ។ វីព្រះសូរ្យរង្សី មានរស្មីក្តៅមហិមា គឺមោះឲ្យក្តៅមហា សមុទ្រនេះពុំដែលបាន ។ កុំថាព្រះសុរិយា ស្ថិតនៅនាអាកាសហោង ទោះមុជទាំងពិមាន ទៅក្នុងមហាសមុទ្រក្តី ។ ពុំអាចនឹងក្តៅបាន ព្រះសុរិយ៉ានវិទ្ធូរង្សី គួរនាជួបគន្ធ- យក្ខរបឹងរឹងឃោរឃៅ ។ មេត្រីនៃព្រះពុទ្ធ ដូចសមុទ្រគម្ភីរជ្រៅ ត្រជាក់ពិតពុំក្តៅ ហេតុនោះអ្នកកុំឃាត់ឡើយ ។ ជនកនូវជននីស្តាប់ពោធិសត្វឆ្លាស់ឆ្លើយ គាប់ដោយធម៌ជាត្រើយ ពិតពុំទាំងឃាត់បុត្រា ។ ពោធិសត្វសាទរ ទទួលពរពីបិតាមាតាស្រេចហើយណា ទើបទូលទៅក្សត្រជេស្ឋដែយ ។ បពិត្រសូមព្រះអង្គ ស្តេចឡើងគង់យានប្រពៃ ទៅឋានយក្ខនោះនៃខ្ញុំនឹងឆ្លើយអាថ៌ប្រស្នា ។ ឯសេនាបតី ស្តាប់ពោធិ៍ហើយទូលថា បពិត្រព្រះរាជា ស្តេចនឹងទៅពុំគួរក្តាត់ ។ បើធនញ្ជ័យឆ្លើយអាថ៌ មូលតរធម៌នេះបានពិត ព្រះអង្គគង់ជីវិតយក្ខពុំបានបរិភោក្តា ។ ថាបើធនញ្ជ័យឆ្លើយ ពុំបានឡើយសមក្សត្រា ជាចំណីយក្សា បទតែទៅនឹងធនញ្ជ័យ ។ បើ

ស្ដេចត្រាស់ប្រើទៅ ធនញ្ជ័យទៅតែឯងនៃ យល់គាប់គួរពេក ក្រៃ បើធនញ្ជ័យឆ្លើយពុំបាន ។ ឲ្យយក្ខយង់នីរភ័យ ស៊ី ធនញ្ជ័យហើយសមបាន ជីវិតឯក្សត្រក្សាន្ត យក្ខពុំមកបរិភោគ ឡើយ ។ ស្ដេចស្ដាប់ពាក្យសេនា- បតីថាដូច្នោះហើយ ទើប ស្ដេចបន្ទូលឆ្លើយ អ្នកទាំងឡាយកុំអារម្ភ ។ ធនញ្ជ័យកុមារ នេះ អាចដឹងបេះធម៌ឧត្តម ប្រាកដបានពិតពុំ មានសន្ទិះបិត្ត អញឡើយ ។ ហេតុបេះធម៌ប្រសើរ ដូចដំណើរព្រះពុទ្ធហើយ អញពុំខានទៅឡើយ អញនឹងទៅផងធនញ្ជ័យ ។ ពោធិ- សត្វទូលថា បពិត្រមហាក្សត្រថ្លាថ្លៃ ខ្ញុំខ្លាចយក្ខនោះនៃ ខ្ញុំ ពុំបង់ទៅឡើយហោង ។ បើព្រះអង្គអម្ចាស់ បង្គាប់ត្រាស់ ប្រើអ្នកផង ឯណាធារនារង ទៅដោះសាអាថ៌នេះបាន ។ ខ្ញុំ នឹងឲ្យឈ្នួលពិត ឥឡូវឥតអ្នកណាហ៊ាន ទៅទើបខ្ញុំយក ប្រាណ ទៅឆ្លើយអាថ៌សារបញ្ហា ។ ពុំគួរស្ដេចខានទៅ គួរ តែទៅនឹងខ្ញុំភ៉ា នឹងយល់អស់ប្រាជ្ញា ខ្ញុំឆ្លើយអាថ៌នឹងយក្ខ យង់ ។ បើស្ដេចខ្លាចយក្ខពិត កុំទៅជិតបូរស្ដេចគង់ ពី ឆ្ងាយហើយព្រះអង្គ ទតមើលខ្ញុំនឹងយក្សា ។ ឯព្រាហ្មណ៍

បរោហិត ថាបពិត្រព្រះរាជា បើស្តេចនឹងយាត្រា ទៅផង
នោះគាប់ចិត្តខ្ញុំ ។ បើឲ្យតែធនញ្ជ័យ ទៅឯងនែយល់ពុំសម
បើធនញ្ជ័យឆ្លើយពុំ បានឡើយយក្ខវាភោក្តា ។ វាមកនាបូរី
ទោះវាស៊ីទាំងក្សត្រា ស៊ីទាំងរាស្ត្រប្រជា បើព្រះអង្គស្តេចទៅ
ផង ។ វាស៊ីតែធនញ្ជ័យ គឺងក្សត្រនៅនោះឯងហោង ជួបមត់
សន្មតសង វាពុំមកស៊ីរាស្ត្រឡើយ ។ កាលនោះនាងឧត្តឡា
អគ្គជាយាសឹងទូលឆ្លើយ បពិត្រក្សត្រត្រានត្រើយ ស្តេចទៅ
ផងគួរគាប់ណា ។ បើនឹងឲ្យតែពៅ ធនញ្ជ័យទៅគេជៀលថា
ស្តេចខ្លាចភ័យមរណា ហើយបំពោតក្មេងឲ្យទៅ ។ ឆ្លើយតាង
ខ្លួនឯងហើយ ពុំគួរឡើយនឹងរស់នៅ ហេតុនោះខ្ញុំថាទៅ នៅ
គាប់គួរសមសេចក្តី ។ ស្តេចស្តាប់ពាក្យជាយា ទើបក្សត្រាពហ៍
ពោធិ សត្វឡើងលើដំរី បើកបាំងនូវស្វេត្រឆ័ត្រ ។ សេនា
មុខមន្ត្រី ព្រាហ្មណ៍សេដ្ឋីផងប្រើនក្តាត់ ហែហមព្រះមហាក្សត្រ
ស្តេចទៅទៀបជ្រៃយក្សា ។ បញ្ឈប់គង់នៅញ្ញ ដង្គុំព្រៃមួយ
នោះណា ទើបពោធិសត្វមហា បុរសរ័តន៍វិសេសសល់ ។
ស្លៀកសស្តាយផៀងស បរិសុទ្ធល្អល្អះនិម៌ល ព្រះហស្តថ្លៃ

មង្គល កាន់ផ្លិតតូចទើបក្រាបលា ។ ព្រះមហាក្សត្រចេញចរ ដូចកេសររាជសីហា និរភិតនិរភយា ចូលទៅកាន់យក្ខនោះ នែ ។ បង្កើតចិត្តមេត្តា ភាវនាព្រះធម៌ថ្លៃ ទៅដល់ក្រោមព្រះជ្រៃ អ្នកដង្ហោយហៅយក្សា ។ ហេតុតែផលមេត្រី ពង្សពោធិសត្វភាវនា ដើមឡើយយក្ខនោះវា លាក់ខ្លួនពួននៅក្នុងជ្រៃ ។ យក្ខបានឮពាក្យចៅ ធនញ្ជ័យហៅដូច្នេះនែ មានចិត្តស្រឡាញ់ក្រៃ ដូចកូនព្រាត់យូរទើបយល់ ។ យក្ខលាក់ខ្លួនពុំបាន ហេតុតែមានស្នេហាសល់ បង្ហាញខ្លួនឲ្យយល់ យក្ខស្រដីដណ្តឹងថា ។ ចៅឯងតើឈ្មោះអ្វី ចូរស្រដីប្រាប់មកវ៉ា ចៅតើកូននរណា ម្តេចហៅហានពន់ពេកក្រៃ ។ ពោធិសត្វឆ្លើយថា អញនាមាហៅធនញ្ជ័យ កុមារជាកូននៃធនញ្ជ័យសេដ្ឋីឯងហោង ។ យក្ខថាព្រះស្តេចមក មានបើរកអ្វីនេះម្តង អ្នកស្តាប់ហើយឆ្លើយស្នង ថាយក្ខកើយអញនេះណា ។ ជាកូនខុំក្សត្រថ្លៃ ព្រះធនញ្ជ័យធិរាជា ស្តេចត្រាស់លើសិរសា ប្រើអ្នកមកឥឡូវនេះ ។ យក្ខថាស្តេចត្រាស់ប្រើ ចៅមកនេះ តើចៅចេះ អាចិមូលតរធម៌នេះ ហើយឬម្តេចចូរស្រដី ។

អ្នកឆ្លើយថាធម៌នេះ ទោះអញបេះពុំបេះក្តី ព្រះស្តែងដណ្តឹងអ្វី ១ សោតស្តេចត្រាស់ប្រើអញ ។ ក្រែងយល់អញក្មេងលន់ សាប់អញទន់ពិសាឆ្ងាញ់ គួរជាបំណាំមិញ ឲ្យព្រះស្តែងបរិភោ· គ្គ ។ អញពុំដឹងកិច្ចកល់ ឬលោកយល់មានប្រាជ្ញា ប្រើមកដោះប្រស្នា នឹងព្រះស្តែងក៏ពុំដឹង ។ អញជាកូនខ្ញុំលោក ប្រើអញមកឥតដំណឹង សេចក្តីទាំងនេះសឹង ព្រះស្តែងដឹងស្រាប់ហើយណា ។ ទើបយក្ខឆ្លាស់ឆ្លើយទៅ ទោះប្រើហៅមោះមកជា បំណាំអញក្តីណា អញពុំគួរស៊ីហៅឡើយ ហេតុដ្បិតហៅមានសាប់ នោះវាតិបពេកហៅរើយ គឺមោះត្រាស់ប្រើហើយ ចូរហៅចូលមកឲ្យដល់ ។

*បទកាកគតិ* កាលនោះព្រះពង្ស ពូជពោធិវង្ស សាក្យនិម៌ល លុះឮយក្ខហៅ ឈ្មោះកូវទសពល ចរចូលទៅដល់ ទល់ទៀបយក្សា ។ យក្ខយល់ព្រះអង្គ ពន្លកពូជពង្សសា-រពេជ្របេស្តា និរភិតនិរភ័យ ហានក្រែមហិមា ទើបដណ្តឹងថា ម្នាលហៅធនញ្ជ័យ ។ ហៅហានទាំងម្ល៉េះ ចូលមកដល់នេះ ឥតភ្លឹកឡើយនែ ហៅពឹងហេតុអ្វី ពោធិសត្វថ្លៃ បន្ទូលថាហៃ

ម្នាលមហាយក្ស ។ អង្គអញប្រព្រឹត្ត ពឹងដោយសុចរិត ធម៌ទាំងបីប្រា- ការកល់ហេតុនោះ អញឆ្ពោះយាត្រា ចូលមកនេះណា ពឹងហេតុនោះឯង ។ យក្ខយល់ឆ្លាស់ឆ្លើយ អញពុំដឹងឡើយ ប្ដូរចៅសំដែង ទើបព្រះពោធិ- សត្វវិសេសស្ដែង អ្នកនឹងសំដែង ជាបទគាថំ ។ អនិមន្តា យរំគន្តា អបុប្ផយំ បរិភាសិ តំអត្តាទំ នញ្ចបសំ សញ្ចហិតា ។ និទានប្រែងប្រែ បាយបែងបន្លែ បទបាឡីថា គេពុំទាន់ហៅ ឡើងទៅម្ចីម្ចា គេពុំបុច្ឆា ប្រាប់ទៅគេមុន ។ សរសើរអាត្មា ឯងអួតប្រាជ្ញា ថាបេះលើសលន់ នេះហៅហីនលក្ខណ៍ ជួជាតជាមន់- ទិលត្ថ ពេកពន់ អប្បឥតលក្ខណា ។ នន្ទិស្ដែងស្ដាប់ អស់អាថ៌សារសព្ទ គិតក្នុងចិត្តថា ក្មេងតូចប៉ុណ្ណោះ បែងបេះបរបា នេះគឺប្រាជ្ញា នៃបុរសឯង ។ ទើបយក្ខថាហៃ នែចៅធនញ្ជ័យ ប្ដូរចៅសំដែង អាថ៌មូលតរធម៌ សម្មាថ្លាថ្លែង ដំណើរបាយបែង ឲ្យអញស្ដាប់រ៉ា ។ ទើបពោធិសត្វ ពន្លកពុទ្ធវង្ស បើកបន្ទូលថា អញពុំសំដែង ថ្លាថ្លែងឡើយណា យក្ខយល់ឆ្លើយថា ហៃចៅធនញ្ជ័យ ។ បើពុំសំដែង អញស៊ីចៅឯង

ឥឡូវនេះនែ ពោធិសត្វស្តាប់ សារសព្ទស្វូមែ ឆ្លាស់ឆ្លើយ
ថាហៃ ម្នាលមហាយក្ស ។ សព្វដងស៊ីគេ នឹងតើហេតុអ្វី
បូរប្រាប់អញវ៉ា យក្ខថាអញស៊ី នឹងក្តីពីរប្រា- ការកល់ ១ ណា
បូលក្នុងជ្រៃអញ ។ មួយដ្បិតពុំថ្លែង ពុំបេះសំដែង មូលតរ
ធមិមិញ ពោធិស្តាប់ហើយ ឆ្លាសឆ្លើយទៅវិញ ព្រះស្តែងស៊ី
អញ ពុំបានឡើយណា ។ អញពុំមកឯង ព្រោះដ្បិតព្រះ
ស្តែង ហៅអញយាត្រា បរបូលមកដល់ មណ្ឌលនេះណា
មួយសោតធម្មា អញសោតបេះផង ។ យក្ខថាចៅឯង បេះ
ហើយពុំថ្លែង ហេតុដ្បិតនោះហោង អញនឹងស៊ីចៅ ឥឡូវនេះ
ម្តង ពោធិឆ្លើយស្នង ពាក្យពិតទៅថា ។ បាននូវបុគ្គល
សឹងពុំគួរសល់ ហេតុដ្បិតនោះណា អញពុំសំដែង ថ្លាថ្លែង
ធម្មា យក្ខដណ្តឹងថា ហៃចៅធនញ្ជ័យ ។ ពុំគួរតាថាន
នោះវណ្តាប់បាន កុំចៅសង្ស័យ ពុំគួរបុគ្គល តើកល់ម្តេចនែ
អ្នកឆ្លើយថាហៃ ព្រះស្តែងឯងណា ។ នេះហៅបុគ្គល ពុំគួរនឹង
មូល - តរធមិថ្លៃថ្លា ដ្បិតតែងស៊ីគេ ឥតល្ហែឡើយណា ឈាម
ជាប់ឧដ្ឋា ពុំដែលស្ងួតឡើយ ។ រីធមិប្រធាន គួរនឹង

កល្យាណ បុគ្គលឯងហើយ គឺអ្នកសាងផល កុសលជា ត្រើយ ហៃមហាយក្ខកើយ បើនឹងបង់ស្លាប់ ។ ព្រះស្តែងប្រ-ព្រឹត្ត តាមដោយសុចរិត កល្យាណធម៌គាប់ អញនូវទេស្នា ឲ្យជាសណ្តាប់ ព្រះស្តែងក្រឡាប់ តាមពាក្យអញហោង ។ យក្ខយល់ស្តែងស្តាប់ អស់អាថ៌សារស័ព្ទ ឆ្លាស់ឆ្លើយរឹងស្នង ជាអញក្រឡាប់ តាមច្បាប់ធម៌ផង ទើបយក្ខយល់ឃ្លង គំរមិត្រអាស្នា ។ ល្អល្អះប្រពៃ រូបស្រែបហើយនៃ យក្ខ ដណ្តឹងជា ហៃហៅធនញ្ជ័យ ឆាប់វៃម្នីម្នា ឡើងលើអាស្នា ហើយទេសទៅហោង ។ ទើបអ្នកឆ្លើយទៅ ជាអញឈប់នៅ ធៀយព្រួយកន្លង បេញញើសក្អែលក្តៅ ប្តូរទៅរកដង ទឹកង្ហូតហើយហោង អញនឹងទេស្នា ។ យក្ខស្តាប់ហើយ ហោះ រំពេចផ្លេកផ្លោះ ទៅដងគង្គា ដល់អនោតត្ត ស្រះថ្វាត់ម្នីម្នា មកផ្ទួតព្រះមហា បុរសរតន៍ថ្លៃ ។ ឲ្យលាប គ្រឿងគន្ធ ពិតោរទិព្វតន់ ក្លិនក្លែបប្រពៃ ប្រដាប់ភ្ញីផ្កា មាលា ច្រើនក្រៃ រូបស្រែបហើយនៃ អារាធនា ។ ទើបពោធិសត្វ មហាបុរសរតន៍ វិសេសថ្លៃថ្លា ឡើងគង់លើគ្រែ ធម្មាសនា

អ្នកនឹងទេស្នា សណ្ដាប់យក្ខយង់ ។ កាលនោះព្រះបាទធនញ្ជ័យនរនាថ ស្ដេចយល់ព្រះពង្ស ពោធិសត្វថ្លៃ ប្រពៃឡើងគង់ លើគ្រែមង្គល គួរគាប់ថ្លៃថ្លា ។ គិតក្នុងព្រះទ័យថាចៅធនញ្ជ័យ ទូន្មានយក្សា ឲ្យនិរភៀសបង់ ហើយនឹងទេស្នាសម្ដេចក្សត្រា អរតេតថ្លៃងថ្លឹង ។ ព្រះបាទចមចៅ ស្ដេចបរបួលទៅ ទៀបជ្រៃនោះនឹង ព្រះស្នំស្រីង្គារ បរិពារសោតសឹងប្រយោជន៍ហេតុនឹង បង់ស្ដាប់ធម្មា ។ ឯពោធិសត្វ ពន្លកពុទ្ធរតន៍ បន្ទូលទៅថា ហៃមហាយក្ខអើយ អញឆ្លើយប្រស្នាប្អូនបងចិន្ដា ស្ដាប់អាថ៌បាឡី ។ បាណាតិបា- តាបចធនាហារគាមី បសេទារា មុសាវាទី មជ្ជបរិ យោបមទា ។ ថាហៃមហាយក្ខ ទោះនរអ្នក ណាមួយពាធា បាណាតិបាតពិឃាតមនុស្សា ទើបអាស្រ័យនា ចាប់បដិសន្ធិ ។ ប្រឡុងប្រែងស្រែក អំពីបុងសក់ អ្នកនៅទិសទី ឧត្ដរកវោ មេនោះបក្សី អម្រឹតផងក្ដី សារពើសព្វសត្វ ។ ធនហារា កាមេអ្នកណា លួចប្លន់បំបាត់ ប្រវិញ្ញបិទបាំង បំភ្លាំងបំភ្លាត់ទ្រព្យធនបំបាត់ នៃអ្នកនានា ។ បរស្សទារំ អ្នកណាមោហ៍

បាំង លបលួចភរិយា ទាំង ១០ ប្រការ ពុំស្រាលឡើយណា មុសាវាទា កុហកកន្លង ។ ពាក្យពុំសត្យា ភូតភាបរបា ញុះញង់កាប់កង បរិមវាយោ ឥរអ្នកផង ឯណាមួយបោកង មកផឹកសុរា ។ ស្រាអែកស្រាសន់- សើមសិងមានមន់- ទិលទៀងក្ដាត់ណា ស្រាសំបកឈើ ធ្វើនឹងផលា ស្រានោះឯង ណា កុំហាប្រើនឡើយ ។ ទោះមួយដំណួប ស្បូវភ្លាំងតិចតួប ទៅក្នុងមាត់ហើយ សិងមានមន្ទិល ស្មូរិលឥតត្រើយ ពុំប្រ- សើរឡើយ ជាអ្នកវង្វេង ។ បើអ្នកឯណា កាន់កម្មប្រាំប្រ- ការពិតពុំលែង ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ធម៌ថ្លែង ហាអ្នក នោះឯង កាត់ដើមកុសល ។ ក្រំបែលបោះបង់- សៀតនឹងតាំ អង្គ ពុំរួបទៅដល់ ត្រីពិធសម្បត្តិ អរហត្តមគ្គផល នឹង ធ្លាក់ទៅទល់ ទុក្ខនៅនរក ។ ហៃយក្ខព្រះស្ដែង ស្ដាប់អញ នូវថ្លែង ផលបាបដោយមុខ នៃអ្នកណាធ្វើ អំពើពៀរធុក ធ្លាក់ទៅរងទុក្ខ រង់កម្មពុំឃ្លាត ។ យក្ខអើយហាបើ អ្នកណា មួយធ្វើ បាណាតិបាត គឺចិត្តរបឹង យោរខឹងពិឃាត មនុស្សផងជាអាទ៌ សព្វសត្វតិរច្ឆាន ។ អ្នកនោះនឹងទៅ

នរកជ្រាំជ្រៅ ឈ្មោះសញ្ជីពមាន អាយុយឺនវែង ជាក់
ស្តែងប្រមាណ ត្រី ៩ លាន ឆ្នាំមនុស្សនេះណា ។ ទើប
បាន ១ ថ្ងៃ ១ ពន្លឺនៃ នរកនោះណា អាយុយឺនបាន ៥ រយ
ឆ្នាំណា រួបមកកើតជា មនុស្សអាយុខ្លី ។ រូបរាងពុំសម
អាក្រក់ជាល់ នៅនៃព្យាធិ ហើយជាអ្នកខ្លៅ កំឡៀ
អប្រិយ៍ មានមិត្រហើយក្តី សិងប្រាសឃ្លាតឃ្លា ។ មួយ
សោតអ្នកឯ- ណាលួចទ្រព្យគេ ធ្លាក់ទៅកើតនា កាឡ
សូត្រនរក ជាទុក្ខមហិមា អាយុបានជា មួយពាន់ឆ្នាំផង ។
មួយពាន់ឆ្នាំត្រៃ ត្រឹង្សទើប ១ ថ្ងៃ នរកនោះហោង បាប
លួចទ្រព្យគេ វៀរវេរារង ពេកពន់កន្លង ទល់ទុក្ខវេទនា ។
លង់លុះល្ហោះ ពីនរកនោះ ឡើងមកកើតជា មនុស្សហើន
កំសត់ ទុរគតកំព្រា ក្សិណក្សត់ទ្រព្យា សូមទានគេស៊ី ។
រីអ្នកបរទារ កាមកាចស្រើបស្រាល ចិត្តពោរអប្រិយ៍ វង្វេង
គិតខុស ទាំងប្រុសទាំងស្រី សិងធ្លាក់ទៅទី នរកសង្ឃាដ ។
អាយុយឺនបាន ពីរពាន់ឆ្នាំមាន កំណាត់ដោយខ្នាត ឡើង
រការដែក សិងក្អែកសិងត្មាត ហោមចឹកពិឃាត អស់សត្វ

នរក ។ អាយុពីរពាន់ ឆ្នាំទិព្វនៅជាន់ យាមាសួគ៌សុខ ទើបបាន ១ ថ្ងៃ នៅឯនរក លុះរួចពីទុក្ខ ឡើងមកកើតជា ។ មនុស្សនេះវិញហើយ សឹងកើតជាខ្ទើយ ឥតគេបេតនា ពុំនោះសោតកើត កំណើតមកជា ស្រីមានរូបអាក្រក់ក្រៃកន្លង ។ រីអ្នកកុហក ធ្លាក់ទៅនរក រោរពជាម្តង អាយុយឺនស្បាន់ ៤ ពាន់ឆ្នាំហោង វិបាករូបរង ទល់ទុក្ខវេទនា ។ ៤ ពាន់ឆ្នាំនៃ តុស្សិតសួគ៌ថ្លៃ នោះទើបបានជា ១ ថ្ងៃនរក រងទុក្ខកាលណា រួចមកកើតជា មនុស្សលោកនេះនៃ ។ ជាមនុស្សមាៈមាត់ ស្អុយស្អេកពេកក្តាត់ ធ្មេញអាក្រក់ក្រៃ បើនឹងស្រដី ពាក្យអ្វីមួយនៃ អ្នកផងដទៃ ពុំយកឡើយហោង ។ រីអ្នកប្រមឹក ស្រាស្លាប់ទៅផឹក ទឹកទង់ដែងផង នៅតាបនរក ជាទុក្ខកន្លង អាយុនោះហោង ៨ ពាន់ឆ្នាំ ។ ដ្បិតចិត្តកំឡៅ វង្វេងធ្លាក់ទៅ នរកជ្រៅជ្រៃ ពិតពុំមានសុខ ទល់ទុក្ខរងកម្ម ៨ ពាន់ឆ្នាំនិម្មានរតី ។ នោះទើបបានជា ១ ថ្ងៃនៅនា នរកឡើងពីនោះមកកើតជា យក្សាទិដ្ឋី សិង្គ្គុតអប្រិយ៍ កើតជាមនុស្សា ។

សិងឆ្គងជូញោះ មានពាក្យអស្សូរស រឹងរូសមហិមា អ្នកផង
តិះដៀល ដំនៀលនិន្ទា ជាអ្នកមោហា ខ្លៅឥតដំណឹង ។
ហេតុនោះព្រះស្តែង បូរអារម្ភក្រែង ខ្លាចភ័យផ្សេងៗ ប្រូវៀរ
បាបកម្ម ទាំង៥ដែលដឹង កាន់តាមដំណឹង ដំណើរធម៌ផង ។
វីបាបទាំង ៥ វៀរវេរាកម្ម អង្គឲ្យសោហ្មង នេះហៅមន្ទិល
នានាំឲ្យឆ្គង បូលព្រះស្តែងបង បិត្តបាំរក្សា ។ បាំសីលទាំង៥
បំបាត់បាបកម្ម នេះហោងហៅជា ឥតមន្ទិលក្រៃ កុំបីសង្កា
បានផលមួយអា- នន្តនាំឲ្យបាន ។ ដួបដល់ត្រីពិធ សម្បត្តិ
សួគ៌បើត លុងលុះនិព្វាន តាមដោយគន្លង ប្រាជ្ញផងសោត
មាន ព្រះពុទ្ធប្រធាន ស្តេចត្រាស់ទេស្នា ។ ទុកជាសណ្តាប់
ឲ្យកាន់ត្រង់ត្រាប់ តាមព្រះធម្មា បើព្រះស្តែងបង់ បំណង់ប្រាថ្នា
សម្បត្តិនានា ពុំគួរបង់បាន ។ បើព្រះស្តែងបង់ ប្រាថ្នាឆ្ពោះត្រង់
សម្បត្តិនិព្វាន តាមដោយព្រះធម៌ សម្មាប្រធាន គាប់គួរបង់
បាន គួរបីប្រាថ្នា ។ វីនន្ទិយក្ខ ស្តាប់ធម៌បាំជាក់ មានចិត្ត
សទ្ធា នឹងធម៌ពោធិ សត្វវិសេសា ក្រួញក្រាបវន្ទា ពង្សពោធិ
សត្វ ។ ឋាឥឡូវខ្ញុំ ប្រាថ្នាសូមសុំ សីល៥នេះប្រាត់ ឥតមន្ទិល

ក្រៃ ភាភ័យបំបាត់ បាបផងខ្វាយខ្វាត់ សូមម្ចាស់ករុណា ។
ព្រះពង្សពោធី ស្ដាប់ពាក្យនន្ទី យក្ខហើយអ្នកថា បើព្រះស្ដែង
ប៉ង បំណងប្រាជ្ញា សុំសីលរក្សា បំបាត់បាបប្រាណ ។
ប្ដូរព្រះស្ដែងអង់- គុយឧកុដិថ្លង់ ស្មារតីស្មាទាន យកសីល
ទាំង ៥ បង់ចាំទុកប្រាណ យក្ខស្ដាប់ហើយមាន ចិត្តត្រេក
អរក្រៃ ។ ក្រញូក្រាបវន្ទា បំផងហើយណា ឧកុដិកលើកដៃ
ប្រណម្យពោធិ- សត្វវិសេសថ្លៃ ស្រាប់ស្រេចហើយនៃ
សូមសុំសីលថា ។ បណ្ឌិតសី- លំយាចាមិ បពិត្រអ្នកមហា
បុរសរ័តន៍ខ្ញុំ សូមសុំសីលា សូមម្ចាស់ករុណា ឲ្យទានខ្ញុំ
ហោង ។ ទើបពោធិសត្វ ពន្លកពុទ្ធរ័តន៍ លើសលែង
លោកផង ឲ្យសីលទាំង ៥ យក្ខចាំរួសរង ទទួលត្រេកត្រង
ជាអ្នកសីលខ្ជាប់ ។ ឯអស់ទេពតា នៅព្រៃនោះណា បន្លឺ
សូរស័ព្ទ ឲ្យសាធុការ ខ្ញូរខ្ញារអឹងអាប់ ស្ញើរភ្លូកក្រឡាប់ ទាំង
ព្រៃព្រឹក្សា ។ ឯអង្គនន្ទី យក្ខយកសីលវិ- សេសស្រេច
ហើយណា ចង់ស្ដាប់ធម៌ទៀត ខំឆ្លៀតសូមអា- រាធនាថា
បពិត្រអ្នកមាន ។ ប្រាជ្ញាច្បង់ច្បាស់ សូមទានអម្ចាស់ សំដែង

និទាន អត្ថមូលតរធម៌ សមាឲ្យបាន ពិស្ដារឲ្យទាន ខ្ញុំ
ស្ដាប់ទៀតវ៉ា ។ អ្នកស្ដាប់ហើយថ្លែង ហាព្នោះព្រះស្ដែង
អញ្ជើញព្រះមហា ក្សត្របួលមកធាប់ ឲ្យស្ដាប់ធម្មា អញ្ញ
នឹងទេស្នា ឥឡូវនេះនែ ។ យក្ខស្ដាប់ហើយទៅ ទូលក្សត្រ
បមហៅ ហាដ្បិតធនញ្ជ័យ កុមារនឹងថ្លែង សំដែងអត្ថនៃ មូល
តរធម៌ថ្លៃ អញ្ជើញស្ដេចទៅ ។ កាលនោះព្រះបាទ ធនញ្ជ័យ
ធិរាជ នរនាថបមហៅ ជ្រាបជាយក្ខយង់ បោះបង់ឃោរឃៅ
ទើបស្ដេចបួលទៅ ប្រាប់មុខមន្ត្រី ។ នៅអស់បរិពារ ព្រះស្នំ
ស្រីង្គារ ហែព្រះបក្រី ស្ដេចទៅគង់ពិត ទៀបជិតពោធិ
សត្វទើបនន្ទី យក្ខយង់ឃោស្នា ។ អញ្ជើញទេពារក្ខ ទេពតា
សំណាក់ សព្វព្រៃព្រឹក្សា សព្វប្រកជ្រលង ដោយដង
អាត្មា ស្ទឹងបឹងគង្គា បរបួលមកស្ដាប់ ។ មូលតរធម៌ថ្លៃ
ដ្បិតហៅធនញ្ជ័យ ប្រាជ្ញាឆ្លៀងឆាប់ អ្នកនឹងទេស្នា ឲ្យជា
សណ្ដាប់ ទេពតាឲ្យសព្វ ពាក្យយក្ខឃោស្នា ។ ដូច្នោះ
ហើយនែ មានបិត្តអរក្រៃ មកជុំគ្នាហា ទាមូលតរធម៌ សម្មា
ថ្លៃថ្លា តែឈ្មោះនោះណា ពុំដែលពុំមាន ។ ពីមុនមកក្ដូវ

ទើបតែឥឡូវ នេះឯងយើងបាន ឮធម៌ប្រាជ្ញប្រែ បន្លែនិទាន
គួរយើងទៅថ្កាន ស្តាប់ធម៌ទេស្នា ។ ទេពតាជំនុំ ហើយ
ចូលមកជុំ បង្ហាញអង្គា ឲ្យយល់ជាក់ច្បាស់ ទើបអស់ទេពតា
អារាធនា ធម៌ពោធិសត្វ ។ ទើបពង្សពោធិ- សត្វសាង
បារមី អ្នកឲ្យសម្គាត់ ពុំឲ្យស្រដី ពាក្យអ្វីប្រើនម៉ាត់ ទើប
ពោធិសត្វ បើកបន្ទូលថា ។ ហៃយក្ខព្រះស្តែង រឺធម៌នេះ
ឯង អង្គីទេពតា តាបសយក្ខយង់ ភ្លូជង្គគ្រុជា សំដែងទេស្នា
ធម៌នេះឡើយនែ ។ រឺធម៌គឺព្រះ មានបុណ្យជាម្ចាស់ សម្ពុទ្ធ
ញាណញៀយ ព្រះបច្ចេកពុទ្ធ អគ្គសាវកប្រពៃ ថ្លែងធម៌នេះនៃ
ប្រោសសព្វសត្វផង ។ បូរព្រះស្តែងស្តាប់ អស់អាបិត្រែង
ត្រាប់ រួសរៀនចាំបង ទុកក្នុងចិន្តា កាលគ្រានេះម្តង ។
ទើបអ្នកសាសង ស្សូត្រជាគាថា ។ ទិដ្ឋិលោភ ឧទ្ធច្ចទោស
ថីនមានា កង្ខាមោហា លោកនាសា ទុសចិត្តា- គំកិ-
លេសេ ។



ចេតិយបុរាណ ឈ្មោះចេតិយពុប៉យ នៅឆ្នេរទន្លេឥរវតី ស្ដេចប៊ុនសៅវតី សាងកាល ព. ស. ៧៨៦ នៅស្រុកបាគន ភូមា ។

# ច្បាប់កូនចៅ

របស់ក្រម ង៉ុយ

៙ កូនចៅចូរចាំស្តាប់ អាពុកប្រាប់ប្រៀនប្រដៅ រូបល្អស
សាប់ក្រៅ កុំឲ្យខ្មៅចិត្តខាងក្នុង ។ កូនចាំបង់ទុកចុះ ជាតិ
ជាមនុស្សមិនខុសពង្ស រូបក្រៅយ៉ាងខ្មៅយង់ ចិត្តខាងក្នុងស
ល្អស្អាត ។ ពាក្យពិតគិតឧបមា កុំត្រាប់ខ្លាឡៀនត្រាប់ត្មាត
សត្វក្អែកខ្មៅហួសខ្នាត ឫកខូចខាតនោះកុំត្រាប់ ។ មើលឫក
សេកលលក ល្អមរៀនយកទុកដម្រាប់ ជាតិផ្តៃត្រកូលអាប់
គួរកុំត្រាប់ឲ្យត្រាប់ស្វា ។ កុំត្រាប់មាន់មានបាប ត្រាប់ពុត
បាបបែកប្រាជ្ញា កុំត្រាប់ខ្លែងឫស្យ៉ា ត្រាប់ពង្សាត្រកូលហង្ស ។
កុំត្រាប់ពុតកង្កែប ឲ្យត្រាប់បែបសត្វកន្លង់ កុំត្រាប់ពុតប្រម៉ង់
ផ្លង់ត្រាប់ពុតសត្វសារិកា ។ កូនចៅចូរចាំស្តាប់ អាពុក
ប្រាប់ប្រែបញ្ញា មនុស្សល្អដូចទេវតា ចិត្តឫស្យាអន្តរក្ត ។
ចិត្តក្នុងពាល់រលោក ផ្អែមតែពាក្យនឹងសំដី កូនចៅទាំងប្រុស
ស្រី កុំបីត្រាប់មនុស្សយ៉ាងហ្នឹង ។ ត្រាប់មនុស្សខ្មៅកក្រើត
ខាងក្នុងចិត្តល្អសភ្លឹង អ្នកស្រែកស្រណុកពឹង រឹងតែពាក្យសំដី
ក្រៅ ។ មានការខឹងដោយយ៉ាង ស្តីក្អេងក្អាងមាត់លឡៅ
ជេរវ៉ែស្តីប្រដៅ ជេរហើយហៅឲ្យស៊ីបុក ។ អ្នកម្យ៉ាងសទាំង

អស់ គ្មានខ្មៅសោះឥតតែសុខ យ៉ាងហ្នឹងប្ដូរប៉ាំទុក ប្អូនប្រិ
ស្រុកមិនទាន់មាន ។ និយាយរឿងឬកខ្លា សុំអាហារតាមចិត្ត
ឃ្លាន ខាំគេទាំងបំពាន ហ៊ានមិនថាគេតូចធំ ។ សត្វត្មាត
រូបអាក្រក់ បើសុំឡក់រកត្រីនុំ អត់ស៊ីសំកុកទំ ឮក្អែកយំស្រាប់
តែអរ ។ អាដែងសត្វសុនខ ឬកអាក្រក់ដេកតែក្រ ឃើញគ្នា
ទោះខ្មៅស មិនដែលអរស្រាប់តែខឹង ។ បេះមួយតែស្អប់គ្នា
ត្រង់ខូចជាមិនទាន់ដឹង ឃើញឆ្កែកន្ទុយឆ្កឹង ប្រឹងដេញឆ្កិត
ប្រខាំឈ្លោះ ។ កំណើតសត្វពានរ អង្គុយឈរដេកទំខ្ពស់
ដៃជើងលោតឡើងចុះ រស់នឹងស្លឹកឈើផ្លែឈើ ។ សត្វក្អែក
ចិត្តចោរខ្លាំង លួចត្រីអាំងគេទុកទើ ត្រីខរភ្យួរខាងលើ ចឹក
បើករើលួចលបឆក់ ។ ពងមាន់ស៊ីមិនកើត ចេញចូលអើត
ភ្នែកស្លើតស្លក់ ចិត្តខ្លាំងខ្មៅអាក្រក់ ឆក់ទៅចោលក្រៅរបង ។
លលកសេកបក្សី ស៊ីចំណីជុំគឹកកង មានភ័យផ្អើលម្ដងៗ ហើរ
ត្រសងមិនឈ្លោះគ្នា ។ មាន់ព្រៃនឹងមាន់ស្រុក ដេកសំកុក
មិនចេះល្ហា ចេះល្ហាវិចាំវេលា ជុះបង្កៀរដាក់បង្គង ។ សត្វ
ចាបសឹងចេះគិត ដឹងថាជិតថ្ងៃខែពង ពាំស្មៅម្ដងមួយទង

បេះផ្ការផ្គងធ្វើសម្បក · ប្រម៉ង់ខ្លែងហោរប្លន់ ឆាបកូនមាន់កណ្ដាលស្រែក មេមាន់យំលំឱក ហែកបញ្ចុករសកូនឯង ។ កំណើតហង្សបក្សី មានរស្មីល្អបំពែង ក្បូរក្បាច់រំលេចខែង គេតែងធ្វើរូបតាងទុក ។ មានវត្ថុមានព្រះអង្គ មានរាជហង្ស នៅខាងមុខ មិនដែលបែកបាក់ពុក ទុកដម្កើងលើដងទង់ ។ បក្សីសត្វសារិកា មានប្រាជ្ញាមិនសូវល្ងង់ សម្បុរសោតខ្មៅយង់ ស្ដេចតែងទ្រង់ប្រោសប្រណី ។ មានរឿងក្នុងមហោសថ វែង បំផុតមិនមែនខ្លី ឈប់ស្លេះរឿងបក្សី បែងសេចក្ដីរឿងកង្កែប ។ ដេកនៅផ្ដាប់គល់ឈូក ខ្ទង់ស្រកូកសម្ងំអែប ផ្កាឈូកល្អអស់បែប មិនដឹងក្លែបក្លិនយ៉ាងណា ។ កន្លង់សត្វបក្សី នៅក្នុងព្រៃដែនបព្វតា ស្វែងហើររកអាហារ ជញ្ជក់ផ្កាឈូកយកបាន ។ អធិប្បាយឱ្យប្រូហែ ជាតិជាខ្មែរទាំងប៉ុន្មាន មានឈ្មោះខ្ពស់ថ្កើងថ្កាន ញាតិសន្ដានធំព្រះពុទ្ធ ។ ប្រពៃពួជព្រះអង្គ បួសជាសង្ឃពង្សកុលបុត្រ កាន់សីលមិនបរិសុទ្ធ បៀរសគេបផុតផ្លូវទិញាន ។ នេះឯងមនុស្សកង្កែប មាត់ប្រវែបបែបមិនឃ្លាន អត់ចិត្តឥតវិញ្ញាណ មិនមានដឹងរសក្លិនផ្កា ។

អ្នកខ្លះគ្មានជម្រែះ មិនចង់ចេះដឹងអក្ខរា មិនស្រេចនឹងធម៌អាថ៌ មានឧបមាដូចកង្កែប ។ អ្នកម្យ៉ាងមិនបួសសោះ ចិត្តជឿស្មោះអស់បទបែប បានភព់ប្រសព្វសេព ឯចឧបសីលដូចកន្លង់ ។ ប្រដូចមនុស្សនឹងសត្វ ផ្លូវបរមត្ថកាត់ជម្រង់ ដម្រាប់ច្បាប់ព្រះអង្គ កុំលះបង់ព្រះសាសនា ។ ជាតិខ្មែរចិត្តខ្មៅខ្វប មានប្រដូចពូជក្រូបធ្មារ មិនដែលធ្លាញ់ពីសា ដូរយ៉ាងណាដូរទាល់ងាប់ ។ មនុស្សម្យ៉ាងដូចនគោង ទ្វីដំបូងប្រសើរគាប់ ចាស់ស្វិតសាញស្រទាប់ គេលែងរាប់ស្អប់លែងស្ល ។ ស្វាយទ្វីចាស់ដូរដែរ ទុំទៅប្រែជាផ្អែមល្អ ជាតិខ្មែរចិត្តខ្មៅស កម្របានបែបដូចស្វាយ ។ ច្រើនដូចក្រូបនគោង ពូជត្នោតដូងប្រយោជន៍ឆ្ងាយ ជម្ពូទ្វីបយើងអាយមនុស្សទាំងឡាយត្រាប់មិនបាន ។ កាលគ្រាប់នៅកំរោល គេបោះចោលមិនរាប់អាន ដើកដុះតាមកំសាន្ត ធំប៉ុន្មានប្រាក់ប៉ុណ្ណឹង ។ ប្រយោជន៍ជាតិដូងត្នោត មនុស្សណាឆោតគិតមិនដឹង គេកាប់មិនបេះខ្ទឹង ប្រឹងតែលូតលាស់ជាថ្មី ។ មិនឥតអំពើសោះ ត្រូវទាំងអស់ការខាងខ្លី ខ្ពស់ឃ្លាតផុតពីដី

ស្លឹកខ្ចីៗគេធ្វើផ្លិត ។ ត្បាញស្មុគ្គបាក់ក្រតិ៍ គេបេះផ្សំប្រើ
តាមបិត្ត អ្នកណាប្រាជ្ញាល្អិត ប្រើហើយប្រិតបានប្រាក់ពាន់ ។
ឆាងតូបត្រូវបំណាង ទាល់ម្ដងៗធ្វើបន់ស្រន់ រកណោះណោះ
មិនទាន់ ធ្វើរួសរាន់តាមប្រញាប់ ។ ខាងពោះធ្វើរបង ប៉ែក
ខាងខ្នងបងកណ្ដាប់ កណ្ដាលហាលថ្ងៃស្លាប់ ក្របែលកាប់
ដុតដាំបាយ ។ ត្នោតម្ដើមលៃលុយកាក់ បូកទាំងប្រាក់
១ ពាន់ប្លាយ មនុស្សរស់រាល់រូបកាយ បានប្រាក់ចាយពី
ដើមត្នោត ។ ស្រទាប់ជាងនឹងស្លឹក ផ្កាមានទឹកធ្វើស្ករប៉ោត
ស្ករផែនហ្មឺនសែនកោដិ ក្បាបរាសោតគេដោតត្រី ។ ចាស់
ល្មមឡៀលក់ដូរ ស្លក្រក្ងូរផ្លែខ្ចីៗ ផ្លែទុំជ្រុះដល់ដី មនុស្ស
ប្រុសស្រីរើសធ្វើនំ ។ ពោលគ្រាប់ដុះកំពឹង ជាប់ល្បួងក្មេង
កុំឲ្យឃិំ ផក់ចាស់សរសៃធំ ចងប្រមុំធ្វើជាប្រែង ។ ផក់
ល្អិតសរសៃខ្ចី វេញខ្សែខ្លីវេញខ្សែវែង ប្រយោជន៍ច្រើនកន្លែង
អ្នកណាឯងអាចត្រាប់បាន ។ ជាតិខ្មែរបិត្តខ្មៅស អាក្រក់
ល្អមានគ្រប់ប្រាណ បើចង់សុខក្សេមក្សាន្ត មើលលំអានពុត
ដើមស្វាយ ។ កុំត្រាប់នោងក្រូប ក្រែងមិនរួបបតុរាបាយ

ដូងះត្នាតប្រយោជន៍ឆ្ងាយ  មនុស្សទាំងឡាយពិបាកត្រាប់ ។
លលកសេកកន្លង់  គួរផ្ចិតផ្ចង់យកជាច្បាប់  សត្វណាកិរិយា
អាប់  ខុសសណ្ដាប់បៀសឲ្យឆ្ងាយ ។  ពាក្យពិតពោល
ប្រដូច  សត្វធំតូចបែបបរិយាយ  រំពឹងគិតក្នុងកាយ  សត្វ
ទាំងឡាយចិត្តខុសគ្នា ។  សត្វស្វាប្រាជ្ញវៃ  មានទុក្ខភ័យ
រាល់វេលា  គំនិតចិត្តល្អជា  ទ្រាំក្ដៅល្វាទាំងថ្ងៃយប់ ។  មាន
ឆោតជាទំនៀម  ដេកលក់ស្ងៀមពីព្រលប់  បុះដីបីដងម្យប់
ស្អាបគល់គ្រប់ក្រែងរលំ  មែកតូចមិនខ្លាចបាក់  អធ្រាត្រភ្ញាក់
ផ្អើលស្រែកយំ  នេះឯងហៅឆោតធំ  មែកតូចធំជុំគ្នាដេក ។
អាដែងតាដេរីប  ជើងតូចតិចអាងធាក់មេឃ  ឆោតហើយ
ព្រហើនពេក  ដេកតែផ្ងារមិនដែលផ្កាប់ ។  អាដែងត្រៀល
បក្សី  ខ្លាចផែនដីផ្អៀងក្រឡាប់  លបឈានមិនហ៊ានឆាប់
ខ្លាចដីផ្កាប់លើកជើងម្ខាង ។  ជន្លេនសត្វតូចប្រែត  ស៊ីមិន
ឆ្អែតតាមសំណាង  ផែនដីធំអស់យ៉ាង  ស៊ីខាងៗខ្លាចអស់ដី ។
កំណើតសត្វទាំងបួន  ឆោតផុងខ្លួនប្រាជ្ញខ្លី  ជាតិមនុស្សទាំង
ប្រុសស្រី  កុំបីឆោតជ្រុលគំនិត ។  រាល់រូបទាំងស្រីប្រុស

បង់តែរស់ជន្មជីវិត គួរជឿគម្ពីរពិត មិនគួរគិតជឿអាគម ។ មិនជឿធម៌ព្រះពុទ្ធ ជឿមេមត់ខ្មោចស្មោះផ្ដំ ខ្សែកអារក្ខធំ បងព័ន្ធរុំរាំងផ្លូវស្លាប់ ។ ជឿណាស់តែខ្សែក ត្រង់ព្រះធម៌ មិនខ្វល់ស្ដាប់ ព្រះកាលមកតឿនប្រាប់ ព្រមប្រញាប់ទាំងបំណង ។ អាគមខ្សែកស្រាប់ ម្ដេចមិនចាប់ព្រះកាលបង អារក្ខស្មោះផ្ដំផង ឆ្លងមិនរួចអកុសលកម្ម ។ នេះឯងត្រដេររឹប មាត់តូចតិចដេកផ្ងារយ៉ាង ជើងតូចដូចសម្រាម ហាំជាក់មេឃយករួចខ្លួន ។ មេឃណាបេះលំ បំផុតធំគ្របទ្វីបបួន ពពកបក់ប្រពួន ព្រះពាយជួនមិនផុតមេឃ ។ ជន្លេនខ្លាចអស់ដី មនុស្សត្រិរិយកំណាញ់ពេក មានទ្រព្យប្រើនអនេក ដេកតែមើលមិនធ្វើទាន ។ ស៊ីសោតមិនពេញពោះ ឲ្យតែរស់សោះតែឃ្លាន សន្សំទុកធ្វើមាន មិនហ៊ានទិញស៊ីស្ដាយប្រាក់ ។ សត្វក្រៀលឆោតភ្លើ ៗ ទំមែកឈើមិនខ្លាចបាក់ ដើរដីជើងម្ខាងដាក់ ម្ខាងលើកលាក់ខ្លាចផ្កាប់ដី ។ នេះឯងហៅឆោតព្រើល ម្ដេចមិនមើលសត្វដំរី ធំលើសសត្វអ្វី ៗ ដើរលើដីមិនក្រឡាប់ ។ ដូចចាស់បុរាណមុន លោកមាន

គុណច្រើនពេះប្បាប់ ធ្វើការមិនប្រញាប់ រៀបរណ្ដាប់មិន ដែលខាន ។ ចាស់ធ្វើគួរយើងកោត ថាចាស់ឆោតថាមិនបាន បើតាមបែបលំអាន សាប់សន្ដានតឹងសត្វក្រៀល ។ ធ្វើការប្ដីប្រពន្ធ រៀបភោជនពេញពាសវាល អុបភ្លើងភ្លឺរន្ទាល ថ្ងៃរសៀលក្រុងពលី ។ រាប់រៀបរឿងភ័ស្ដុភារ ថ្វាយបូជាអស់ផ្កាភ្ញី នាងហ៊ឹងព្រះធរណី មានឫទ្ធីសោយបំណី ។ បំណែកបំណាំចាស់ ប្រាកដណាស់មានរាសី ទឹមគោទឹមក្របី ភ្ជួររាស់ដីម្ដេចមិនសុំ ។ រៀបការប្ដីប្រពន្ធ ដីមិនធ្ងន់មិនប៉ូរយំ ភ្ជួររាស់ស្រែតូចធំ ស្មៅរលំរលើងអស់ ។ មិនដែលក្រុងពលី ម្ចាស់ធរណីមិនឥតសោះ ភ្ជួរហើយមានថែមរាស់ ដូចគេរាស់ល្មមសង្ស័យ ។ ទោះភ្ជួរបំការស្រែ ពីរបីខែធ្វើរាល់ថ្ងៃ កាប់គាស់មិនសំបៃ មិនឲ្យថ្លៃដីមិនខឹង ។ អ្នកខ្លះទាយតាមបេះ ថាដីនេះរកស៊ីតឹង បើទ្រាំនៅត្រង់ណាំង ប្រឹងទាល់ងាប់ជាប់តែក្រ ។ បើតាមព្រះពុទ្ធដីកា មនុស្សឫស្យាចិត្តមិនល្អ កំណាញ់ច្រើនដំណា ក្រពីព្រោះមិនធ្វើទាន ។ អ្នកចិត្តល្អជ្រះថ្លា នៅត្រង់ណាបេះតែមាន មិន

ដែលខ្សត់អត់ឃ្លាន ព្រោះផលទានពីជាតិមុន ។ អ្នកខ្លះទុក្ខ
វេទនា មានរោគារពាធគ្រុន ស្លាប់កូនស្លាប់ប្រពន្ធ ហោរគួរ
គន់ថាគ្រោះថ្នាក់ ។ មានទោសពីព្រោះដី គំនិតខ្លីឆោត
ជឿជាក់ ឆោតបង់ទាំងលុយកាក់ រើលើកដាក់រកដីល្អ ។
ដីនោះរស់រុះរើ មានឫសឈើនឹងក្រួសុប្ម បើគិតតាមច្បាប់
ធម៌ ស្លាប់នឹងក្រអកុសលកម្ម ។ បាណាធ្វើឯរាប សាង
ផ្លូវបាប ៗ ឲ្យផល ជាតិនេះពៀរមកផ្តល់ ខ្យល់មិនស្រួល
ទទួលកម្ម ។ ហោរមួយថាទាស់ដី ហោរពីរបីថាគ្រោះឆ្នាំ
អ្នកបេះអួតអាងបាំ វេរា ៥ បំភ្លេចចោល ។ ជឿហើយនៅ
សង្ស័យ ដូចល្ងក់ដៃចាប់ស្រមោល ឆោតឆៅខ្លៅកំរោល
ជឿតែលោលតេងតាងចិត្ត ។ ដីដេកមិនកំរើក មិនបេះបើក
មិនបេះបិទ មិនខឹងមិនអាណិត ជាហេតុបិតមនុស្សគួរនៅ ។
ផ្កាប់ផ្ងារដោយសារភ្លូរ ស្អឹងបឹងបួរមានរាក់ជ្រៅ អ្នកឆ្លងពឹង
ទូកទៅ អ្នកសំពៅពឹងសមុទ្រ ។ អ្នកប្រាជ្ញពឹងគម្ពីរ អ្នក
រកស៊ីពឹងពាក្យផុត ខ្លាចស្លាប់ភេទក៍ស្លូត រត់ស្លូតស្លក់ទៅរក
ក្បួន ។ កង្កែបហើងគីង្គក់ បានទឹកប៉ុកថាមាំមួន ក្អេង

ក្អាងមិនរេះពួន នឹកថាខ្លួនបានសាន្តសុខ ។ កង្កែបពឹងត្រពាំង មានព្រៃបាំងមានល្បាប់ផុក ទឹកជ្រៅលំនៅស្តុក ស្រួលស្រណុកចិត្តគ្រាន់បើ ។ តាំងឫកថាខ្លួនក្អេង លោតបុះឡើងស្រួលដេកដើរ គិតថាគាប់ប្រសើរ មិនទាន់ស្មើនឹងសមុទ្រ ។ កង្កែបបែបទាំងបួន អួតរាល់ខ្លួនមិនតក់ស្លុត បើតាមពាក្យព្រះពុទ្ធ គេបមិនផុតគឺផលកម្ម ។ ទឹកជ្រៅតែងមានជ្រោះ មានសត្វពស់វាពួនចាំ កង្កែបឯបទ្រោលត្រាំ ពស់លបខាំលេបមិនលែង ។ ជាតិមនុស្សដូចកង្កែប មានច្រើនបែបផ្ទះសម្បែង អ្នកម្យ៉ាងខ្ទមពីរល្វែង នឹកថាឯងអស់ប៉ុណ្ណឹង ។ អ្នកម្យ៉ាងផ្ទះគ្រឿងឈើ ប្រក់ស្លឹកលើដេកសម្លឹង បេញឫកឲ្យគេដឹង ប្រឹងមើលងាយអ្នកនៅខ្ទម ។ អ្នកម្យ៉ាងអាងផ្ទះក្បឿង រុងរឿងនឹងរូបឆោម របស់ទ្រព្យមានព្រម នៅមិនល្មមស្មើផ្ទះថ្ម ។ ព្រះកាលកេណ្ឌកម្មការ មិនកោតខ្លាចអ្នកមានក្រ បើសីលបរិសុទ្ធល្អ ទើបអង្វរព្រះកាលបាន ។

ព្រះកាលដឹងប្រាកដ ដល់កំណត់មិនព្រមខាន មហាជន ទាំងប៉ុន្មាន គួរសន្និដ្ឋានប្ដូលចិត្តចុះ ។ ប្រិតប្រុងក្នុងគំនិត កុំប្រព្រឹត្តអំពើខុស រាល់រូបទាំងស្រីប្រុស គិតឲ្យអស់កុំឲ្យ សល់ ។ ផ្ទះឈើនឹងផ្ទះថ្ម អាក្រក់ល្អស្រេចនូវផល ជាតិ មុនធ្វើបុណ្យដល់ កុសលប្រានបានផ្ទះថ្ម ។ អ្នកខ្វាបស្អប់ អ្នកបារិន ជាតិអ្នកមានស្អប់អ្នកក្រ អាក្រក់ស្អប់អ្នកល្អ ព្រោះ គេឈ្ងុធរាប់អាន ។ អ្នកខ្វបនឹងអ្នកជា នៅជិតគ្នាមិនសូវ បាន អ្នកកាន់ច្បាប់បូរាណ មិនខានស្អប់ទំនើបថ្មី ។ អ្នក ស្លូតស្អប់អ្នកកាច ឬកអ្នកប្រាជ្ញស្ងៀមមិនស្ដី ឬកមនុស្ស កាឡកិណី ស្អប់សិរីមិនចង់ជិត ។ អ្នកស្ងួតបិត្តសូរជន បាយទ្រព្យធនបាយក្នុងគិត ឲ្យខានឲ្យមិនពិត គំនិតនៅក្នុង កំណាញ់ ។ កំណើតបិត្តតិរិយ ស៊ីបំណាំមិនសូវឆ្ងាញ់ ស៊ី ហើយតែគិតកាញ់ គ្មានសម្លាញ់នឹងឈ្មោះណា បើគេស្ងួត ដូចខ្លួន ទឹងគុំគួនជេរផ្ដាសា ខ្លួនឯងស្ងួតឫស្យា មានគេបា មិនសុខចិត្ត ។ កូនចៅជឿតាំបុះ ធ្វើជាប្រុសឲ្យប្រុងប្រិត

ពិចារណាឲ្យល្អិត ទុកជាក្រឹត្យក្រមប្រដៅ ។ ប្រដូចមនុស្ស នឹងសត្វ បែបបរមត្ថចិត្តសខ្មៅ ស្ទួតកាបប្រាជ្ញនឹងខ្លៅ ចូរ កូនចៅពិចារណា ។ កើតមកមានពូជពង្ស កុំល្ងឹតល្ងង់លង់ ប្រាជ្ញា ខំរៀនខំសិក្សា ទុកជាការប្រយោជន៍ខ្លួន ។ រំពឹង ប្រឡងធី ពាក្យគម្ពីរនឹងពាក្យក្បួន បេះបាំឲ្យមាំមួន ប្អូនប្អូ ចប់ម្ល៉េះហើយហោង ។

# រឿងស្តេចក្រុងចិន

រឿងស្តេចក្រានចិន

មានពាស់ទំនិយាយមួយយ៉ាងទៀតថា លោកសម្តេចព្រះសុគន្ធ តែពុំដឹងជារាជសករាជស្តេចណាទេ ថាលោកចិញ្ចឹមឆ្កែឈ្មោល ១ អំពីតូច លុះឆ្កែនោះធំឡើង មានគំនិតមារយាទណាស់ លោកព្រះសុគន្ធមានព្រះទ័យអាណិតឆ្កែនោះដូចជាកូនសិស្សសំឡាញ់ ដ្បិតឆ្កែនោះបេះដូចជាមនុស្ស បើលោកនិមន្តទៅស្វូត្រមន្តក្តី ទៅឆាន់ផ្ទះឧបាសកទាយកឯណាក្តី ឬ ១ ទៅបុណ្យទានឯណា ៗ ក្តី លោកឲ្យឆ្កែនោះឯងពាំបង់យាមទៅ ប្ដូនកាលលោកឲ្យពាំសម្ពត់ដូតកន្សែងជូតដៃបានទាំងអស់ បើលោកឲ្យឆ្កែនោះពាំទៅហើយ មានសាមណេរភិក្ខុកូនសិស្សឧបាសកឯណា មកបញ្ចោតយកពីឆ្កែនោះមិនបានឡើយ បើលោកប្រើឲ្យពាំហើយដល់ទៅកន្លែងឈប់ហើយ ឆ្កែនោះយករបស់នោះទៅប្រគេនវិញ ។ ១ ទៀតបើភិក្ខុសាមណេរប្រើឲ្យពាំរបស់អ្វី ៗ ក្តីបានដូចគ្នាទាំងអស់ មិនដែលយករបស់នោះទៅចោលឲ្យបាត់ឡើយ · បើការអ្វីដែលលោកធ្លាប់ប្រើ ធ្លាប់តាមទៅហៅភិក្ខុសាមណេរកូនសិស្សឯណា

លោកមិនបានទៅហៅ លោកប្រើតែឆ្កែនោះទៅហៅក៏បាន ឯឆ្កែនោះបើលោកប្រើទៅហើយ វាទៅដល់មាត់ជណ្តើរកុដិនោះ វាព្រុះវាលូហៅកូនសិស្សនោះៗ ដឹងថាលោកគ្រូប្រើឆ្កែមកហៅ ក៏ទៅតាមឆ្កែនោះ ឆ្កែនោះចេះដឹងដូចជាមនុស្ស តែមិនចេះស្តី អស់ភិក្ខុសាមណេរកូនសិស្សស្រឡាញ់គ្រប់គ្នា បើចង់ប្រើឆ្កែនោះនាំរបស់អ្វីទៅណាក៏បាន ឆ្កែនោះឯងឧស្សាហ៍បំរើលោកសង្ឃក្នុងវត្តនោះ មិនឲ្យអន់ចិត្ត លុះនៅយូរទៅឆ្កែនោះស្លាប់ បានទៅកើតជាកូនស្តេចស្រុកចិន ។ ឯលោកសម្តេចព្រះសុគន្ធ ជ្រាបថាឆ្កែនោះស្លាប់ហើយ លោកក៏មានព្រះទ័យអាណិតឆ្កែនោះណាស់ លោករៀបធ្វើបុណ្យឲ្យទានរកទីកន្លែងបញ្ចុះខ្មោចឆ្កែនោះល្អសមគួរ ហើយលោករំពឹងពិចារណាថាតើឡូវនេះឆ្កែនោះទៅកើតឯណា លោកពិចារណាទៅដឹងថា ឆ្កែនោះទៅកើតជាកូនស្តេចស្រុកចិនមានមុខដូចជាឆ្កែ លោកនិយាយនឹងអស់កូនសិស្សថា ឆ្កែនោះទៅកើតជាកូនស្តេចស្រុកចិនហើយ ។ ឯកូនស្តេចស្រុកចិននោះធំឡើង អាពុកស្លាប់ទៅ បានកូនសោយរាជ្យជំនួសអាពុកនោះឡើង ។

លុះស្តេចដែលមានមុខដូចជាឆ្កែនោះ បានសោយរាជ្យកាលណា បើនរណាមើលមុខស្តេចនោះត្រង់ហើយ ស្តេចឲ្យយកអ្នកនោះទៅសម្លាប់ អស់នាហ្មឺនសព្វមុខមន្ត្រី គ្មាននរណាហ៊ានមើលមុខស្តេចនោះឡើយ ឯស្តេចបានជាមិនឲ្យគេមើលមុខ ពីព្រោះមុខស្តេចនោះដូចជាមុខឆ្កែ ដ្បិតស្តេចខ្មាសគេមិនឲ្យមើល លុះស្តេចសោយរាជ្យយូរបន្តិចទៅ កើតឈឺតែក្នុងក្បាលនោះមិនចេះបាត់ យកគ្រូហ្មឯណាមកមើលមិនចេះបាត់ ហើយស្តេចឲ្យហោរគន់គូរមើលជម្ងឺនោះ ហេតុម្តេចបានជាឈឺមិនចេះជា ដល់ហោរគូរមើលទៅដឹងថា កន្លែងដែលកប់ខ្មោចឆ្កែនោះមានដើមឈើដុះចាក់ឫសត្រូវក្បាល បានជាស្តេចឈឺក្បាលមិនបាត់ កាលលោកព្រះសុគន្ធយកខ្មោចឆ្កែនោះទៅកប់ លោកដាំដើមឫស្សីជុំវិញខ្មោចឆ្កែនោះ ដល់ដើមឫស្សីនោះធំឡើងមានទំពាំងដុះចាក់ឫសទៅត្រូវក្បាលឆ្កែនោះ ត្រូវដូចពាក្យហោរទាយ ឯហោរនោះគូរមើលសព្វគ្រប់ហើយ យកសេចក្តីក្រាបទូលស្តេច ថាកាលជាតិមុនស្តេចកើតនៅស្រុកខ្មែរ កន្លែង

ទីដែលកប់នោះ មានដើមឫស្សីដុះឫសចាក់ត្រូវត្រង់ក្បាល បានជាចេះតែឈឺក្នុងក្បាលមិនចេះបាត់ ស្តេចឮដូច្នោះឲ្យនាហ្មឺនសើបសួររកទីកន្លែងដែលកប់ខ្មោចនោះ លុះឃើញហើយស្តេចឲ្យគាស់ខ្មោចឆ្កែនោះនាំយកទៅស្រុកចិន ធ្វើចេតិយបញ្ចុះខ្មោចនោះល្អរុងរឿង ឯស្តេចនោះអំពីថ្ងៃនោះមក បាត់ជម្ងឺឈឺក្នុងព្រះកេសនោះទៅ ហេតុដូច្នោះបានជាដឹងមកដល់យើងស្រុកខ្មែរ ថាស្តេចស្រុកចិនមុខដូចឆ្កែ បើនរណាមើលត្រង់មុខស្តេចៗ ឲ្យយកទៅសម្លាប់ ។ ឯធនញ្ជ័យដឹងដូច្នោះហើយចង់មើលឲ្យឃើញមុខស្តេចនោះ បានជាធ្វើនំបញ្ចុកឲ្យមានសរសៃវែងនឹងដើយស៊ីមើលមុខស្តេចនោះឲ្យបាន ។

ចប់ រឿងស្តេចស្រុកចិន តែប៉ុណ្ណោះ ។

# បញ្ជីរឿង

ទំព័រ

១ ខេមាខេមសរណកថា សំដែងអំពីពុទ្ធសរណៈ ព្រះមហាពិទូរ ក្រសេម រៀបរៀង (ត) ១៣៤

២ ច្បាប់ថ្មី ប្រដៅកិច្ចការផ្សេង ៗ . . . . . . . . . . . . . . . . . . . ១៤៣

៣ រឿងព្រេងខ្មែរ រឿងអ្នកដំណើរពីរនាក់ . . . . . . . . . . . . . . . . . ១៦៤

# រូបក្រៅរឿង

១ ព្រះស្តូបមហាពោធិ នៅក្រុងបាគន ភូមា . . . . . . . . . . . . . . . . ១៣៣

២ រូបភាពរឿងជាតក ធ្វើអំពីដីបញ្ចុះឋ្នាំ នៅក្រុងប.គន . . . . . . . . . . . ១៤១

# TABLE DES MATIÈRES


I. Khemā Khema Saranakathā........................ 135

II. Nouveaux conseil.................................. 153

III. Conte populaire cambodgien inédit:

Histoire de deux hommes.......................... 165


## HORS TEXTE:


I. Le temple de Mahabodhi à Pagan-Birmanie-réplique de

celui qui se trouve aux Indes........................ 133

II. Plaques émaillées représentant la vie du Bouddha..... 151



ព្រះស្តូបមហាពោធិ នៅក្រុងបាគន (ភូមា) សាងពី ព. ស. ១៧៩០ ក្បាច់រចនាធ្វើផ្តិតតាមក្បាច់រចនាព្រះស្តូបនៅស្រុកពុទ្ធគយា (ឥណ្ឌា) ។

ខេមាខេមសរណគាថា

ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត

រៀបរៀង (ត)

សរណវត្ថុ ក្នុងព្រះពុទ្ធសាសនាមាន ៣ ប្រការ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, លំដាប់នេះនឹងពណ៌នាអំពីរឿងព្រះពុទ្ធសរណៈជាមុន ក៏ក្នុងរឿងព្រះពុទ្ធសរណៈនោះនឹងបាននាំយកប្រវត្តិជាតិកំណើតរបស់ព្រះអង្គមកត្រាទុកខាងដើម ព្រោះជារឿងដែលពួកពុទ្ធសាសនិកជនត្រូវតែជ្រាបខានមិនបាន តែនឹងសំដែងតែដោយសង្ខេបដូចមានតទៅនេះ ៖

## ព្រះពុទ្ធសរណៈ

ក្នុងកាលមុនពុទ្ធសករាជ ៨០ ឆ្នាំ ក្នុងថ្ងៃមហាមង្គលសម័យពេញបូណ៌មីខែពិសាខ ព្រះពុទ្ធជាម្ចាស់ដ៏ជាបរមសាស្ដានៃពួកពុទ្ធបរិសទ្យស្ដេចឧប្បត្តិឡើង ក្នុងត្រកូលក្សត្រិយ៍សាក្យរាជវង្ស គោតមគោត្រ ជាព្រះរាជឱរសព្រះបាទសុទ្ធោទនព្រះចៅក្រុងកបិលពស្ដុ នឹងព្រះនាងមហាមាយា ជាអរិយកជាតិ គឺជាជាតិដែលចំរើនរុងរឿងដោយចំណេះវិជ្ជា នឹងរបៀបបែបផែនទំនៀមទម្លាប់ នឹងមានឫទ្ធិអំណាចក្នុងមជ្ឈិមប្រទេសដែលហៅក្នុងកាលឥឡូវនេះថា ឥណ្ឌៀ សឹងតាំងនៅក្នុងទិសពាយ័ព្យ

នៃប្រទេសកម្ពុជានេះ ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ គឺមានលក្ខណៈជាមហាបុរស ត្រូវតាមក្នុងគម្ពីរព្យាករណ-សាស្ត្ររបស់ព្រាហ្មណ៍ កាលព្រះអង្គប្រសូតបាន ៥ ថ្ងៃ ព្រះរាជបិតាឲ្យធ្វើមង្គលពិធីទទួលព្រះលក្ខណៈនឹងព្រះរាជទាន នាមថា "សិទ្ធត្ថ" វេលានោះព្រាហ្មណ៍ដែលជំនាញក្នុងក្បួនព្យាករណសាស្ត្របានព្យាករក្រាបបង្គំទូលថា ព្រះរាជឱរសនេះមានលក្ខណៈល្អត្រូវតាមក្នុងតម្រាមហាបុរិសលក្ខណ-ព្យាករណសាស្ត្រយ៉ាងបរិបូណ៌ ថាបើនៅគ្រប់គ្រងឃរាវាស នឹងបានជាស្ដេចចក្រពត្តិ មានអំណាចគ្របទូទៅលើពិភពផែនដី ថាបើចេញទ្រង់ផ្នួសនឹងបានត្រាស់ជាព្រះពុទ្ធ បានជាសាស្ដាឯកក្នុងលោក; ព្រះអង្គជាទីពេញព្រះហឫទ័យព្រះរាជបិតាយ៉ាងបំផុត បានទទួលការទំនុកបំរុងផ្សេង ៗ តាមផ្លូវលោកវិស័យឲ្យសុខសម្រានបរិបូណ៌គ្រប់យ៉ាង លុះមានព្រះជន្មល្មមសិក្សាសិល្បវិជ្ជាបានហើយ ទើបស្ដេចទៅសិក្សាវិជ្ជារដ្ឋបសាសនសាស្ត្រនឹងយុទ្ធសាស្ត្រ ។ ល ។ ក្នុងសំណាក់គ្រូវិស្វាមិត្រ ទ្រង់រៀនចេះចប់ស្ទាត់យ៉ាងឆាប់ទាល់តែអស់

បំណែរអំពីគ្រូ នឹងរកកុមារដទៃ ៗ មកប្រៀបផ្ទឹមពុំបាន; កាល ព្រះជន្មបាន ១៦ វស្សា ព្រះរាជបិតាទ្រង់ដណ្ដឹងនាងយសោធរា ឬហៅថាពិម្ពា ជាធីតាព្រះបាទសុប្បពុទ្ធ កោលិយរាជវង្ស មកអភិសេកជាព្រះជាយា លុះដល់ព្រះជន្ម ២៩ វស្សា ទើប មានព្រះឱរស ១ អង្គទ្រង់នាម រាហុលកុមារ សំងប្រសូតអំពី នាងយសោធរា ។

គ្រានោះ ព្រះអង្គទ្រង់ប្រារព្ធសេចក្ដីចាស់ ឈឺ ស្លាប់ ដែលគ្របសង្កត់មហាជនគ្រប់រូប គ្មានអ្នកណាបៀសបាន ដល់ម្នាក់ ដែរដូច្នេះព្រោះទោសដែលមិនបានស្ដាប់ពាក្យប្រ-ដៅរបស់អ្នកប្រាជ្ញ ឃើញអ្នកដទៃចាស់ ឈឺ ស្លាប់ ក៏ឡេឈ្អឹន ធ្អន់ស្អប់ខ្ពើម មិនគិតដល់ខ្លួនថា វានឹងដួបគ្នាយ៉ាងនោះដែរ វង្វេងស្រវឹងក្នុងជីវិត ឃាក់ដួបជាមិនបេះ ចាស់ ឈឺ ស្លាប់ មិនគិតរកឧបាយគ្រឿងរួចអំពីសេចក្ដីចាស់ឈឺស្លាប់ខ្លះឡើយ កាលដឹងឃើញយ៉ាងនេះហើយ គួរនឹងស្វែងរកឧបាយគ្រឿង រួចចាកទុក្ខទាំងនេះ ទើបគាប់ ព្រោះធម្មតាសភាវៈទាំងពួង សុទ្ធតែមានរបស់ដែលផ្ទុយគ្នាសម្រាប់កែគ្នាជាដរាប ដូច

យ៉ាំងមានក្ដៅហើយ មានត្រជាក់កែ មានងងឹតហើយ មានភ្លឺកែ តែការដែលនឹងរកឧបាយកែទុក្ខ ៣ យ៉ាងនេះ មិនមែនជារបស់ងាយឡើយ អ្នកដែលនៅក្នុងឃរាវាសវិស័យ ឃើញជាស្វែងរកមិនបាន ព្រោះឃរាវាសជាទីបង្អៀតបង្អល់ណាស់ ហើយជាទីតាំងនៃអារម្មណ៍ដ៏ធ្វើចិត្តឲ្យសៅហ្មង ដោយហេតុសេចក្ដីស្រឡាញ់ សេចក្ដីស្អប់ សេចក្ដីវង្វេង ថែមទាំងក្នុងរាជត្រកូលក៏រឹតតែស្រវឹងវង្វេងទៅដោយពួកស្រ្តីបំរើទាំងថ្ងៃទាំងយប់ រឹតតែធ្វើជីវិតឲ្យទទេណាស់ឡើង ព្រះអង្គទ្រង់នឿយណាយក្នុងសេចក្ដីរស់នៅរបស់ព្រះអង្គ ដែលអ្នកដទៃសំគាល់ឃើញថាជាសុខក្រៃពេកក្នុងផ្លូវលោកិយ ទ្រង់ឃើញបព្វជ្ជាជាឱកាសដែលឃ្លាតអំពីអារម្មណ៍ដែលដឹកនាំចិត្តឲ្យវង្វេងម្លៅជាឱកាសស្រួលនឹងបានស្វែងរកឧបាយនោះ ដើម្បីនឹងបំពេញឲ្យជាប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃ ធ្វើជីវិតឲ្យមានប្រយោជន៍កើតផ្កាផ្លែ កុំឲ្យអសារសូន្យសោះដូច្នេះ កាលទ្រង់ព្រះចិន្តាឃើញដូច្នេះហើយ ទើបទ្រង់បង្អោនព្រះអជ្ឈាស្រ័យទៅក្នុងបព្វជ្ជា មិនអាលោះអាល័យក្នុងឃរាវាសសម្បត្តិ ។

នាសម័យថ្ងៃមួយ ព្រះសិទ្ធត្ថកុមារចេញពាកនិវេសន៍បន្ទះដល់ធ្នោរស្ទឹងអនោមា ទ្រង់អធិស្ឋានភេតបព្វជិត ហើយក៏ស្ដេចទៅសិក្សាលរមើលលទ្ធិសម័យរបស់អាឡារតាបស និងឧទ្ទកតាបសជាអាចារ្យមេគណៈធំ ដែលមហាជនរាប់អានល្បីល្បាយក្រៃឈ្មោះក្នុងវេលានោះ ព្រះអង្គទ្រង់សិក្សាលរមើលក្នុងលទ្ធិនោះគ្រប់យ៉ាងទៅ ឃើញថាមិនមែនជាផ្លូវសម្មាសម្ពោធិញាណទើបព្រះអង្គចេញពាកសំណាក់អាចារ្យទាំងពីរ ចារិកតទៅបន្ទះដល់តំបន់ឧរុវេលាសេនានិគម ទតព្រះនេត្រឃើញស្ថានទីនោះស្រួលសម្រាប់អ្នកប្រកបសេចក្ដីព្យាយាម ទើបទ្រង់សំណាក់នៅទីនោះ ទ្រង់បំពេញទុក្ករកិរិយាទរមានរាងកាយអស់កំណត់ ៦ ឆ្នាំ ទ្រង់ឃើញថា គ្មានផ្លូវសម្រេចហើយទើបទ្រង់ផ្លះផ្លូវដំណើរជាថ្មី គឺទ្រង់ដំណើរផ្លូវកណ្ដាល បំពេញវីរិយក្នុងផ្លូវចិត្ត ទើបបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ-ញាណ បាននូវបញ្ញាជាគ្រឿងដឹងនូវធម៌ដ៏វិសេស ជាទីពេញព្រះហឫទ័យថា "ដឹងហើយ" គឺដឹងអរិយសច្ចនោះឯង ក្នុងរាត្រី

នៃវិសាខបូណ៌មី ក្រោមដើមពោធិអស្សត្ថព្រឹក្ស ក្នុងកាលមុនពុទ្ធសករាជ ៤៥ ឆ្នាំ ។

ឯកោវ លោកេ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ ព្រះអង្គតែមួយអង្គប៉ុណ្ណោះ ក្នុងលោកនេះ ជាអ្នកត្រាស់ដឹងនូវពោធិញាណដោយប្រពៃចំពោះព្រះអង្គឯង គ្មានបញ្ញាដទៃរបស់អ្នកឯណានីមួយនឹងជាងនេះទៅទៀតបាន ព្រះអង្គដល់នូវសេចក្ដីបរិសុទ្ធផុតប្រមាណ មានអសេក្ខធម្មក្ខន្ធគឺសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ បរិបូណ៌ក្នុងព្រះសន្ដាន គ្មានអ្នកណាក្នុងត្រៃភពនឹងប្រៀបផ្ទឹមឲ្យត្រឹមស្មើបាន ទ្រង់លះកិលេសទាំងពួងព្រមទាំងវាសនា ឲ្យដាច់ខាតជ្រះស្រលះគ្មានសេសសល់ ព្រះអង្គបរិសុទ្ធព្រមទាំងកាយវាចាចិត្ត គ្មានសេចក្ដីទុច្ចរិតឯណានីមួយ ដែលព្រះអង្គលះមិនទាន់បាន គោងបិទបាំងទុកកុំឲ្យអ្នកដទៃដឹងឃើញនោះគ្មានសោះឡើយ មានព្រះហឫទ័យតាំងស្មើក្នុងលោកធម៌ គ្មានរំភើបឬស្រែបស្រាល ហើយអាចនឹងលើកបញ្ញត្តិឡើងប្រដៅសត្វដទៃឲ្យរួចចាកសំសារទុក្ខបានផង មានព្រះហឫទ័យប្រាថ្នាប្រយោជន៍គុណដល់

សព្វសត្វជានិច្ច ទ្រង់ប្រកបសត្តូបការកិច្ច ដោយមិនបាន សំឡឹងលាភសក្ការៈអំពីអ្នកឯណា ទ្រង់សំដែងធម្មកថាប្រដៅ វេនេយ្យសត្វដោយត្រៃញាណ គឺសីល សមាធិ បញ្ញា ជា ឧបាយគ្រឿងលះកិលេសយ៉ាងគ្រោតគ្រាត យ៉ាងកណ្តាល យ៉ាងសុខុម ទាល់តែអស់ទៅជាទីបំផុត ទ្រង់ប្រដៅទេវតា មនុស្ស ពួកភពួសត្វឲ្យវៀសចាកកុមគ្គមិច្ឆាបដិបត្តិ ដែល មិនមែនផ្លូវព្រះនិព្វានឲ្យបដិបត្តិដំណើរក្នុងមជ្ឈិមាបដិបទាផ្លូវ កណ្តាល គឺមគ្គមានអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ដ៏សង្គ្រោះចូលក្នុងកងសីល សមាធិ បញ្ញានោះឯង ពពួក វេនេយ្យសត្វអ្នកមានឧបនិស្ស័យ បានស្តាប់ធម្មទេសនាដែល ទ្រង់ប្រដៅនោះ ហើយបដិបត្តិតាម ក៏បានលុះធម៌វិសេស គឺមគ្គផលនិព្វាន កន្លងបង់នូវភាវៈជាបុថុជ្ជន ឡើងកាន់អរិយ-ភូមិ គឺជាព្រះសោតាបន្ន សកទាគាមី អនាគាមី អរហន្ត តាមសមគួរដល់ឧបនិស្ស័យ ។

បើនឹងសរុបរួមសេចក្តីទៅ ព្រះគុណសម្បត្តិដ៏មាននៅក្នុង ព្រះអង្គសម្តេចព្រះបរមសាស្តា កំណត់ជាអាការមាន ៣ ប្រការ

គឺព្រះវិសុទ្ធិគុណ ១ ព្រះបញ្ញាគុណ ១ ព្រះករុណាគុណ ១, ឯព្រះវិសុទ្ធិគុណនោះបានដឹងបទថា អរហំ ព្រះអង្គជាអ្នកឆ្ងាយចាកកិលេសគ្រឿងសៅហ្មងចិត្ត គឺ រាគៈ ទោសៈ មោហៈ យ៉ាងគ្រោតគ្រាត យ៉ាងកណ្ដាល យ៉ាងល្អិត ព្រះអង្គលះបានដោយអំណាចសីលសមាធិ បញ្ញា ទៅជាបុគ្គលមានខន្ធសន្តានដ៏បរិសុទ្ធ គួរតែងតាំងបញ្ញត្តិដល់ពពួកពុទ្ធបរិសទ្យ គួរដល់អាមិសបូជារបស់សត្វលោក អាចឲ្យផលបរិបូណ៌ដល់អ្នកបូជា លោកទើបធ្វើសក្ការបូជាត ៗ មកដរាបដល់សព្វថ្ងៃនេះ ព្រះពុទ្ធគុណបទអរហំនេះ ជាព្រះគុណនាមដ៏ធំ ប្រកាសព្រះវិសុទ្ធិគុណក្នុងអង្គព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ប្រការ ១ ។

បំណែកឯព្រះបញ្ញាគុណនោះបានដឹងបទថា សម្មាសម្ពុទ្ធោ ព្រះអង្គជាអ្នកត្រាស់ដឹងនូវរបស់ពិតយ៉ាងប្រសើរ គឺអរិយសច្ចធម៌ ៤ ដោយព្រះអង្គឯង, វិជ្ជាចរណសម្បន្នោ ព្រះអង្គជាអ្នកដល់ព្រមដោយវិជ្ជានឹងចរណៈ សុគតោ ព្រះអង្គជាអ្នកទៅកាន់លោកុត្តរធម៌ដោយល្អ, លោកវិទូ ព្រះអង្គជាអ្នកទ្រង់ជ្រាបច្បាស់នូវលោក មានសង្ខារលោកជាដើម ឬនបទនេះ

ជាគុណនាមប្រកាសព្រះបញ្ញាគុណដ៏មាននៅក្នុងអង្គព្រះបរម-សាស្ដា ជាកំលាំងដ៏ធំក្រៃលែង ក្នុងការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធប្រការ ១ ។

បំណែកឯព្រះករុណាគុណនោះបាននឹងបទថា អនុត្តរោ បុរិសទម្មសារថិ ព្រះអង្គជួបជានាយសារថីដ៏សំខាន់ ទ្រង់ទូន្មានបុរសដែលគួរទូន្មាន គ្មានអ្នកណាប៉ុនទូន្មានជាងព្រះអង្គ គឺទ្រង់ទូន្មានឲ្យលុះលោកុត្តរធម៌ ជាអកុប្បធម៌ គ្មានវេលានឹងត្រឡប់មកកាន់លោកិយធម៌ទៀត សត្ថា ទេវមនុស្សានំ ព្រះអង្គបានជាសាស្ដា (អ្នកប្រដៅ) របស់ទេវតានឹងមនុស្សទាំងឡាយ ពុទ្ធោ ព្រះអង្គជាអ្នកភ្ញាក់ នឹងជាអ្នកដាស់ពួកពុទ្ធវេនេយ្យឲ្យភ្ញាក់អំពីសេចក្ដីលក់ គឺកិលេសនិទ្រារម្មណ៍ ជាអ្នកបានធ្វើនូវពុទ្ធកិច្ចពេញទី ភគវា ព្រះអង្គជាអ្នកបែកបាយនូវព្រះធម៌របស់ពិតដល់វេនេយ្យសត្វទាំងឡាយ គុណនាម ៤ បទនេះ ប្រកាសព្រះមហាករុណាគុណដ៏មាននៅក្នុងព្រះអង្គ ព្រះគុណសម្បត្តិទាំង ៩ ប្រការនេះ ប្រកាសព្រះពុទ្ធគុណដ៏ជាកំពូលនៃសេចក្ដីល្អទាំងពួងសឹងមាននៅក្នុងព្រះអង្គ នឹងរក

សាស្តាឯណាទ្រង់នូវគុណសម្បត្តិដូច្នេះគ្មាន ទើបរាប់ថា ព្រះពុទ្ធជាសរណៈរបស់លោកប្រការ ១ ។

ព្រះធម្មសរណៈ

ព្រះសម្មាសម្ពុទ្ធជាអ្នកចេះដឹងពិត ឃើញពិត ជាអ្នកមានខន្ធសន្តានបរិសុទ្ធផូរផង់ពិត ហើយជាអ្នកមិនឥតគំនិតសោយសុខតែមួយព្រះអង្គឯង បានសំដែងសាសនធម៌ទុកឲ្យសត្វនិករបដិបត្តិតាមច្រើនបែបច្រើនបទយ៉ាងវិចិត្រ ធ្លុនល្មមនឹងកម្រាបកិលេសដែលកើតឡើងក្នុងផ្លូវកាយវាចាចិត្ត នឹងរកសាស្តាដូចព្រះអង្គគ្មាន សាស្តាឯទៀតមិនសូវអំពល់នឹងប្រកាសសាសនធម៌បង្កុលខុស បង្កុលត្រូវ ផ្លូវអាក្រក់ល្អ បាបបុណ្យ គុណទោស ប្រយោជន៍អប្រយោជន៍ ឲ្យសត្វដឹងជាយ៉ាងណាគួរលះ យ៉ាងណាគួរប្រកបឲ្យកើតឲ្យមានឡើង សាស្តាខ្លះក៏មិនប្រាកដថាបានប្រកាសសាសនធម៌អ្វីទុក ខ្លះក៏ប្រកាសបន្តិចបន្តួច ៦-៧ ខ យ៉ាងច្រើនណាស់ត្រឹម ១០ ខទុកឲ្យសត្វបដិបត្តិតាម ក៏ឯខសាសនធម៌នោះទៀត ក៏មិនឃើញជាសំខាន់

ត្រង់ណា បេះតែកេណ្ឌាឲ្យជឿឲ្យភក្ដីនឹងព្រះជាម្ចាស់ឲ្យច្រើន ៗ ក៏បានសុខហើយ អ្នកប្រាជ្ញក្នុងសម័យនេះដែលមិនមែនជាព្រះ អាចនឹងបញ្ញត្តិសាសនធម៌ឲ្យល្អជាងព្រះជំពូកខ្លះទៅទៀត តាមដែលគិតមើលទៅឃើញថា ប៉ុណ្ណឹងមិនល្មមនឹងកម្ចាបកិលេសទាំងឡាយរបស់សត្វឲ្យរងាបរម្ងាប់ទៅបាន ប្រៀបបីដូចជាភ្លើងឆេះផ្ទះមួយ បុគ្គលយកទឹកមួយផ្តិលទៅលត់ នឹងរលត់ម្ដេចបាន បំណែកឯសរណៈបំពូកខ្លះដែលគ្មានប្រកាសពាក្យប្រដៅទុកសោះ មិនបាច់ពោលឡើយ តែសម្រាប់មនុស្សដែលខ្សត់វិចារណបញ្ញារមែងជឿកាន់យកដោយងាយ ៗ ។

បំណែកឯព្រះបរមសាស្ដាមិនដូច្នោះ បានទ្រង់ប្រកាសសាសនធម៌ច្រើនក្បួនច្រើនប្រភេទ បរិសុទ្ធបរិបូណ៌អស់បែបនឹងរកសាស្ដាឯណានីមួយអាចផ្ទៀត ឬយល់ទាស់ខាតខុសខ្វះកន្លះត្រង់នេះត្រង់នោះទៀតមិនបាន វៀរលែងតែបុគ្គលពាលដែលដឹងមិនដល់មិនយល់ល្អអាក្រក់ ប្រកបដោយទិដ្ឋិសំគាល់ថាខ្លួនវិសេស វាអាចនឹងពោលថាមិនដល់នឹងរាក់បាន ព្រះពុទ្ធវិបនដែលទ្រង់ប្រទានទុករហូត ៤៥ ឆ្នាំ តាំងតែបានត្រាស់

ដរាបនិព្វាន ព្រះអរហន្តបើរជាសាវកររបស់ព្រះអង្គបានរៀបរៀង ទុកជាពួកជាកង កំណត់ទុកជាខន្ធបាន ៨.៤០០០ ព្រះធម្មក្ខន្ធ បើនឹងកំណត់ជាសៀវភៅតាមដែលសៀមបានបោះពុម្ពហើយ សៀវភៅកម្រាស់ប្រមាណ ២ សង្ទីម៉ែត្រកន្លះ ទទឹង ១៦ សង្ទីម៉ែត្រ បណ្ដោយ ២៤ សង្ទីម៉ែត្រ រួមទាំងអស់ ៤៥ ក្បាល ក្រៅអំពីនេះនៅមានគម្ពីរបន្ទាប់បន្សំ ដែលហៅថា អដ្ឋកថា ដីកា អនុដីកា យោជនា នឹងគម្ពីរដោយឡែកផ្សេងទៀតជាច្រើន រួមគម្ពីរក្នុងព្រះពុទ្ធសាសនាទាំងអស់ប្រមាណជាង ៣០០ គម្ពីរ ឃើញថាមានចំនួនច្រើនជាងគម្ពីរពាហិរសាសនាក្នុង ១០០ ជា ១ ព្រះឱវាទទាំងអស់នេះបំណែកចេញជា ២ ប្រភេទ គឺព្រះធម៌នឹងព្រះវិន័យ ព្រះធម៌ជាឱវាទទូទៅដល់បុគ្គលគ្រប់ជាន់ បំណែកឯព្រះវិន័យជាក្រឹត្យសម្រាប់ភិក្ខុ ភិក្ខុនី កាន់កាប់នឹងបដិបត្តិផ្ទាល់ខ្លួន មានច្រើនរយសិក្ខាបទ ។

ធម៌គឺធម្មជាតិឬធម្មតា របស់ឯណាខុសធម្មជាតិ ឬខុសធម្មតា របស់នោះមិនមែនជាធម៌ ខសំខាន់គឺកុំប្រឡំយករបស់ដែលខុសលំអានធម្មជាតិ ឬខុសលំអានធម្មតាមកថាជាធម៌

បើជាប្រទូស្សប៊ូលប៊ិត្តដូច្នោះ អាចនឹងធ្វើឲ្យបដិបត្តិខុស ការដែលនឹងធ្វើសេចក្តីប៊ូលប៊ិត្តថា យ៉ាងណាជាដូចម្តេច គោងមានហេតុផលពិសោធឲ្យត្រឹមត្រូវ ខ្លួនឯងអាចកំបាំងវង្វេងដោយគំនិតខ្លួនឯងក៏បាន ព្រោះមនុស្សប៉ុប្មានច្រើនតែគិតប៊ូលខាងខ្លួន ឬពុំដូច្នោះក៏ប្រកាន់ដោយអំណាចទិដ្ឋិ, ដែលព្រះអង្គទ្រង់សំដែងធម៌ គឺទ្រង់សំដែងក្រឹត្យនៃធម្មតាដែលអាចនឹងប្រព្រឹត្តទៅបាន មិនបានទ្រង់សំដែងបំផ្លើសក្រៅក្រឹត្យធម្មតា ហើយធម៌ទាំងឡាយដែលទ្រង់សំដែងនោះ ក៏មិនបាននាំមកអំពីឯណា ជារបស់មាននៅក្នុងលោកនេះស្រាប់ហើយ. តែមនុស្សទាំងពួងមិនអាចនឹងបាន ព្រះអង្គគ្រាន់តែជាអ្នកលើកឡើងបង្ហាញប៉ុណ្ណោះ ធម៌នោះលោកកំណត់ទុកជា ៣ ជាន់ ធម៌ជាន់ទាបជាគោលប្រព្រឹត្តឲ្យទៅជាមនុស្សល្អក្នុងបច្ចុប្បន្ន ធម៌ជាន់កណ្តាលជាគោលប្រព្រឹត្តឲ្យទៅជាមនុស្សល្អជាងនេះ ក្នុងខាងមុខឬជាតិមុខ ធម៌ជាន់ខ្ពស់ជាគោលប្រព្រឹត្តឲ្យទៅជាមនុស្សល្អបំផុត សេចក្តីប្រព្រឹត្តតាមក្រឹត្យធម្មតាបាត់ជា ៣ ផ្លូវ គឺផ្លូវកាយ វាចា ចិត្ត មានទាំងជាន់ទាប ជាន់កណ្តាល ជាន់ខ្ពស់

ជារបស់ជ្រាលជ្រៅដោយលំដាប់ ជាគ្រឿងសម្រាប់បំបាត់សេចក្ដីអាក្រក់ដែលកើតឡើងក្នុងផ្លូវកាយវាចាចិត្ត ប្រៀបដូចជាឱសថផ្សេងៗ សម្រាប់បំបាត់រោគក្នុងកាយមនុស្ស បុគ្គលរាល់រូបគួរមានធម៌ក្នុងចិត្ត មនុស្សដែលរាប់ថាល្អសុទ្ធតែមានធម៌ក្នុងចិត្តទាំងអស់ ដូចយ៉ាងបុគ្គលបំពួកខ្លះមិនប្រាកដថាបានរៀនធម៌អាថ៌ ឬនឹងដឹងស្គាល់ថា អ្វីជាធម៌ក៏ទេ ឬនឹងបានសមាទានសីលប្រាំតាំឧបោសថក៏ទេ តែជាបុគ្គលសុភាពមិនធ្វើការបៀតបៀនខ្លួននឹងអ្នកដទៃ ប្រព្រឹត្តតែកិច្ចដែលជាប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃ ជាអ្នកមានកេរ្តិ៍ឈ្មោះល្អជាទីរាប់អាននៃប្រជុំជនដ៏ច្រើន បាននូវសេចក្ដីសុខសម្រាន្តក្នុងលោកនេះរហូតកាល មិនដែលត្រូវទោសទណ្ឌកម្មឯណានីមួយដោយសារសេចក្ដីប្រព្រឹត្តរបស់ខ្លួន បុគ្គលដូច្នេះពិតមែនតែមិនដឹងថាអ្វីជាធម៌ តែកិរិយាដែលប្រព្រឹត្តដូច្នោះត្រូវទៅលើធម៌របស់ព្រះសម្មាសម្ពុទ្ធជាច្រើន ទើបបានសុខរុងរឿងដូច្នេះ ។

( មានតទៅទៀត )



រូបភាពរឿងជាតក ធ្វើអំពីដីបញ្ចុះថ្នាំយ៉ាងជាន ប្រតិស្ឋានទុកនៅប៉ិតឡែក
ក្រុងបាគន សាងពី ព.ស. ១៦០០ ។

ច្បាប់ថ្មី

## ច្បាប់ថ្មី

*បទព្រហ្មគីត*

ពីព្រេងព្រឹទ្ធឲ្យទូន្មាន ចែងចងជានិទាន ទុកគ្រាន់មើលជាច្បាប់ថ្មី ។ ឲ្យអស់កូនចៅក្រោយ ស្ដាប់កុំឲ្យភ្លេចស្មារតី ប្រដៅទាំងប្រុសស្រី យកទុកខ្លួនគ្រប់អាត្មា ។ កើតមកបានជាមនុស្ស ទោះស្រីប្រុសក្រណាស់ណា ក្រគិតក្នុងអាត្មា ឲ្យបានដឹងសមនឹងគួរ ។ នឹងអស់ញាតិសន្ដាន សោះគេមានពាក្យថាផ្លូ កុំឆ្មើងកុំតែងតួ ធ្វើកំប៉ោងកុំពាក្យធំ ។ នឹងដើរដូចភុជង្គ ឲ្យឱនអង្គអាចអារម្មណ៍ ឲ្យត្រូវនឹងច្បាប់ក្រម ប្រើប្រណិបត្តិកុំបីឆ្គង ។ រៀនបទរៀនបាទបាស កុំប្រឡាសលើសរៀមច្បង ស្រដីនឹងអ្នកផង ពាក្យឲ្យគួរកុំឯងរ៉ឺយ ។ អឺអើអញជាប់សាប់ ឆ្គងពាក្យពេចន៍គេស្រដី ដើមដៀលឲ្យអប្រិយ៍ ស្រដីថាកូនឥតពូជ ។ ចាស់ទុំមិនប្រដៅ ជេរកូនចៅទើបវាខូច គេថាកូនឥតពូជ មិនដឹងច្បាប់នឹងចាស់ទុំ ។ គេដៀលមកម៉ែឪ ពាក្យអាស្រូវស្អុយរហុំ គេស្ដីដើមដៀរដុំ

ដំណៀលនោះមកដល់ចាស់ ។ កុំកាបកុំស្ទួតពេក កុំបម្រៀក រៀនរហ័ស កុំខ្លាបកុំហានណាស់ ឲ្យរំពឹងរំពៃគ្រប់ ។ ទោះដេកឲ្យរហ័ស ភ្ញាក់មុនចាស់ឡើងលុបមុខ មាត់មើលឲ្យសព្វគ្រប់ ទ្រព្យរបស់សឹមដេកវិញ ។ ស្លាម្លូស៊ុំឲ្យប្រៀក កុំបីបៀកទាំងមូលមិញ តូចធំឲ្យប្រៀកបេញ តាមពាក្យចាស់ថាអភ័ព្វ ។ ដេកយប់កុំដេកយូរ ហើយទទូរដួបគេស្លាប់ សំពត់ស្លៀកឲ្យខ្ជាប់ កុំអាក្រាតបេញពីខ្លួន ។ ទោះដេកកុំស្រមុក ឲ្យលង់លក់ក្រៅពីក្បួន ទោះភ្ញាក់ឲ្យដឹងខ្លួន ឡើងអង្គុយកុំមាត់ខ្លាំង ។ ប្រែប្រាណប្រុងវិញ្ញាណ ខ្លាចក្រែងមានចោរចិត្តខ្លាំង ប្រញប្រាណប្របជញ្ជាំង ជញ្ជូនទ្រព្យលួចយកទៅ ។ បើឥតមោះមន្ទិល កុំឲ្យខ្ជិលដេកទៅវិញ ភ្ញាក់ឡើងក្រោកបុះបេញ រកជក់ឬាំស៊ុម្ល្ហា ។ ទោះពេលពន់ព្រលប់ ឲ្យគន់គ្រប់ទ្រព្យផងណា កាំបិតខាងអាត្មា ឲ្យសិតទឹកទុកបុងជើង ។ ប្រអប់ដាក់ទឹមស្នា ថ្វាយទេវតារក្សាយើង ហើយឲ្យបម្តក់ភ្លើង នៅក្រានក្រៅកុំឲ្យដាប់ ។ កុំឲ្យអស់រលីង រលត់ភ្លើងហើយជាភ្លេច សព្វថ្ងៃ

មើលកុំដាច់ កុំដើរយកពីផ្ទះគេ ។ ថៃទាំមើលបង្ក្រាន ឧស ឲ្យមានកុំទម្មេរ បង្កាត់បង្កើតកេរ្តិ៍ កុំប្រហែសឲ្យស្ងួណ្យសុង ។ ប្រយ័ត្នក្រែងក្រងាយ ពុំសប្បាយឈឺពោះពុង បង្កាត់កំដៅ អង្គុ អុបបំភ្លឺមើលនេះនោះ ។ មានកាលយប់ងងឹត ភ្លេបមិន គិតប្អូនកូនជុះ គ្មានភ្លើងអុបបន្ទុះ ក្រានរលុះរលត់ផេង ។ រត់រកភ្លើងសស្រោក ព្រួយពិបាកតែខ្លួនឯង ហេតុខ្ជិលពុំគិត ក្រែង ក្រយប់ថ្ងៃសោះដើរឆ្ងាយ ។ ហើយឲ្យថៃទាំទឹក ទោះ យប់ព្រឹកកុំគិតងាយ ដងដាក់ក្អមរាល់រាយ សព្វព្រួបពាង អាងអុងធំ ។ កុំឲ្យស្ងួតក្អមផេង អស់រលីងពីពាងធំ គ្មាន សោះនោះមិនសម ប្អូនក្រែងក្រទោះយប់ថ្ងៃ ។ ទោះដើរទៅ ឆ្ងាយជិត កាន់កាំបិតកំដរដៃ ក្រែងមានមែកឈើព្រៃ កាប់ កាន់មកទុកជាឧស ។ ប្អូនកាលក្រែងបន្លា មុតអាត្មាគ្រាន់ ចាក់ផស់ ជាគ្រឿងគ្រប់ពុំខុស ការសត្រូវទោះធ្នាផ្តៃ ។ ដើរព្រៃគន់មើលលើ ឃើញស្លឹកឈើជាបន្លៃ កាប់កាន់កុំ ដៃទេ អង្គុយគន់មើលផ្ទេងស្តាំ ។ ក្រែងមានឈើព្រៃងាប់ គួរកាប់កាន់យកជាថ្នាំ ផ្ញើក្រានគ្រាន់ដណ្តាំ បាយបានឆ្អិន

ឆាប់ដូចចិត្ត ។ សោះស្រីស្រដីបាន ដ្បិតឱសមានមិនព្រួយ គិត សព្វថ្ងៃប្រុងគំនិត ថែទាំទើបគង់របស់ ។ មាសប្រាក់ ស្រូវអង្ករ ទុកឲ្យល្អកុំសប្បុរស សំបៃកុំឲ្យអស់ មើលថែ ប្ដីនឹងខ្លួនឯងហោង ។ ស្លូវស្លួបកុំឲ្យដាច់ បើគង់តិចឲ្យឧស្សាហ៍ រិះរកផ្សំទៀតណា ឲ្យបានច្រើនក្រវើនទុក ។ នឹងបាយគិត មុខក្រោយ ទោះនឹងឲ្យៗមើលមុខ កុំឲ្យស៊ុកគ្រលុក ទោះ នឹងទុកឲ្យបំណាំ ។ រដូវធ្វើបម្ការ ឲ្យឧស្សាហ៍គ្រឿងគ្រប់ដាំ ស្លឹកគ្រៃខ្ចីត្រប់ត្រាំ ត្រាវត្រសក់គ្រប់បន្លែ ។ កុំខ្ជិលកុំប្រអូស ទៅងងូសរកសុំគេ គេមិនឲ្យឯងទេ ហេតុគឺមោះព្រោះខ្ជិល ដាំ ។ ទោះធ្វើស្រែបម្ការ ឲ្យរក្សាមើលថែទាំ កុំខ្ជិលកុំប្រហាំ បបបូកដីស្មៅវល្លិផង ។ កុំឲ្យបង់កំឡាំង ទោះខែប្រាំងប្រើ ឲ្យដង ទឹកទៅស្រោចស្រប់ផង ឲ្យលូតលាស់មានផ្កាផ្លែ ។ ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំប្អូញប្អែ ខ្លាំងខ្សោយកុំឲ្យ ថ្ងៃ ខ្លាចតែនឿយហើយមិនធ្វើ ។ ដាងយប់បិតឫស្សី ត្បាញជាស្អីឈ្នាងកញ្ជើ កុំឲ្យស្រីស្ដីលើ ឥតអំពើធ្វើលេង ទៅ ។ កុំទុកដៃទទេ ដាងទំនេរបោចស្នោព្រៅ ខាងផ្ទះ

ខាងលំនៅ ឲ្យរាលកាលកើតសុខ ។ ឲ្យមានក្តីបារម្ភ ធ្វើ
ស្រែកុំបោលបម្ការ ដឹងដែកកាំបិតព្រា ទុកឲ្យជាកុំឲ្យបាត់ ។
ដេកយប់ឲ្យរាំងទ្វារ ទ្រព្យជាៗប្រុងប្រយ័ត្ន ត្របៀកបាំកុំភ្លាត់
កុំភ្លេចបោលមិនដឹងខ្លួន ។ ប្រយ័ត្នប្រយោជន៍យូរ ទោះលក់
ដូរមើលថៃធ្លន ទោះទ្រព្យរបស់ខ្លួន ឲ្យសួរកូនសួរប្រពន្ធ ។
កុំអាងឯងជាប្រុស ចាយរបស់មិនគិតគន់ មិនដឹងដល់ប្រពន្ធ
ព្រាក់ព្រមពាក្យឥតបើហា ។ ទោះបីបើបងប្អូន ពឹងរកខ្លួន
ទៅណាៗ ទោះទៅលេងឥតការ ឥតគេរកដើរឆ្ងាយជិត ។
ឲ្យប្រាប់អ្នកនៅផ្ទះ កុំលលាស់ឥតគំនិត គេភ័យព្រួយប្រឹងគិត
ព្រោះមិនដឹងជាទៅណា ។ បើទៅលើមានភ័ព្វ ប្រសើរគាប់
នោះឥតបើ ប្រសិនពានពស់ខ្លា ខ្យល់ចាប់បុកឥតគេសម ។
ទោះដើរមានដំណឹង ឲ្យរំពឹងអាចអារម្ភ នឹងដើរៗឲ្យសម
យប់ព្រលប់ឲ្យមាត់ក ។ កុំស្ទៀមកុំស្ទាត់ពួន លបលាក់
ខ្លួនខ្លាចមិនល្អ ឲ្យមើលឲ្យមាត់ក ដើរឲ្យល្អសោះគេបើ ។
ទោះខ្លួនត្រូវប៉ុន្មាន ពាក្យសន្តានវែងមុសា គេផ្ទៃមកអាត្មា
តាមទំនងដំណើរខុស ។ កូនអើយបាំកុំភ្លោយ កុំបាឲ្យ

អាប់កេរ្តិ៍យស ធម្មតាកើតជាប្រុស ឲ្យរករៀនច្បាប់មាត្រា ។ លោកថាហៅឆ្កួតបី ១ ឆ្កួតស្រី ១ ឆ្កួតស្រា ឆ្កួត ១ ល្បែងពាលា គឺបៀប៉ោធ្វរកំតាត់ ។ ទាក់មាន់ទាក់ទទា ផល់ភ្នាល់គ្នាបរបាញ់សត្វ អន្ទាក់ដាក់បង្កាត់ ល្បែងអស់នោះមិនកំណើត ។ ធម្មតាប៉ោនូវបៀ មិនដែលខ្មែរណានឹងកើត មិនដែលមានកំណើត មានតែលិចលង់ខ្លួនទេ ។ ប្អូនកាលគេបាញ់ឯង រៀងរាល់ល្បែងតែងនឹងរេ មានកាលឯងបាញ់គេ កុំទុកចិត្តអួតឯងប៉ុន ។ ពីព្រឹកស្ងៀកហ្វូលជរល្ងាចស្ងៀកសខ្វះបងក្បិន ពីព្រឹកត្បូកក្បាលបិន ល្ងាចមិនទាន់បិនដាក់ខ្នោះ ។ ប្អូនកាលវាចងជើង ព្យួរខ្ពស់ឡើងក្បាលដាំបុះ ភ្នែកស្លឹងតឹងក្រញូស វាទារប្រាក់ឲ្យបានឆាប់ ។ មើលមុខល្អតិចអ្វី មិនខ្មាសស្រីឈរហាំស្តាប់ មុខមិញដូចគេស្លាប់ មាត់ស្ញេញស្ញាញពេបដូចក្មេង ។ ស្រែកថ្ងូរអាយអួយយើយ អាបឹកអើយអាណិតលែង អញរកប្រាក់ឲ្យឯង ឲ្យអាបិកស្អែកនេះបាន ។ បិនឮស្រែបស្រាយមកបណ្តើររកទ្រព្យសន្តាន តឹងទារទាល់តែបាន ទ្រព្យឲ្យទៅ

ទើបវាលែង ។ អ្នកកាយអ្នកកើយកុំ គួរអារម្មាល់តែល្បែង កុំលកុំលួកលេង គួរឲ្យវាងឲ្យរេះសោះ ។ កុំឈមកុំឈរជិត ខ្លាចមិនអត់បង់កេរ្តិ៍យស កុំល្បងល្បែងនោះសោះ ប្តូរឲ្យដោះឲ្យដើរចេញ ។ ប្រាប់មួយចាំវាល់ខ្លួន ទោះបងប្អូនមិត្រសម្លាញ់ ពឹងខ្លួនឯងឲ្យចេញ ឲ្យបងការគេយកទៅ ។ ឯទ្រព្យបានទៅវា ឯជារនាស្រាប់នឹងនៅ វាបានទ្រព្យរត់ទៅ នៅតែខ្លួនជារនាស្រាប់ ។ ដល់គេមកតាំងទារ អ្នកជារនាឲ្យបានឆាប់ មិនបានគេប្រាប់ ទៅជាខ្ញុំព្រោះជារនា ។ បងប្អូនមានធុរៈ ក្រជំពាក់គេតឹងទារ បើមានទ្រព្យជួយជាកុំជារនាណាអ្នកអើយ ។ កូនអើយប្តូរកូនចាំ អាពុកផ្តាំកុំបីណាយ ប្រយ័ត្នវាល់រូបកាយ កុំភ្លាំងភ្លេចពាក្យនេះណា ។

១ ទៀតហៅឆ្កួតស្រី ប្តូរកុំបីក្លបកាមា វាតែងតោងអាត្មា ឆាំវង្វេងភ្លេចបាបបុណ្យ ។ ភ្លេចទានសីលសូណ្យសោះ ភ្លេចឃ្មាងខ្មោះដល់ជីពជន្ម ភ្លេចទោសភ្លេចទាំងគុណ ភ្លេចទាំងការកាន់រសាយ ។ បង្កើតតែទោសទុក្ខ មិនបានសុខសឹងឲ្យក្លាយ បង្កើតក្តៅក្រហាយ ឲ្យទាស់ទែងខឹងនឹងគ្នា ។ បង

ទោសគុំគង្គួន មិនគិតខ្លួនខ្លាចមរណា មានកាលក្មួយនឹងមា គុំកាប់គ្នាឲ្យសោះសូណ្យ ។ បង្កើតឲ្យបិត្តធំ ទំងគំនុំនឹងជាកូន ឯបងទំងនឹងប្អូន ម្តាយនឹងកូនគុំធ្វើគ្នា ។ ឬខ្ញុំគុំកាប់ម្ចាស់ ឲ្យក្តៅរោលរាលក្នុងអង្គា កើតទោសទាស់ពុំជា ជាគំនុំគុំមិនស្បើយ ។ មានកាលគេដាក់ឃ្នាង វាយមិនរាងបាលបិត្តឡើយ លក់ថ្លៃខ្ញុំគេហើយ មិនគិតខ្លាចស្លាប់អាត្មា ។ គេកាប់ដោតទាំងក្បាល មិនបេះបាលបិត្តឡើយណា ភ្លេចខ្លួនសូណ្យសោះសា នឹកតែត្រង់សេពសប្បាយ ។ រីឯកម្មកិលេស កុំប្រហែសគួរឲ្យណាយ គួរកុំសេពអ្នកកាយ អ្នកអើយកុំគិតសង្ស័យ ។ នេះឯងហៅធ្លុតស្រី គួរកុំបីឲ្យអាល័យ បួរបាំបងសព្វថ្ងៃ ទុកទូន្មានអង្គអាត្មា ។ អ្នកប្រាជ្ញលោកនិទាន តែងទូន្មានរាល់រូបា មួយហៅធ្លុតសុរា នោះកុំផឹកឲ្យស្រវឹង ។ វានាំភ្លេចវិញ្ញាណ ភ្លេចសីលទានសោះសូណ្យឈឹង ផឹកហើយមិនដែលនឹង នាំបិត្តនោះឲ្យធំក្រៃ ។ ឯខ្លួនឯងតូចទេ មើលទៅគេប៉ុនមេដៃ កំឡាំងឯងស្មើបៃ មិនកោតខ្លាចគេឡើយណា ។ ក្អេងក្អាងពាក្យកក្អេរ អ្នួត

ពូកែដ្បិតបានស្រា មិនមានខ្លាចនរណា ស្រដីតែរកកល
ឈ្លោះ ។ បញ្ចោរបញ្ចៀសផ្ដាស ជេររាងវាសមិនបំឈ្មោះ
នាំហេតុហើយនឹងឈ្លោះ ឆ្លើយឆ្លងពាក្យឲ្យបានទាស់ ។
ប្រពន្ធឃើញឃាត់ទៅ ប្ដីមិនត្រូវថាកុំអ្នក ឯងទឹងលោ
វាយជាក់ ដោយចិត្តធំដ្បិតបានស្រា ។ មានកាលប្អូនស្រវឹង
ភ្លេចពុំដឹងខ្លួនឡើយណា ដើរដួលដេកផ្កាប់ផ្ការ ក្រាតសំពត់
បេញពីខ្លួន ។ គេឃើញអស់កេរ្តិ៍ខ្មាស ក្មេងជៀវជុំសើច
ទ្រហឹង ដេកដូចគេស្លាប់ឈឹង ក្អែក្អួតពាសពេញទាំងខ្លួន ។
គំនិតអ្នកផឹកស្រា កុំអួតថាឯងនឹងនួន ផឹកហើយស្រវឹងមួន
ខ្លួនខ្សត់ទេអួតថាមាន ។ អ្នកស្លូតទៅជាកាច អ្នកកំឡាប
ទៅជាហ៊ាន ខុសត្រូវទៅបំពាន បំពុលខ្លួនឲ្យបានបាប ។
នេះឯងហៅផ្លូតស្រា ក្នុងធម៌ថាវាពុំគាប់ អ្នកណាផឹកហើយ
បាប បង់កេរ្តិ៍យសពុំសួស្ដី ។ គួរកុំសេពសុរា នាំអាត្មា
ឲ្យអប្រិយ៍ នឹងធ្លាក់ទៅអវិចី នរករងទុក្ខវេទនា ។ ហៃ
អស់ផងសម្មាយ កុំវាយមាយក្នុងអង្គា ប្ដូរស្ដាប់ច្បាប់នេះ
ណា ទុកទូន្មានខ្លួនសព្វថ្ងៃ ។ នេះហើយហៅផ្លូតបី

លោកស្រដីក្នុងធម៌ថ្លៃ បើអ្នកណាមួយនៃ នឹកប្រាថ្នាដោយ បំណាច់ ៗ លោកបងជាឧបមា ឲ្យអ្នកណាមួយផ្ចិតផ្ចង់ យកដែកដុលបោះបង់ ក្នុងភ្លើងក្រានឆេះប្រាលឆ្អៅ ៗ បើ កាន់ដែកដែលដុត នោះមិនមុតមិនមានក្តៅ កាន់បាននោះ ទើបហៅ បិត្តមុតមែនមិនគិតប្រាណ ៗ នេះទើបលោក ឲ្យធ្វើ អស់អំពើទាំងបីបាន ដោយធម៌ពីបុរាណ លោក ឧបមាដូច្នោះហោង ៗ សុំរេបប៉ុណ្ណេះខ្ញុំ ប្រាប់ប្រែអស់ ធម៌អាថ៌ផង ទុកទៅជាច្បាប់ហោង លើកលេងល្បងលង ប្រាជ្ញា ៗ ចាត់ចែងតែងជាបទ ព្រហ្មប្រាកដកាលបិតា ប្រដៅខ្ញុំនេះណា ចាំបងទុកជាច្បាប់ទៅ បើអ្នកឯណាមើល កុំបារព្រើលលើកពុំត្រូវ កុំសើចដៀលខ្ញុំក្រូវ សូមជម្រុវជម្រង់ ផង ៗ ទោះបីបើខាតខុស កែ្រងលើសលោះពាក្យផ្គាំផ្គង ពុំត្រូវដោយគន្លង មិនដូចច្បាប់ព្រេងមកនៃ ៗ គិតកាព្យ រាយរាប់រោះ ខ្ញុំនាមឈ្មោះអ្នកម៉ឺនមៃ លើកអស់អាថ៌នេះនៃ ជាសុរេបតែម្ល៉េះហោង ៗ ៚

## រឿងអ្នកដំណើរពីរនាក់

អំពីនេះនឹងនិយាយពីមនុស្សពីរនាក់ដើរទៅផ្លូវឆ្ងាយ បួនយប់ក្នុងព្រៃងងឹតដើរទៅមិនរួចបបួលគ្នាដេកក្នុងព្រៃ ឯអ្នកទាំងពីរបង់ដេកតែកណ្ដាល ប៉ុន្តែមិនដឹងគិតធ្វើដូចម្ដេចនឹងបានដេកកណ្ដាល បុរសពីរនាក់គិតគ្នាថា បើដូច្នោះយើងដេកយកជើងទល់គ្នា ឯបុរសពីរនាក់ដេកយកជើងទល់គ្នាក៏លក់ទាំងពីរនាក់ទៅ លុះឯក្រោយមានខ្លាមកឃើញមនុស្សដេកយកជើងទល់គ្នា ហើយទទូរសម្ដត់ជិតមើលមិនដឹងថាសត្វអ្វីវែងដូច្នេះ ខ្លាឆ្ងល់ណាស់ ដ្បិតមិនដែលឃើញ ក៏បបួលអស់សត្វឯទៀតជាច្រើនមានទាំងដំរី ក្របី គោ រមាស រមាំង ក្ដាន់ ប្រើស ទ្រាយ បបក ស្វានស្វា គ្រប់សត្វទាំងអស់មកដល់មើល គ្មានសត្វណានឹងស្គាល់សោះ លុះឯក្រោយទៀតសត្វទាំងអស់មកគិតគ្នាថា ឥឡូវនេះនឹងមានអ្នកឯណានឹងស្គាល់សត្វនេះ បើដូច្នោះយើងបបួលគ្នាមកមើលសត្វនេះច្រើនភាសាណាស់ហើយ ឥឡូវនេះនៅសល់សត្វអ្វីទៀតដែលមិនបានមក

មើល អស់សត្វទាំងនោះគិតគ្នាទៅនៅសល់សត្វទន្សាយពុំបាន មក មួយទៀតឮល្បីថាសត្វទន្សាយនេះជាអ្នកមានប្រាជ្ញា ចេះ និយាយក្បួនច្បាប់ទំលាប់ចេះកល់មាយាហាំទំនិមទំនៀមជាច្រើន បើដូច្នេះយើងប្រើបងដំរីឲ្យទៅអញ្ជើញបងទន្សាយនោះទើបបាន ដ្បិតបងទន្សាយបើមាននរណាទៅពឹងការអ្វីនោះកាន់ខ្លួនណាស់ អស់សត្វនោះគិតគ្នាហើយ ឲ្យដំរីទៅអញ្ជើញបងទន្សាយ ឯ បងដំរីទៅឃើញទន្សាយអង្គុយនៅលើក្បាលដំបូក ទន្សាយ ឃើញដំរីដើរយោកយោកមកពីនាយក៏សួរថា បងដំរីមានដំណើរ ហេតុអ្វី បានជារលះរលាំងមក ដំរីឆ្លើយថាបងទន្សាយ ដ្បិត មានសត្វអ្វីគ្មាននរណាស្គាល់ បានជាអស់សត្វក្នុងព្រៃយើងនេះ ឲ្យខ្ញុំមកអញ្ជើញបងទន្សាយឯងទៅមើល ក្រែងបងទន្សាយ ដឹងស្គាល់សត្វនោះ ឯទន្សាយឮដូច្នោះឆ្លើយថា សត្វនោះ ដូចម្ដេច តូចឬធំ វែងឬខ្លី ដំរីថាសត្វនោះធំប៉ុងធំដើម ត្នោត កណ្ដាល ហើយវែងប្រមាណប្រាំបីហត្ថ ទន្សាយឮដូច្នោះ ឆ្លើយឡើងថា ឱបើដូច្នោះបងដំរីកុំព្រួយចិត្ត ចាំខ្ញុំទៅមើលឲ្យ ស្គាល់សត្វនោះ ប៉ុន្តែបងដំរីឯងឲ្យខ្ញុំជិះលើក្បាលបងឯងទៅ

ដំរីញដូច្នោះហើយដើរចូលទៅឧនក្បាលឡើទន្សាយជិះលើក្បាលដំរីធ្វើជាក្អេងក្អាង លុះទៅដល់ហើយទន្សាយចុះពីក្បាលដំរីយកស្លឹកឈើដែលមានស្នាមដង្កូវវារដូចជាអក្សរកាន់លើកឡើងធ្វើជាសំបុត្រ ថាអស់បងប្អូនស្តាប់ខ្ញុំ ដ្បិតខ្ញុំជាបំរើព្រះឥន្ទលោកប្រើឲ្យនាំសំបុត្រមក ហើយទន្សាយឡើងលើដំបូកធ្វើជាសំបុត្រថា សត្វនេះព្រះឥន្ទលោកប្រើមក ឈ្មោះសត្វយោគីយោគា យកទាំងអស់គ្នា យកទាំងអញ យកទាំងឯងអស់សត្វឮទន្សាយមើលសំបុត្រព្រះឥន្ទឲ្យមកយកទាំងអស់គ្នា ក៏ស្ទុះបោលជាន់គ្នា ស្លាប់បាក់ដៃបាក់ជើងពាសពេញស្រែកលាន់ទាំងព្រៃ ឯមនុស្សនោះដឹងថាអស់សត្វនោះផ្អើលភ្ញាក់រត់ជាន់គ្នាស្លាប់ដូច្នោះហើយ ក្រោកឡើងលើកដៃសំពះទន្សាយថា បងទន្សាយមានគុណនឹងយើងខ្លាំងណាស់ បើសិនណាយើងមិនបានបងទន្សាយមកធ្វើប្រាជ្ញាឲ្យយើងនោះសមយើងខ្លាវាតឹងខាំស៊ីជាបំណាំវា បងទន្សាយឯងមានប្រាជ្ញាល្មមធ្វើជាសុភាបាន ឯមនុស្សទាំងពីរនាក់មើលទៅឃើញអស់សត្វជាន់គ្នាស្លាប់ពាសពេញដូច្នោះ បបួលគ្នាអារយក

សាប់រែកទាំងពីរនាក់ ហើយឃើញខ្លាសំគមមួយដើរវាជាន់បាក់ជើងដើរបានតិចៗ ក៏បបួលគ្នាយកខ្សែចងដឹកយក លុះដើរទៅបន្តិច ជួបនឹងអ្នកបររទេះគោ ឯអ្នកបររទេះគោនោះឃើញអ្នកទាំងពីររែកសាប់មកដូច្នោះ ក៏បញ្ឈប់រទេះសួរថាអ្នកធ្វើម្ដេចក៏បានសាប់ច្រើនដល់ម្លេះ អ្នកនោះបញ្ឆោតថា ផ្លែកំបាក់ជើងខ្ញុំនេះឯងវាដេញខាំ ដ្បិតផ្លែនេះជាផ្លែបណ្ដេញ ខ្ញុំតែងតែដេញសត្វមកមិនដែលស្លូតផ្ទាំងដល់មួយពេលា ក្រែងតែគ្មានសត្វ ថាបើព្រៃឯណាមានសត្វហើយមិនដែលរួចនឹងអាក្លិកផ្លែបណ្ដេញខ្ញុំនេះ ឲ្យឃើញតែស្នាមជើងនោះសង្ឃឹមជាបាន ឲ្យលាងផ្ទាំងឲ្យហើយ មុខជានឹងបានមិនដែលខានទេ ឯអ្នកបររទេះគោឮអ្នកនោះនិយាយអួតប្រាប់ដូច្នោះហេតុតែជាមនុស្សល្ងង់ ហើយចិត្តចង់បានខ្លាកំបាក់ជើងសំគមនោះណាស់ គិតថាផ្លែមែនទែន ក៏និយាយអង្វរល្បួងលោមថា បើដូច្នោះអ្នកអាណិតខ្ញុំៗ សុំដូរផ្លែអ្នកយកទៅបណ្ដេញដ្បិតស្រុកខ្ញុំមានសត្វច្រើនណាស់ ឯអ្នករែកសាប់ឆ្លើយថាបើខ្ញុំលក់ផ្លែឲ្យអ្នកឯង ផ្ទះខ្ញុំសមនឹងត្រៀមផ្ទាំងហើយ រកអ្វី

ស៊ីគ្មាន ប៉ុន្តែអ្នកបានជួបនឹងខ្ញុំម្តងដូច្នេះនេះ មិននិយាយក៏មិនបាន ឯឆ្កែខ្ញុំនេះខ្ញុំស្រឡាញ់រកអ្វីប្រៀបគ្មានទេ ដូច្នេះបើអ្នកចង់ទិញតើអ្នកឲ្យថ្លៃប៉ុន្មាន ឯអ្នកបររទេះគោឆ្លើយថា ខ្ញុំមានតែគោមួយនឹមនេះឯង តែគោនេះខ្ញុំស្រឡាញ់រកអ្វីប្រៀបគ្មាន ដ្បិតបរបានមួយថ្ងៃរាល់ល្ងាចមិនឈប់សោះក៏បាន ក្នុងមួយថ្ងៃឲ្យទឹកផឹកតែម្តង ទើបឯរបឿនដែលលឿននោះក្នុងស្រុកអាយនេះ គ្មានគោណាលឿនស្មើទេ ឥឡូវនេះចិត្តខ្ញុំចង់បានឆ្កែអ្នកឯងយកទៅបណ្តេញសត្វឯស្រុកខ្ញុំ ៗ សុំដូរជាថ្នូរគោមួយនឹមគ្រប់ទាំងប្រដាប់កណ្តឹងបង្ក្រង់ត្រដោកខ្សែទាមខ្សែបន្តោលគ្រប់ប្រដាប់ស្រាប់តែឡើងជិះបរ ខ្ញុំសុំតែខ្លួននឹងប្រពន្ធចុះចេញ អ្នកស្រាប់តែឡើងជិះបរទៅ អ្នករែកសាប់ឮអ្នកបររទេះថាដូរជាគោមួយនឹមគ្រប់ប្រដាប់ ស្រាប់តែឡើងជិះ ក៏នឹកអរក្នុងចិត្តណាស់ដោយសាររែកសាប់វាធ្ងន់ផង ហើយធ្វើជាមិនចង់ដូរ ឯក្នុងចិត្តចង់ដូរណាស់និយាយថាឆ្កែខ្ញុំនេះខ្ញុំស្រឡាញ់ណាស់ ឥឡូវអ្នកមកសុំដូរពីខ្ញុំទៅខ្ញុំកាត់ចិត្តដូរឲ្យអ្នកចុះ ប៉ុន្តែអ្នកថែរក្សាឲ្យល្អកុំឲ្យអត់ឃ្លាន ហើយអ្នកយកសាប់

នេះទុកឲ្យស៊ីតាមផ្លូវទៅ ឯអ្នកវែកសាច់ឲ្យសាច់ទៅអ្នកនោះ ល្មមខ្លាស៊ីឆ្អែត ហើយយកសាច់ដាក់លើរទេះបរទៅ ឯអ្នកម្ចាស់រទេះគោនោះក៏ដឹកខ្លាសំគមកំបាក់ជើងនោះទៅបន្តិចទៅ ឲ្យសាច់ទៅខ្លាស៊ីតែរឿយ ៗ ឯខ្លានោះបានសាច់ស៊ីមានកំឡាំងក៏ក្រាញមិនបង់ទៅ ត្រាតែដាច់ខ្សែហើយដើរចូលទៅក្នុងព្រៃ ឯអ្នកនោះដឹងជាខ្លានោះរត់ចូលទៅក្នុងព្រៃហើយរត់ទៅចាប់ហើយហៅថាបឹស ៗ អាក្លិកមកឯអញ ឯខ្លាឃើញមនុស្សទៅជិតបែរមកគំរាមធ្វើហើរ ៗ ហ៊ ៗ សន្ធាប់ឲ្យអ្នកនោះ ឯអ្នកនោះឃើញខ្លាគំរាមមុខគួរឲ្យខ្លាចដូច្នោះ ក៏ថយមកក្រោយវិញ មិនហ៊ានតាមទៅទៀត ប៉ុន្តែនឹកស្តាយមើលទៅរទេះបរទៅបាត់មិនដឹងជាទៅណា ឯអ្នកដូរខ្លានឹងរទេះគោនោះបានហើយម្ចាស់ម្នាដាក់អម្រែកលើរទេះឡើងជិះទាំងពីរនាក់បរជាប្រញាប់ទៅឲ្យតែហួសពីមុខម្ចាស់រទេះនោះ ឯអ្នកម្ចាស់រទេះដល់ខ្លាវាបោលចូលព្រៃទៅហើយនឹកស្តាយណាស់ មិនដឹងគិតធ្វើដូចម្តេច បបួលប្រពន្ធត្រឡប់ទៅផ្ទះវិញ ។៖ ៙ ——